USAID
FROM THE AMERICAN PEOPLE

WINROCK INTERNATIONAL
Putting Ideas to Work

# របាយការណ៍ស្តីអំពី
# ការប៉ាន់ប្រមាណពីវិធីសាស្ត្រនៃការផ្តល់សេវាគាំទ្រ
# នៅក្នុងមណ្ឌល និង នៅតាមសហគមន៍

រៀបរៀងដោយ រូប៊ីន ម៉ូនី និងស្រ៊ុន រចនា

ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២

# ការប៉ាន់ប្រមាណស្តីអំពីវិធីសាស្រ្តនៃការផ្តល់សេវាគាំទ្រនៅក្នុងមណ្ឌល និងនៅតាមសហគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅកម្ពុជា

ខែតុលាឆ្នាំ២០១២

---

រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

**ការបដិសេធន៍ទទួលខុសត្រូវ**:ការសិក្សាស្រាវជ្រាវនេះ អាចប្រព្រឹត្តទៅបានដោយមានជំនួយសប្បុរសពីសំណាក់ប្រជាជនអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ។ ខ្លឹមសារនៅក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវរបស់អង្គការវីនរ៉ក់អន្តរជាតិ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ ឬទស្សនៈរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# មាតិការ


**ពាក្យបំព្រួញ** ........ ១

**សេចក្តីថ្លែងអំណរគុណ** ........ ៣

**ខ្លឹមសារសង្ខេប** ........ ៤

**១. សេចក្តីផ្តើម** ........ ៩

ប្រវត្តិគម្រោង ........ ៩

តើអ្វីទៅជាអំពើជួញដូរមនុស្ស? ........ ១០

តើអ្វីទៅជាការថែទាំនៅក្នុងមណ្ឌល ហើយនិងអ្វីទៅជាការថែទាំនៅសហគមន៍ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរ? ........ ១០

គោលបំណងនៃការសិក្សា ........ ១១

**២. ការរៀបចំការសិក្សាស្រាវជ្រាវ** ........ ១២

**២.១. សំនួរស្រាវជ្រាវសំខាន់ៗ** ........ ១៣

**២.២. យុទ្ធសាស្ត្រនៃការជ្រើសរើសសំណាក** ( Sampling Strategy ) ........ ១៣

**២.៣. ការប្រមូលទិន្នន័យ** ( Data Collection ) ........ ១៤

**២.៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ** ( Limitations of Study ) ........ ១៦

**២.៥. ការពិចារណាប្រកបដោយក្រមសីលធម៌** ( Ethical Considerations )៖ ........ ១៧

**២.៦. ការពិនិត្យមើលលើឯកសារដែលមានស្រាប់** ( Literature Review )៖ ........ ១៨

**៣. របកគំហើញសំខាន់ៗ** ( KEY FINDINGS ) ........ ២២

**៣.១. តម្រូវការមូលដ្ឋានរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ........ ២២

**៣.២. សេវាគាំទ្រដែលមានដើម្បីផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ២៤

៣.២.១. ការកំណត់អត្តសញ្ញាណជនរងគ្រោះនិងអន្តរាគមន៍វិបត្តិ ........ ២៤

៣.២.២. ការថែទាំក្រោយពេលជួយសង្គ្រោះ ........ ២៥

៣.២.៣ ការធ្វើសមាហរណកម្មឡើងវិញ និង/ឬ សមាហរណកម្ម ........ ២៦

៣.២.៤. ភាពជាដៃគូ ........ ២៨

៣.២.៥. សេវាកម្មដែលផ្តល់ដល់ជនរងគ្រោះ ........................................................................ ២៩

៣.២.៦. នរណាផ្សេងទៀតដែលអាចទទួលសេវាគាំទ្រទាំងនេះ? ..................................... ៣៨

៣.២.៧. តើមានការចំណាយប៉ុន្មានសម្រាប់សេវាកគាំទ្រ? ............................................... ៣៨

**៣.៣. គម្លាតនិងបញ្ហាប្រឈម** ........................................................................................ ៤១

**៣.៤. ចំនុចខ្លាំងនិងចំនុចខ្សោយរវាងសេវាគាំទ្រនៅមណ្ឌលនិងនៅសហគមន៍** . ៤៥

**៣.៥. ការពេញចិត្តរបស់ជនរងគ្រោះចំពោះការផ្តល់សេវាគាំទ្រ** ......................... ៤៧

**៤. អនុសាសន៍** ........................................................................................................... ៤៨

**៤.១. គោលការណ៍ណែនាំសម្រាប់គំរូនៃការអន្តរាគមន៍នានា** ............................ ៤៨

**៤.២. ការបន្តផ្តល់សេវាគាំទ្រ** ....................................................................................... ៥១

៤.២.១. កំណត់អត្តសញ្ញាណជនរងគ្រោះ និងសេវាកម្មអន្តរាគមន៍វិបត្តិ .................... ៥១

៤.២.២. ការថែទាំក្រោយពេលជួយសង្គ្រោះ .......................................................... ៥៣

៤.២.៣.  ការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញ ........................ ៥៩

**៤.៣. ការពិចារណាពិសេសសម្រាប់ក្រុមគោលដៅផ្សេងគ្នា** ................................... ៦១

**៤.៤. ការបង្ការទប់ស្កាត់** ............................................................................................. ៦២

**៥. សេចក្តីសន្និដ្ឋាន** ..................................................................................................... ៦៣

**ឧបសម្ព័ន្ធ ក: ឯកសារយោង** ........................................................................................ ៦៥

**ឧបសម្ព័ន្ធ ខ: បញ្ជីរាយនាមអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ** ....................................... ៦៧

**ឧបសម្ព័ន្ធ គ: គោលការណ៍ណែនាំ អំពីការសម្ភាសន៍** ............................................. ៧១

# ពាក្យបំព្រួញ

| | |
|---|---|
| CTIP | Counter Trafficking in Persons<br>ការប្រឆាំងអំពើជួញដូរមនុស្ស |
| CCWC | Commune Committee for Women and Children<br>គណៈកម្មាធិការឃុំទទួលបន្ទុកកិច្ចការស្ត្រី និង កុមារ |
| DoSVY | Department of Social Affairs, Veterans and Youth Rehabilitation<br>មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| GBV | Gender-based Violence<br>អំពើហិង្សាផ្អែកលើយេនឌ័រ |
| ILO | International Labour Organization<br>អង្គការ ពលកម្មអន្តរជាតិ |
| IOM | International Organization for Migration<br>អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| MoH | Ministry of Health<br>ក្រសួងសុខាភិបាល |
| MoI | Ministry of Interior<br>ក្រសួងមហាផ្ទៃ |
| MoLVT | Ministry of Labor and Vocational Training<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | Ministry of Women Affairs<br>ក្រសួងកិច្ចការនារី |
| TIP | Trafficking in Persons<br>អំពើជួញដូរមនុស្ស |
| USAID | United States Agency for International Development<br>ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| UNIAP | United Nations Inter-Agency Project on Human Trafficking<br>កម្មវិធីអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិ ប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| UNICEF | United Nations Children’s Fund |

មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ

| | |
|---|---|
| WCCC | Women's and Children's Consultative Committee<br>គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |

# សេចក្តីថ្លែងអំណរគុណ

អង្គការវីនរ៉ក់ អន្តរជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកទាំងឡាយដែលបានចូលរួម និងជួយសម្របសម្រួលដល់ដំណើរការនៃការសិក្សាស្រាវជ្រាវនេះ។

អង្គការវីនរ៉ក់ អន្តរជាតិ សូមថ្លែងអំណរគុណជាពិសេសផងដែរចំពោះក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងបុគ្គលទាំងឡាយដែលបានចំណាយពេលវេលាដ៏មមាញឹករ ដើម្បីចូលរួមផ្តល់បទសម្ភាសន៍ និងផ្តល់ព័ត៌មាន ដើម្បីឆ្លើយតបនឹងសំណួរជាច្រើន។ ការចូលរួមចំណែក និងការណែនាំរបស់អ្នកទាំងអស់គ្នា បានជួយអោយក្រុមសិក្សាស្រាវជ្រាវស្វែងយល់ពីស្ថានភាពបច្ចុប្បន្នរបស់ជនរងគ្រោះដោយអំពើជួញដូរ និងបានជួយដល់ការបង្កើតកម្មវិធីជាអាទិភាពផ្សេងៗ។ អង្គការវីនរ៉ក់ អន្តរជាតិ សូមថ្លែងអំណរគុណជាពិសេសដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់មូលនិធិ និងគាំទ្រដល់ដំណើរការនៃការសិក្សាស្រាវជ្រាវនេះ។

សូមកោតសរសើរដ៏ស្មោះស្មគ្រ័ចំពោះក្រុមសិក្សាស្រាវជ្រាវ ដែលដឹកនាំដោយទីប្រឹក្សាអន្តរជាតិ លោកស្រី **រ៉ូប៊ីន ម៉ូនីយ** និង ទីប្រឹក្សាជាតិ លោក **ស្រ៊ុន រចនា** និងសមាជិកក្រុមសិក្សាស្រាវជ្រាវ កញ្ញា **អ៊ុក រស្មី** លោក**ស្រ៊ុន ទិដ្ឋា** លោក **ហឿន សម្បត្តិ** និងកញ្ញា **សុទ្ធី តុលាសត្យា**។

ជាចុងបញ្ចប់ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការរួមចំណែករបស់ស្ត្រី បុរស និងកុមារទាំងឡាយ ដែលជាជនរងគ្រោះដោយអំពើជួញដូរ ដែលបានចែករំលែកពីបទពិសោធន៍ក្នុងការទទួលបានសេវាគាំទ្រផ្សេងៗ ហើយបានជួយពួកយើងក្នុងការកំណត់ជាអនុសាសន៍ផ្សេងៗក្នុងរបាយការណ៍នេះ។

# ខ្លឹមសារសង្ខេប

អង្គការវីនរ៉ក់ អន្តរជាតិ បាននឹងកំពុងអនុវត្តនូវកម្មវិធីប្រឆាំងនឹងអំពើជួញដូរមនុស្សជំហានទី២(CTIPII) នាពេលបច្ចុប្បន្ននៅប្រទេសកម្ពុជា ដែលឧបត្ថម្ភដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID)។ ក្នុងការអនុវត្តកម្មវិធីប្រឆាំងនឹងអំពើជួញដូរមនុស្សជំហានទី២នេះ អង្គការវីនរ៉ក់អន្តរជាតិ បានរៀបចំនូវការសិក្សាស្រាវជ្រាវនេះ ដើម្បីធ្វើការប៉ាន់ប្រមាណ និងប្រៀបធៀបពីគម្រូនៃការថែទាំនៅមណ្ឌល និងការថែទាំនៅតាមសហគមន៍ ក្នុងគោលបំណងអភិវឌ្ឍវិធីសាស្ត្រឯកទេសក្នុងការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស (TIP)។ ការប៉ាន់ប្រមាណនេះ គឺដើម្បីស្រាវជ្រាវរកនូវការអនុវត្តដ៏មានប្រសិទ្ធិភាពបំផុតរបស់អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងផ្តល់ឱកាសសម្រាប់ការកែលម្អគម្រូនៃការថែទាំនៅក្នុងមណ្ឌល និងការថែទាំនៅតាមសហគមន៍ ក្នុងគោលបំណងបង្កើតវិធីសាស្ត្រឯកទេស ដើម្បីគាំទ្រទៅដល់ជនរងគ្រោះដោយអំពើជួញដូរដែលរួមទាំងបុរសផងដែរ ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះមានដូចតទៅ៖

១. ប៉ាន់ប្រមាណទៅលើតម្លៃ ការប្រើប្រាស់ និងភាពរកបាន នៃសេវាគាំទ្រទាំងនៅក្នុងមណ្ឌល និងនៅសហគមន៍ ដែលជនរងគ្រោះដោយអំពើជួញដូរកំពុងទទួលបានការថែទាំនាពេលបច្ចុប្បន្ន (ថាតើមណ្ឌល ឬសហគមន៍ចំណាយលើការផ្តល់សេវាគាំទ្រនីមួយៗអស់ថ្លៃប៉ុន្មាន មានសេវាគាំទ្រអ្វីខ្លះ បើសិនជាមាន ថាតើជនរងគ្រោះត្រូវចំណាយប្រាក់ចំនួនប៉ុន្មានដើម្បីទទួលបានសេវាគាំទ្រនេះ)។

២. កំណត់ និងប្រៀធៀបពីចំណុចខ្លាំង ចំណុចខ្សោយ ឧបសគ្គ និងការទទួលបាននូវការថែទាំនៅតាមមណ្ឌល និងការថែទាំនៅក្នុងសហគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ និងអំពើជួញដូរកម្លាំងពលកម្ម ទៅលើកុមារា កុមារី បុរស និងស្ត្រីជាដើម។

៣. ស្វែងយល់ពីទស្សនៈរបស់ជនរងគ្រោះទៅលើការថែទាំនៅមណ្ឌល និងការថែទាំនៅតាមសហគមន៍ ការពេញចិត្តរបស់ជនរងគ្រោះទៅលើសេវាគាំទ្រ និងវិធីសាស្ត្រនានាដែលអាចបំពេញទៅតាមតម្រូវការរបស់ជនរងគ្រោះដែលត្រូវបានសង្គ្រោះ ។

៤. ផ្តល់អនុសាសន៍ពីគម្រូឯកទេសនៃការថែទាំនៅក្នុងបរិបទប្រទេសកម្ពុជា ដោយផ្តោតសំខាន់ទៅលើជនរងគ្រោះដោយអំពើជួញដូរ ដូចជា កុមារា កុមារី បុរស និងស្ត្រី ហើយប្រសិនបើសមស្រប ផ្តល់អនុសាសន៍ទៅលើបញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ ដើម្បីធានាឲ្យបាននូវនិរន្តភាព។

អ្នកផ្តល់ពត៌មានសំខាន់ៗមួយចំនួន ដូចជាមន្ត្រីរាជរដ្ឋាភិបាល អង្គការដែលផ្តល់សេវាគាំទ្រនៅតាមមណ្ឌល និងសហគមន៍ ដៃគូអភិវឌ្ឍន៍ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានធ្វើបទសម្ភាសន៍

ទាក់ទងទៅនឹងតម្រូវការរបស់ជនរងគ្រោះ សេវាគាំទ្រ កង្វះខាត និងបញ្ហាប្រឈមនានាក្នុងការផ្តល់សេវាគាំទ្រទាំងនោះ ព្រមទាំងផ្តល់អនុសាសន៍សម្រាប់ការកែលម្អសេវាគាំទ្រឲ្យបានល្អប្រសើរ។

នៅប្រទេសកម្ពុជា សេគាំទ្រផ្សេងៗត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ អ្នកផ្តល់សេវាគាំទ្រមួយចំនួន ផ្តោតទិសដៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះ និងអន្តរាគមន៍វិបត្តិ ដើម្បីជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ស្ថាប័នទាំងនេះផ្តល់អាទិភាពទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងតំបន់ដែលមានគ្រោះថ្នាក់ខ្ពស់ និងសហការជាមួយអាជ្ញាធរក្នុងការជួយសង្គ្រោះពួកគេ ។

អ្នកផ្តល់សេវាគាំទ្រជនរងគ្រោះផ្សេងទៀត ផ្តល់អាទិភាពទៅលើការថែទាំក្រោយពេលជួយសង្គ្រោះ ហើយជាទូទៅ វាមានលក្ខណៈជាមណ្ឌល ដែលមានទីតាំងស្ថិតនៅក្នុងតំបន់គោលដៅសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ជាទូទៅសេវាគាំទ្រទាំងនេះ ត្រូវបានផ្តល់ជូនដោយអង្គការដែលផ្តល់សេវានៅតាមសហគមន៍ ដោយមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ឬក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ស្ថាប័នទាំងនេះបានផ្តល់សេវាគាំទ្រមួយចំនួនដូចជា ការថែទាំសុខភាព ការគាំទ្រផ្នែកចិត្តសង្គម ការអប់រំ ការបណ្តុះបណ្តាលបំណិនជីវិត និងជំនាញវិជ្ជាជីវៈ ជំនួយផ្នែកច្បាប់ ការធ្វើជាអ្នកតំណាង និងការពារក្តី។ ភាគច្រើន សេវាគាំទ្រក្រោយពេលជួយសង្គ្រោះ គឺផ្តល់ជូនដល់ស្ត្រី និងកុមារី ដែលជាជនរងគ្រោះដោយអំពើជួញដូរដម្បីធ្វើអាជីវកម្មផ្លូវភេទ ។

កម្មវិធីសមាហរណកម្ម និងសមាហរណកម្មឡើងវិញ គឺជាសេវាគាំទ្រដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងការធ្វើសមាហរកម្មពួកគេទៅរស់នៅក្នុងសហគមន៍ថ្មីមួយ ឬត្រឡប់ទៅរស់នៅក្នុងសហគមន៍កំណើតរបស់ពួកគេវិញ ក្រោយពេលដែលពួកគេធ្លាប់រងគ្រោះដោយអំពើជួញដូររួចមក។ សេវាគាំទ្រក្នុងការធ្វើសមាហរណកម្ម និងសមាហរណកម្មឡើងវិញ ដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម ត្រូវបានគេបង្កើតឡើងក្នុងកម្រិតតិចតួចនៅឡើយ។ ស្ថាប័នដែលផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងជនរងគ្រោះដោយអំពើជួញដូរ បានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍ថា ជនរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្មមិនចង់ស្នាក់នៅក្នុងមណ្ឌលទេ ហើយពួកគេចង់ត្រឡប់ទៅសហគមន៍វិញយ៉ាងឆាប់រហ័ស។ ជាលទ្ធផល ជនរងគ្រោះទាំងនោះត្រូវបានបញ្ជូនត្រឡប់ទៅសហគមន៍របស់ពួកគេយ៉ាងឆាប់រហ័ស ប៉ុន្តែពួកគេខ្វះខាតនូវការគាំទ្រមួយចំនួននៅសហគមន៍ ឬមិនបានទទួលសេវាគាំទ្រគ្រប់ជ្រុងជ្រោយដូចជនរងគ្រោះផ្សេងទៀតដែលបានស្នាក់នៅក្នុងមណ្ឌលនោះទេ។ ភាពខុសគ្នានេះបណ្តាលឲ្យមានការកើនឡើងនូវភាពងាយរងគ្រោះដោយសារអំពើជួញដូរជាថ្មីម្តងទៀត។

**កង្វះខាត និងបញ្ហាប្រឈមក្នុងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរឲ្យបានត្រឹមត្រូវច្បាស់លាស់ គឺនៅមានការខ្វះខាតនៅឡើយ
- សេវាគាំទ្រមួយចំនួនមិនមាននៅក្នុងសហគមន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះទេ
- សេវាគាំទ្រមួយចំនួនមិនអាចធានាឲ្យទទួលបានជោគជ័យ ក្នុងការធ្វើឲ្យមានលំនឹងនូវសុវត្ថិភាពផ្នែកសេដ្ឋកិច្ចដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឡើយ
- កម្មវិធីសមាហរណកម្ម និងសមាហរណកម្មឡើងវិញមានការខ្វះខាតនូវលើផ្នែកធនធាន
- ការកាត់ទោសមិនមានភាពត្រឹមត្រូវ
- គុណភាពនៃសេវាគាំទ្រមិនមានភាពដូចគ្នា
- សមត្ថភាពរបស់ស្ថាប័នជួនកាលនៅមានកម្រិតនៅឡើយ
- ការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដែលជាកុមារា និងបុរស មានចំនួនតិចតួចនៅឡើយ ទោះជាមានចំនួនជនរងគ្រោះដោយអំពើជួញដូរជាបុរស និងកុមារគួរអោយកត់សម្គាល់ ហើយការរងគ្រោះនេះទាក់ទងនឹងការជួញដូរពលកម្ម។
- សេវាគាំទ្រដែលផ្តល់ឲ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលមានពិការភាព និងជនរងគ្រោះដែលមានបញ្ហាសុខភាពផ្លូវចិត្ត ឬជនរងគ្រោះដោយសារអំពើរំលោភបំពាន គឺនៅមានចំនួនតិចតួចនៅឡើយ ។

## អនុសាសន៍

គោលបំណងនៃការអន្តរាគមន៍នានា ដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ច គឺដើម្បីជួយសង្គ្រោះជនរងគ្រោះឲ្យបានរួចផុតពីស្ថានភាពកេងប្រវ័ញ្ច និងបញ្ជូនពួកគេឲ្យត្រឡប់ទៅរស់នៅក្នុងសហគមន៍របស់ពួកគេវិញ ឬសហគមន៍ថ្មីមួយទៀតតាមការជ្រើសរើសរបស់ពួកគេដោយផ្អែកលើសុវត្ថិភាព។

ទោះបីជាយ៉ាងណាក៏ដោយ ការគ្រាន់តែបញ្ជូនជនរងគ្រោះត្រឡប់ទៅសហគមន៍ គឺមិនទាន់គ្រប់គ្រាន់នោះទេ។ កាតព្វកិច្ចដ៏ចំបង គឺកិច្ចការពារជនរងគ្រោះ និងផ្តល់ឲ្យពួកគេនូវជំនាញ និងធនធានចាំបាច់ដើម្បីទប់ស្កាត់នូវការជួញដូរជាថ្មីម្តងទៀត។

ជនរងគ្រោះគ្រប់រូបដែលធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្សមានតម្រូវការ ចំណុចខ្លាំង និងបញ្ហាប្រឈមផ្សេងៗគ្នា។ ការឆ្លើយតបដ៏ល្អបំផុត គឺការផ្តល់នូវការថែទាំជាបន្តបន្ទាប់ ដែលសំដៅទៅលើសេវាគាំទ្រក្នុងការអន្តរាគមន៍វិបត្តិ ដើម្បីកំណត់ពីអត្តសញ្ញាណជនរងគ្រោះ និងសង្គ្រោះជនរងគ្រោះ ការថែទាំក្រោយពេលជួយសង្គ្រោះដែលផ្តល់នូវសុវត្ថិភាព និងតម្រូវការជាមូលដ្ឋាន ការគាំទ្រផ្នែកស្មារតី និងការប្រឹក្សាយោបល់ ការគាំទ្រផ្នែកច្បាប់ ការគាំទ្រលើផ្នែកបំនិនជីវិត និងការបង្កើនសុវត្ថិភាពនៃប្រាក់ចំណូលសម្រាប់គ្រួសារ ដើម្បីបង្ការកុំឲ្យពួកគេក្លាយជាជនរងគ្រោះម្តងទៀត។ ជនរងគ្រោះម្នាក់ៗ មិនមែនសុទ្ធតែត្រូវការសេវាគាំទ្រទាំងអស់នោះទេ។ ជនរងគ្រោះខ្លះត្រូវការនូវសេវាគាំទ្រមួយចំនួន និងមានរយៈពេលកំណត់ខុសៗគ្នាទៅតាមស្ថានភាព

ជាក់ស្តែង។ ការទទួលនូវសេវាគាំទ្រទាំងនេះគួរតែត្រូវបានជ្រើសរើសដោយជនរងគ្រោះ ហើយគួរតែអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់ជនរងគ្រោះម្នាក់ៗ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ ។

ការបន្តផ្តល់សេវាគាំទ្រជាបន្តបន្ទាប់ គួរតែផ្តោតទៅលើការផ្តល់អន្តរាគមន៍វិបត្តិ ការថែទាំក្រោយពេលជួយសង្គ្រោះ និងការធ្វើសមាហរណកម្ម ឬសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍។ គោលបំណងនៃការទំនាក់ទំនងជាបឋមជាមួយជនរងគ្រោះដោយអំពើជួញដូរ គឺដើម្បីជួយដល់ពួកគេក្នុងការប៉ាន់ប្រមាណពីជំនាញ ចំណុចខ្លាំង និងតម្រូវការរបស់ពួកគេ ដើម្បីបង្កើតផែនការនីមួយៗដោយផ្អែកទៅតាមគោលបំណងផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ។ ការធ្វើផែនការនីមួយៗ គួរត្រូវបានធ្វើឡើងដោយជនរងគ្រោះ ឲ្យសមស្របទៅតាមអាយុរបស់ពួកគេ។

មានគោលការណ៍ទូទៅមួយចំនួនដែលគួរតែអនុវត្ត ដើម្បីបន្តនូវការកែលម្អលើការផ្តល់សេវាគាំទ្រនានាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា ដែលគោលការណ៍ទាំងនេះរួមមានដូចខាងក្រោម៖

- លើកកម្ពស់ឲ្យមានការចូលរួមពីជនរងគ្រោះដោយអំពើជួញដូរ នៅគ្រប់ដំណាក់កាលនៃការផ្តល់សេវាគាំទ្រ។ ឧទាហរណ៍ ការលើកកម្ពស់ឲ្យមានការចូលរួមក្នុងការធ្វើការប៉ាន់ប្រមាណ និងការបង្កើតផែនការករណីរបស់ជនរងគ្រោះនីមួយៗ និងការផ្តល់សេវាគាំទ្រផ្សេងៗ ដើម្បីការពារដល់សិទ្ធិមនុស្សជាមូលដ្ឋាន។ ផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះឲ្យចូលរួមក្នុងការឆ្លើយតបក្នុងការបង្កើត និងផ្តល់សេវាគាំទ្រផ្សេងៗ។
- ផ្តល់នូវការគោរពដល់ជនរងគ្រោះដោយអំពើជួញដូរ និងផ្តល់នូវព័ត៌មានគ្រប់បែបយ៉ាងដល់ពួកគេចាប់តាំងពីពេលទំនាក់ទំនងជាលើកដំបូង។ ផ្តល់ដល់ជនរងគ្រោះនូវតម្រូវការចាំបាច់ជាមូលដ្ឋាន មណ្ឌលសុវត្ថិភាព និងការគាំទ្រក្នុងការបញ្ជូនត្រឡប់ ឬស្នាក់នៅក្នុងសហគមន៍របស់ពួកគេ ឬសហគមន៍មួយផ្សេងទៀតឲ្យបានឆាប់រហ័សនៅពេលដែលមានសុវត្ថិភាព។
- ការប៉ាន់ប្រមាណ និងការប៉ាន់ប្រមាណឡើងវិញពីតម្រូវការ និងសុវត្ថិភាព គួរត្រូវបានធ្វើជាបន្តនៅគ្រប់ដំណាក់កាលនៃការអន្តរាគមន៍ ហើយយកលទ្ធផលនៃការប៉ាន់ប្រមាណនេះធ្វើជាមូលដ្ឋានដើម្បីបង្កើតផែនការករណី ។
- ត្រូវបន្តផ្តល់ដល់ជនរងគ្រោះនូវសេវាគាំទ្រនានា ដូចជាអន្តរាគមន៍វិបត្តិ ការថែទាំក្រោយពីសង្គ្រោះ រួមមានកន្លែងស្នាក់នៅ អាហា ការគាំទ្រចិត្តសាស្ត្រសង្គម ការបង្កើតប្រាក់ចំណូល និងរក្សាស្ថេរភាពប្រាក់ចំណូល ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួយផ្នែកច្បាប់ និងការធ្វើសមាហរណកម្ម ឬសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ដល់ជនរងគ្រោះដោយអំពើជួញដូរគ្រប់វ័យ និងគ្រប់ភេទព្រមទាំងផ្តល់ការគាំទ្រដល់ជនរងគ្រោះដែលមានពិការភាពផងដែរ។
ជនរងគ្រោះគួរត្រូវបានផ្តល់ជម្រើសផ្សេងៗ (នៅពេលចាំបាច់) ក្នុងបរិយាកាសមួយដែលមិនសូវមានភាពតឹងរឹងពេក និងមានបរិយាកាសដូចនៅក្នុងក្រុមគ្រួសារ។
- កែលម្អគុណភាពនៃការថែទាំនៅតាមមណ្ឌលបណ្តោះអាសន្នឲ្យមានភាពប្រសើរឡើង។

- ពង្រីកឲ្យបានទូលំទូលាយនូវសេវាគាំទ្រនៅតាមសហគមន៍ ដើម្បីឲ្យជនរងគ្រោះមានភាពងាយស្រួលក្នុងការទទួលបាននូវសេវាគាំទ្រទាំងនោះ។
- ធ្វើសមាហរណកម្ម ឬធ្វើសមាហរណកម្មឡើងវិញ ដល់ជនរងគ្រោះដោយអំពើជួញដូរទៅក្នុងសហគមន៍ឲ្យបានឆាប់រហ័ស នៅពេលដែលសហគមន៍នោះត្រូវបានប៉ាន់ប្រមាណថាមានសុវត្ថិភាព ឬនៅពេលណាដែលពួកគេជ្រើសរើសទៅរស់នៅក្នុងសហគមន៍វិញ។ ប្រសិនបើពួកគេរស់នៅក្នុងមណ្ឌល គេត្រូវធ្វើការប៉ាន់ប្រមាណឡើងវិញទៅតាមរយៈពេលកំណត់ណាមួយ ដើម្បីកំណត់ថាតើពួកគេនៅតែចាំបាច់ក្នុងការបន្តស្នាក់នៅក្នុងមណ្ឌល ឬយ៉ាងណា ។
- នៅពេលដែលអាចធ្វើទៅបាន ការអន្តរាគមន៍ទាំងឡាយគួរដោះស្រាយនូវមូលហេតុចំបងមួយក្នុងចំណោមមូលហេតុចំបងនានានៃអំពើជួញដូរ ដូចជាភាពក្រីក្រ និងការស្វែងរកប្រាក់ចំណូលសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ។ យន្តការពង្រឹងស្ថេរភាពប្រាក់ចំណូលគួរត្រូវបានពិចារណាដើម្បីគាំទ្រដល់ក្រុមគ្រួសាររបស់ជនរងគ្រោះ ខណៈពេលដែលពួកគេកំពុងទទួលនូវការបណ្តុះបណ្តាលជំនាញរយៈពេលវែង ។
- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ជនងរងគ្រោះដោយអំពើជួញដូរ នៅក្នុងសហគមន៍របស់ជនរងគ្រោះនៅពេលសមស្រប និងមានសុវត្ថិភាព ហើយប្រសិនបើជនរងគ្រោះស្នាក់នៅក្នុងមណ្ឌល ពួកគេគួរត្រូវបានបែងចែក ឲ្យដាច់ដោយឡែកពីសេវាគាំទ្របន្ទាន់។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ គួរត្រូវបានផ្តល់ដល់ជនរងគ្រោះ ដោយផ្អែកលើការប៉ាន់ប្រមាណពីតម្រូវការទីផ្សារ មានន័យថាត្រូវផ្តល់នូវការបណ្តុះបណ្តាលដល់ពួកគេឲ្យស្របតាមតម្រូវការទីផ្សារ ។
- ផ្តោតសំខាន់លើការកែលំអគុណភាពសេវាគាំទ្រនៅគ្រប់កម្រិត ។
- បង្កើនជំនាញឯកទេសដល់បុគ្គលិក ដែលត្រូវផ្តល់សេវាគាំទ្រដោយផ្ទាល់ ទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអន្តរាគមន៍វិបត្តិ ការគាំទ្រផ្នែកចិត្តសង្គម និងសកម្មភាពបង្កើតប្រាក់ចំណូល ។
- បង្កើនសមត្ថភាព ធនធាន និងភាពជាដៃគូជាមួយអាជ្ញាធររាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្ស រួមមានអន្តរាគមន៍វិបត្តិ ការថែទាំក្រោយពេលសង្គ្រោះ និងសមាហរណកម្មឡើងវិញ ។
- សេវាគាំទ្រទាំងអស់ដែលត្រូវផ្តល់ដល់ជនរងគ្រោះត្រូវស្រប ឬលើសពីអ្វីដែលមានចែងនៅក្នុង ***គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស បទដ្ឋានអប្បបរមាសម្រាប់ការថែទាំក្រោយពេលជួយសង្គ្រោះសម្រាប់កុមារ និងប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល។***
- ធ្វើការវាយតម្លៃពីគុណភាពនៃការផ្តល់សេវាគាំទ្រឲ្យបានទៀងទាត់ ដើម្បីកំណត់ថាតើសេវាគាំទ្រទាំងអស់នោះឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរ ឬទេ ។

## ១. សេចក្តីផ្តើម

### ប្រវត្តិគម្រោង

នៅក្នុងប្រទេសកម្ពុជា អង្គការវីនរ៉ក អន្តរជាតិ គឺកំពុងអនុវត្តកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ ដែលហៅកាត់ថា (CTIPII) ដែលទទួលបានជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ។ CTIPII គឺជាកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ជ្រុងជ្រោយមួយដែលមានរយៈពេល៤ឆ្នាំ (ខែតុលា ឆ្នាំ២០១១ ដល់ ខែកញ្ញា ឆ្នាំ២០១៥) ដែលត្រូវបានបង្កើតឡើងដើម្បីបង្កើនសមត្ថភាព និងត្រៀមខ្លួនរួចជាស្រេចសម្រាប់ស្ថាប័នកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព។ ការផ្តោតជាចំបងរបស់កម្មវិធី គឺគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព រួមបញ្ចូលទាំងការជួញដូរពលកម្ម។

ការអន្តរាគមន៍របស់ CTIP II គឺមានគោលដៅ និងឆ្លើយតបទៅនឹងកង្វះខាតជាក់លាក់នៅក្នុងគោលនយោបាយ ការបង្ការទប់ស្កាត់ ការកាត់ទោស និងការការពារ និងបង្កើនចំណេះដឹង និងជំនាញដល់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុក ដើម្បីនាំមកនូវការផ្លាស់ប្តូរដែលមាននិរន្តភាព និងយូរអង្វែង។ កម្មវិធី CTIP II នឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់មនុស្សចំនួន ៨.៥០០នាក់ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងរាជធានីចំនួន១ និងខេត្តចំនួន៦ នៅក្នុងប្រទេសកម្ពុជា ដូចជា រាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង ហើយត្រូវបានប៉ាន់ប្រមាណថាមានមនុស្សចំនួន ១២.០០០នាក់ បន្ថែមទៀតនឹងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពបង្ការទប់ស្កាត់ផ្សេងៗ។

បច្ចុប្បន្ននេះ មានការកើនឡើងនៃការផ្តល់ជូននូវការថែទាំនៅតាមសហគមន៍ របស់អង្គការមិនមែនរដ្ឋាភិបាល ដល់ជនរងគ្រោះដោយការកេងប្រវ័ញ្ច និងការបំពាន រួមមានជនរងគ្រោះដោយអំពើជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភ និងអំពើហិង្សាក្រោមរូបភាពផ្សេងៗ។ ចំពោះការថែទាំក្នុងរយៈពេលវែងសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ អង្គការមិនមែនរដ្ឋាភិបាលខ្លះបានប្រើប្រាស់វិធីសាស្ត្រដោយការផ្តល់ការថែទាំនៅក្នុងមណ្ឌល និងអង្គការខ្លះ ផ្តល់ការថែទាំនៅតាមសហគមន៍ ហើយអង្គការមិនមែនរដ្ឋាភិបាលខ្លះទៀតបានប្រើប្រាស់វិធីសាស្ត្រទាំងពីរ។ មណ្ឌលភាគច្រើនបានផ្តល់សេវាគាំទ្រចំបងតែចំពោះតែជនរងគ្រោះដែលជាកុមារ និងស្ត្រីប៉ុណ្ណោះ។ នេះជាបញ្ហាប្រឈមមួយសម្រាប់ជនរងគ្រោះជាបុរសដែលមិនមានលទ្ធភាពទទួលបានសេវាគាំទ្រពីមណ្ឌល ដែលបញ្ហានេះអាចធ្វើអោយជនរងគ្រោះជួបប្រទះនូវភាពរងគ្រោះម្តងទៀតក្នុងអំពើជួញដូរ និងការកេងប្រវ័ញ្ចពលកម្ម។

## តើអ្វីទៅជាអំពើជួញដូរមនុស្ស?

និយមន័យនៃពាក្យ ***អំពើជួញដូរមនុស្ស*** របស់អង្គការសហប្រជាជាតិត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការសិក្សានេះ។ នៅឆ្នាំ ២០០០ អង្គការសហប្រជាជាតិ បានកំណត់និយមន័យអំពើជួញដូរមនុស្សថាផ្អែកលើធាតុផ្សំសំខាន់ចំនួនបីគឺ **អំពើ មធ្យោបាយ** និង **គោលបំណង**។ វាត្រូវបានគេស្គាល់ថាជាពិធីសារ**ប៉ាឡឺម៉ូ** (Palermo Protocol)។ ពិធីសារនេះបានអោយនិយមន័យបន្ថែមនៃអំពើជួញដូរមនុស្សថាជា៖ **អំពើ**មួយដែលរួមបញ្ចូលសកម្មភាពជាច្រើនដូចជា “ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការបង្ខាំង ឬការទទួលនរណាម្នាក់”។ **មធ្យោបាយ**រួមមានការប្រើប្រាស់ “ការគំរាមកំហែង ឬការប្រើប្រាស់កំលាំងបាយ ការបង្ខិតបង្ខំ ការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការប្រើអំណាចរំលោភបំពាន ឬការបំពានលើអ្នកដែលទន់ខ្សោយ ឬផ្តល់ប្រាក់ ឬអត្ថប្រយោជន៍”។ **គោលបំណង**គឺជាផ្នែកមួយនៃការកេងប្រវ័ញ្ចដែលមានឥទ្ធិពលជាងគេដែលរួមមាន “ការប្រព្រឹត្តអំពើពេស្យាចារទៅលើអ្នកផ្សេង ការធ្វើអាជីវកម្មផ្លូវភេទ ពលកម្មបង្ខំ ទាសភាព ឬការប្រព្រឹត្តស្រដៀងនេះ ការដកហូតសរីរាង្គ ឬប្រភេទផ្សេងទៀតនៃការកេងប្រវ័ញ្ច”។[1]

## តើអ្វីទៅជាការថែទាំនៅក្នុងមណ្ឌល ហើយអ្វីទៅជាការថែទាំនៅសហគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរ?

***ការថែទាំនៅក្នុងមណ្ឌល*** គឺជាការថែទាំដែលមានការស្នាក់នៅជាក្រុមនៅក្នុងមណ្ឌល។ មិនមានមណ្ឌលណាដែលមានលក្ខណៈដូចគ្នាទេ ដូចជា ទីតាំង ទំហំ ការចំណាយ រយៈពេលនៃការស្នាក់នៅ ហើយចំនួនជាក់ស្តែងនៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមណ្ឌលបានផ្តល់សេវាគាំទ្រមានចំនួនខុសគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត និងពីមណ្ឌលមួយទៅមណ្ឌលមួយទៀត។[2] ប្រភេទនៃមណ្ឌលរួមមានមណ្ឌលសង្គ្រោះបន្ទាន់ មណ្ឌលសំចត មណ្ឌលផ្តល់ការស្នាក់នៅរយៈពេលខ្លី និងរយៈពេលវែង។ មណ្ឌលទាំងនេះផ្តល់សេវាគាំទ្រជាច្រើន រួមមាន ការការពារសុវត្ថិភាពពីជនប្រព្រឹត្តល្មើស ការថែទាំសុខភាព ការគាំទ្រចិត្តសង្គម ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ពត៌មានផ្នែកច្បាប់ ការធ្វើជាតំណាង និងការពារក្តី និងការធ្វើសមាហរណកម្ម ឬការធ្វើសមាហរណកម្មចូលទៅសហគមន៍វិញ។

***ការថែទាំនៅសហគមន៍*** ត្រូវបានកំណត់ថាជាការថែទាំដែលមិនមានការស្នាក់នៅក្នុងមណ្ឌល។ ការថែទាំនៅសហគមន៍ គឺជាការថែទាំដែលអាចរស់នៅជិតក្រុមគ្រួសារ។ ការថែទាំនៅសហគមន៍អាចជាការស្នាក់នៅក្នុងមណ្ឌលដែរ ប៉ុន្តែត្រូវមានការចូលរួមពីសហគមន៍ក្នុងការធ្វើឱ្យជាសះស្បើយ។[3] ការថែទាំនៅសហគមន៍គឺជាការថែទាំដែលមានរូបភាពផ្សេងៗគ្នា។ ឧទាហរណ៍ដូចជា ការរស់នៅក្នុងផ្ទះ ហើយទទួលបានសេវាគាំទ្រផ្សេងៗ ដូចជាការថែទាំពីសាច់ញ្ញាតិ ការថែទាំបីបាច់ពីគ្រួសារចញ្ចឹមបណ្តោះអាសន្ន ការថែទាំនៅក្នុងវត្ត និងការរស់នៅក្នុងផ្ទះដោយឯករាជ្យ។[4] សេវាគាំទ្រទាំងឡាយដែលបានទទួលនៅតាមសហគមន៍ អាចជាសេវា

---

[1](United Nations, 2000)
[2] (Chemonics, 2007)
[3](ILO, 2006)
[4](Tsugami, 2012)

គាំទ្រដែលដូចគ្នានឹងសេវាគាំទ្រដែលជនរងគ្រោះបានទទួលនៅក្នុងមណ្ឌល ដែលរួមមានការថែទាំសុខភាព ការគាំទ្រផ្នែកចិត្តសង្គម ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ពត៌មានផ្នែកច្បាប់ ការធ្វើជាតំណាង និងការពារក្តី និងការធ្វើសមាហរណកម្ម ឬការធ្វើសមាហរណកម្មចូលទៅសហគមន៍វិញ។

## គោលបំណងនៃការសិក្សា៖

គោលបំណងទូទៅនៃការសិក្សានេះ គឺដើម្បីធ្វើការប៉ាន់ប្រមាណ និងប្រៀបធៀបរវាងគម្រូនៃការថែទាំនៅក្នុងមណ្ឌល និងនៅសហគមន៍ ដើម្បីផ្តល់ព័ត៌មានអំពីការបង្កើតវិធីសាស្រ្តឯកទេសមួយក្នុងការថែទាំជនរងគ្រោះ។ ការប៉ាន់ប្រមាណនេះនឹងស្រាវជ្រាវមើលលើការអនុវត្តដ៏ល្អរបស់អ្នកផ្តល់សេវាគាំទ្រទាំងឡាយ និងឱកាសផ្សេងៗដើម្បីធ្វើឲ្យប្រសើរឡើងនូវគម្រូនៃការថែទាំនៅក្នុងមណ្ឌល និងនៅសហគមន៍ ដើម្បីផ្តល់ព័ត៌មានអំពីវិធីសាស្រ្តឯកទេសក្នុងការគាំទ្រជនរងគ្រោះដោយអំពើជួញដូរ រួមបញ្ចូលទាំងបុរសផងដែរ។ គោលបំណងនៃការប៉ាន់ប្រមាណមានដូចជា៖

១. ប៉ាន់ប្រមាណទៅលើតម្លៃ ការប្រើប្រាស់ និងភាពរកបាននៃសេវាគាំទ្រទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍ដែលជនរងគ្រោះដោយអំពើជួញដូរ កំពុងទទួលបានការថែទាំនាពេលបច្ចុប្បន្ន (ថាតើមណ្ឌល ឬសហគមន៍ផ្តល់សេវាគាំទ្រនីមួយៗអស់ថ្លៃប៉ុន្មាន មានសេវាគាំទ្រអ្វីខ្លះបើសិនជាមាន ថាតើជនរងគ្រោះត្រូវចំណាយប្រាក់ចំនួនប៉ុន្មានដើម្បីទទួលបានសេវាគាំទ្រទាំងនេះ។ ឧទាហរណ៍នៃសេវាគាំទ្រទាំងនេះរួមមាន៖

   ក. ការគាំទ្រផ្នែក ចិត្តសង្គម
   ខ. ការថែទាំសុខភាពផ្លូវកាយ
   គ. ការផ្តល់អាហាររូបត្ថម្ភ
   ឃ. បំណិនជីវិត និង វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ
   ង. សុវត្ថិភាពសេដ្ឋកិច្ច
   ច. ការអប់រំ
   ឆ. ឯកសារសំគាល់អត្តសញ្ញាណ
   ជ. ពត៌មានផ្នែកច្បាប់
   ឈ. និតិវិធីផ្លូវច្បាប់
   ញ.ផ្សេងៗ

២. កំណត់ និងប្រៀបធៀបពីចំនុចខ្លាំង ចំនុចខ្សោយ ឧបសគ្គ និងការទទួលបាននូវការថែទាំនៅមណ្ឌល និងនៅតាមសហគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ និងពលកម្មទៅលើកុមារា កុមារី ស្ត្រី និងបុរសជាដើម។

៣. ស្វែងយល់ពីទស្សនៈរបស់ជនរងគ្រោះចំពោះការថែទាំនៅមណ្ឌល និងនៅសហគមន៍ ការពេញចិត្តរបស់ជនរងគ្រោះចំពោះសេវាគាំទ្រ និង វិធីសាស្ត្រនានាដែលអាចបំពេញទៅតាមតម្រូវការរបស់ជនរងគ្រោះដែលត្រូវបានគេជួយសង្គ្រោះ។
៤. ផ្តល់អនុសាសន៍អំពីគម្រូឯកទេសនៃការថែទាំនៅក្នុងបរិបទប្រទេសកម្ពុជា ដោយផ្តោតសំខាន់ទៅលើជនរងគ្រោះដោយអំពើជួញដូរ ដែលជាកុមារា កុមារី ស្ត្រី និងបុរស ហើយប្រសិនបើសមស្របផ្តល់អនុសាសន៍ទៅលើបញ្ហាប្រឈមនានាដែលត្រូវដោះស្រាយដើម្បីធានាអោយបាននិរន្តភាព។

## ២. ការរៀបចំការសិក្សាស្រាវជ្រាវ

វិធីសាស្ត្របែបគុណភាពដែលត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណថាតើគម្រូសេវាគាំទ្រនីមួយៗ ឬការរួមបញ្ចូលសេវាគាំទ្រទាំងពីរ មានលក្ខណៈសមស្រប និងតាមពេលវេលានៅក្នុងបិរបទប្រទេសកម្ពុជា ឬទេ។ ធីសាស្ត្រនៃការប្រមូលទិន្នន័យរួមមានការពិនិត្យឡើងវិញលើទិន្នន័យដែលមានស្រាប់ និងរបាយការណ៍ផ្សេងៗ បទសម្ភាសន៍ជាមួយអ្នកផ្តល់ពត៌មានសំខាន់ៗ ដូចជាអាជ្ញាធររដ្ឋាភិបាល អង្គការដែលផ្តល់សេវាគាំទ្រនៅតាមសហគមន៏ (រួមមានថ្នាក់ដឹកនាំ និងបុគ្គលិកដែលផ្តល់សេវាគាំទ្រដោយផ្ទាល់) ដៃគូអភិវឌ្ឍន៍នានា និងជនរងគ្រោះដោយអំពើជួញដូរផ្សេងៗ។

### ២.១. សំនួរស្រាវជ្រាវសំខាន់ៗ

សំនួរស្រាវជ្រាវត្រូវបានកំណត់ក្នុងលក្ខខ័ណ្ឌយោងដូចខាងក្រោម៖

១. តើសេវាគាំទ្រនៅមណ្ឌល និងនៅសហគមន៍អ្វីខ្លះដែលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជួញដូរកំលាំងពលកម្មអាចរកបាន? ហើយចំនួនជនរងគ្រោះដោយអំពើជួញដូរមនុស្សប៉ុន្មានភាគរយដែលអាចទទួលបានសេវាកម្មដែលគេផ្តល់អោយ? តើអ្នកណាផ្សេងទៀតដែលអាចទទួលបានសេវាគាំទ្រទាំងនេះក្រៅពីជនរងគ្រោះដោយអំពើជួញដូរមនុស្ស?
២. តើមានចំនុចខ្លាំង និងចំនុចខ្សោយអ្វីខ្លះចំពោះប្រភេទនៃអ្នកផ្តល់សេវាគាំទ្រនីមួយៗ?
៣. តើអ្វីជាភាពខុសគ្នាជាចំបងរវាងវិធីដែលអ្នកផ្តល់សេវាគាំទ្រទាំងពីរប្រភេទក្នុងការបំពេញតម្រូវការរបស់ជនរងគ្រោះ?
៤. តើជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស មានគំនិតយោបល់អ្វីខ្លះ ចំពោះការថែទាំនៅក្នុងមណ្ឌល និងនៅសហគមន៍ ហើយតើវិធីសាស្ត្រទាំងនោះអាចឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះដែលត្រូវបានគេសង្គ្រោះអោយមានសុវត្ថិភាពដោយរបៀបណា?
៥. តើការពេញចិត្តរបស់ជនរងគ្រោះមានកំរិតណាចំពោះសេវាគាំទ្រដែលគេបានទទួល?

៦. ដោយផ្អែកលើរបបគំហើញនៃការស្រាវជ្រាវ តើមានអនុសាសន៍អ្វីខ្លះត្រូវបានប្រើប្រាស់ទៅថ្ងៃមុខ ដើម្បីគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសជនរងគ្រោះជាបុរស?

## ២.២. យុទ្ធសាស្ត្រនៃការជ្រើសរើសសំណាក (Sampling Strategy)

យុទ្ធសាស្ត្រនៃការជ្រើសរើសសំណាកដែលមានគោលបំណង គឺត្រូវបានប្រើប្រាស់ក្នុងការទាញយកព័ត៌មានដែលត្រូវការ។ អ្នកចូលរួមដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ គឺជាអ្នកសក្តិសមបំផុតក្នុងការឆ្លើយសំនួរស្រាវជ្រាវទាំងនោះ។ អ្នកចូលរួមត្រូវបានជ្រើសរើសដោយផ្អែកលើចំណេះដឹង ដែលត្រូវបានគេរំពឹងទុកថានឹងអាចឆ្លើយសំនួរស្រាវជ្រាវ។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ គឺត្រូវបានជ្រើសរើសមកពីស្ថាប័នដែលធ្វើការទាក់ទងនឹងផ្នែកច្បាប់ គោលនយោបាយ ឬអង្គការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរ និងជនរងគ្រោះដោយអំពើជួញដូរខ្លួនឯងផ្ទាល់។ អ្នកចូលរួមត្រូវបានកំណត់ជ្រើសរើសដោយផ្អែកលើសៀវភៅវាយឈ្មោះអង្គការ និងសេវាគាំទ្រ ហើយនិងតាមរយៈដំណើរការការពិនិត្យមើល និងកំណត់អត្តសញ្ញាណរបស់បុគ្គលសំខាន់ៗ ដែលមានបទពិសោធន៍ និងចំណេះដឹងជ្រៅជ្រះអំពីការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ អ្នកចូលរួមទាំងនេះរួម មាន៖

- ជនជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមមានកុមារា កុមារី ស្ត្រី និង បុរស ដែលកំពុងទទួលសេវាគាំទ្រនៅមណ្ឌល និងនៅសហគមន៍
- បុគ្គលិកដែលផ្តល់សេវាគាំទ្រនៅមណ្ឌល និងនៅសហគមន៍
- បុគ្គលិកសង្គមធ្វើការងារក្នុងស្ថាប័នរដ្ឋាភិបាល
- អាជ្ញាធរមូលដ្ឋាន
- អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ

មិនមានការកំណត់ចំនួនអ្នកផ្តល់បទសម្ភាសន៍មុនសម្រាប់ធ្វើបទសម្ភាសន៍ទេ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ វិធីសាស្ត្រនៃការជ្រើសរើសសំណាកដែលមានគោលបំណង នឹងផ្តល់លទ្ធផលល្អបំផុតនៅពេលមានអ្នកចូលរួមយ៉ាងហោចណាស់ចំនួនចាប់ពី២០ ទៅ ៣០នាក់ ត្រូវបានធ្វើបទសម្ភាសន៍។ ការសិក្សានេះបានសម្ភាសន៍អ្នកផ្តល់ព័ត៌មាន ចំនួន១៣០នាក់ ដែលចំនួននេះលើសពីចំនួនអប្បបរមាយ៉ាងច្រើន។

បន្ថែមពីលើកត្តាផ្សេងៗជាច្រើនទៀត ទីតាំងរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវក៏ត្រូវបានពិចារណាដែរ។ ចំពោះបណ្តាក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា គឺត្រូវបានគេផ្តោតជាសំខាន់នៅទីក្រុងភ្នំពេញ។ ហេតុដូច្នេះហើយបានជាអ្នកផ្តល់បទសម្ភាសន៏សំខាន់ៗមួយចំនួនធំ ត្រូវបានសម្ភាសន៍នៅទីក្រុងភ្នំពេញ។ ទោះជាយ៉ាងនេះក្តី យើងក៏បានធ្វើដំណើរទៅកាន់ខេត្តមួយចំនួនក្រៅពីទីក្រុងភ្នំពេញ។ ផ្អែកទៅ

លើចំនួនអ្នកផ្តល់សេវាគាំទ្រ និងចំនួនជនជនរងគ្រោះដោយអំពើជួញដូរ មានខេត្តចំនួន៣បន្ថែមទៀតត្រូវបានកំណត់ និងជ្រើសរើសសម្រាប់ការប្រមូលទិន្នន័យ។ ទីតាំងនៃការសិក្សាស្រាវជ្រាវនេះរួមមានៈ

- រាជធានីភ្នំពេញ
- ខេត្តសៀមរាប
- ខេត្តបន្ទាយមានជ័យ
- ខេត្តបាត់ដំបង

លើសពីខេត្តដែលបានគ្រោងទុកសម្រាប់ការសិក្សាស្រាវជ្រាវ ក្រុមសិក្សាស្រាវជ្រាវបានចុះទៅខេត្តកំពង់ធំ និងខេត្តស្វាយរៀង ដើម្បីធ្វើការសម្ភាសន៍ក្រុមគោលដៅដែលជាជនរងគ្រោះដោយអំពើជួញដូរ។ បញ្ជីរាយនាមអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗមាននៅក្នុងឧបសម្ព័ន្ធក។

## ២.៣. ការប្រមូលទិន្នន័យ (Data Collection)

វិធីសាស្ត្រនៃការប្រមូលទិន្នន័យរួមមានការពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ រួមមានអាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចពិភាក្សាក្រុមជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអ្នកផ្តល់សេវាគាំទ្រ។ សេចក្តីណែនាំអំពីការសម្ភាសន៍ត្រូវបានបង្កើតឡើងដើម្បីទទួលបានពត៌មានជាមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងសំនួរស្រាវជ្រាវតាមប្រភេទនីមួយៗ។

### ២.៣.១. ការពិនិត្យមើលលើឯកសារដែលមានស្រាប់

បច្ចុប្បន្ននេះ មានពត៌មានសំខាន់ៗជាច្រើនស្តីអំពីស្ថានភាព និងបទអន្តរាគមន៍ផ្សេងៗដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃការពិនិត្យមើលលើឯកសារដែលមានស្រាប់ គឺដើម្បីស្វែងយល់ពីច្បាប់ និងគោលនយោបាយនាពេលបច្ចុប្បន្ន ការអន្តរាគមន៍ពេលបច្ចុប្បន្ន កង្វះខាត ទំនោរទៅថ្ងៃអនាគត និងការអនុវត្តល្អៗ ឬវិធីសាស្ត្រផ្សេងៗ (ទាំងនៅក្នុងប្រទេសកម្ពុជា និងឬក្នុងតំបន់)។ ឯកសារពាក់ព័ន្ធដែលត្រូវបានពិនិត្យឡើងវិញ គឺមាននៅក្នុងឧបសម្ព័ន្ធក។ ប្រភពទិន្នន័យចំបងរួមមានឯកសារពាក់ព័ន្ធគោលនយោបាយ របាយការណ៍ប្រចាំឆ្នាំ ការវាយតម្លៃកម្មវិធី ការសិក្សាដែលពាក់ព័ន្ធផ្សេងៗ និងរបាយការណ៍អំពីការអនុវត្តល្អៗនៅក្នុងតំបន់។

### ២.៣.២. ការសម្ភាសន៍បែបស៊ីជម្រៅជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗៈ

កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ ត្រូវបានធ្វើឡើងជាមួយអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយដៃគូអភិវឌ្ឍន៍នានា និងអ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះទាំងឡាយ។

អ្នកតំណាងមកពីក្រសួងរាជរដ្ឋាភិបាលចំនួន៥នាក់ ត្រូវបានផ្តល់បទសម្ភាសន៍។ ក្រសួងទាំងនោះរួមមាន ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី។

ក្រៅពីនេះក៏មានមានអ្នកតំណាងមកមន្ទីរ និងការិយាល័យនៅតាមថ្នាក់ខេត្ត ស្រុក និងឃុំចំនួន៣៣នាក់ បានផ្តល់ បទសម្ភាសន៍។ មន្ទីរ និង ការិយាល័យទាំងនេះរួមមានមន្ទីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីកិច្ចការនារី ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យកិច្ចការនារី និង សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារខេត្ត ស្រុក និង មេឃុំ ព្រមទាំងគណៈកម្មការ ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ។

មានតំណាងអ្នកផ្តល់បទសម្ភាសន៍ចំនួន៧រូប មកពីអង្គការដៃគូអភិវឌ្ឍន៍ចំនួន៤ ដូចជា អង្គការយូនីសេហ្វ (UNICEF) កម្មវិធី អន្តរភ្នាក់ងារ សហប្រជាជាតិ (UNIAP) អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) និងអង្គការពលកម្មអន្តរជាតិ (ILO)។

មានតំណាងអ្នកផ្តល់បទសម្ភាសន៍ចំនួន៧២រូបមកពីអង្គការមិនមែនរដ្ឋាភិបាលចំនួន៤២ការិយាល័យ (អង្គការជាច្រើនមានគម្រោងផ្សេងៗនៅតាមខេត្តលើសពីមួយ) ដែលផ្តល់សេវាគាំទ្រដោយផ្ទាល់បានផ្តល់បទសម្ភាសន៍។

បញ្ជីរាយនាមអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗគឺមាននៅឧបសម្ព័ន្ធ ខ។ កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗត្រូវបានធ្វើឡើងដោយប្រើការសម្ភាសន៍ដែលមានលក្ខណៈបត់បែនដ៏ស៊ីជម្រៅ។ វិធីសាស្ត្រនៃការសម្ភាសន៍ដែលមានលក្ខណៈបត់បែន ត្រូវបានជ្រើសរើសដើម្បីអនុវត្តក្នុងការសិក្សាស្រាវជ្រាវនេះ ពីព្រោះវាមានលក្ខណៈបត់បែន ដែលអាចធ្វើឲ្យអ្នកសម្ភាសន៍បង្កើតសំនួរថ្មីៗសម្រាប់សួរដេញដោលបន្ថែម ដែលសំនួរទាំងនេះកើតចេញអ្វីដែលអ្នកផ្តល់បទសម្ភាសន៍បានឆ្លើយ។

សេចក្តីណែនាំសម្រាប់ការសម្ភាសន៍តាមផ្នែកនីមួយៗ ត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យជាក់លាក់អំពីប្រភេទសេវាគាំទ្រដែលបានផ្តល់ ការចំណាយលើសេវាគាំទ្រ កង្វះខាត និងបញ្ហាប្រឈមមុខ គុណភាព និងភាពដែលអាចទទួលយកនៃសេវាគាំទ្រដែលបានផ្តល់ដល់ជនរងគ្រោះ ចំនួនជនរងគ្រោះដែលត្រូវបានគេកំណត់អត្តសញ្ញាណ។ សេចក្តីណែនាំសម្រាប់ការសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗគឺមាននៅឧបសម្ព័ន្ធ គ។

### ២.៣.៣. ការពិភាក្សាក្រុម (Focus Group Discussions)៖

កិច្ចពិភាក្សាក្រុមត្រូវបានជ្រើសរើសជាគម្រូមួយក្នុងការសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរ និងអ្នកល់សេវាគាំទ្រដល់ជនរងគ្រោះ ព្រោះវាមានលក្ខណៈល្អបំផុតក្នុងការប្រើប្រាស់ជាមួយក្រុម ដែលមានភាពស្រដៀងគ្នាច្រើនជាងតែមួយ និងមានប្រធានបទដែលត្រូវបានកំណត់ជាក់លាក់មួយ។ វិធីសាស្ត្រនេះត្រូវបាន

រៀបចំឡើងសម្រាប់ការប្រមូលគំនិតយោបលរបស់សមាជិកក្រុម។ ដោយសារតែសំនួរតម្រូវអោយឆ្លើយជាក្រុមជាជាងបុគ្គល ការសន្ទនាមានលក្ខណៈបើកចំហ ពីព្រោះអ្នកចូលរួមចូលចិត្តប្រើប្រាស់យោបល់របស់គ្នាទៅវិញទៅមកក្នុងការឆ្លើយ។

**កិច្ចពិភាក្សាក្រុមជាមួយអ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ៖**

កិច្ចពិភាក្សាក្រុមមួយ ត្រូវបានធ្វើឡើងជាមួយក្រុមបុគ្គលិក ដែលជាអ្នកបម្រើការងារក្នុងការផ្តល់សេវាគាំទ្រផ្ទាល់ បន្ថែមពីលើការសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ ដែលជាអ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ។ ក្រុមបុគ្គលិកដែលជាអ្នកបម្រើការងារក្នុងការផ្តល់សេវាគាំទ្រទាំងអស់ ដែលបានសម្ភាសន៍គឺត្រូវបានអញ្ជើញឲ្យចូលរួមក្នុងការពិភាក្សា និងមានអង្គការចំនួន៨ចូលរួម។ ការសង្ខេបអំពីរបកគំហើញត្រូវបានចែករំលែកនៅក្នុងកិច្ចប្រជុំពិភាក្សា ហើយការពិភាក្សាក៍បានផ្តោតលើចំនុចខ្លាំង និងចំនុចខ្សោយនៃប្រភេទសេវាគាំទ្រ កង្វះខាត និងអនុសាសន៍សម្រាប់ទិសដៅពង្រឹងសេវាគាំទ្រជនរងគ្រោះនៅថ្ងៃអនាគត។ វិធីសាស្រ្តនេះក៏បានផ្តល់ឳកាសដល់ក្រុមបុគ្គលិក ដែលជាអ្នកបម្រើការងារក្នុងការផ្តល់សេវាកម្មដើម្បីពិភាក្សាជាមួយគ្នា។

**ការពិភាក្សាក្រុមជាមួយជនរងគ្រោះដោយការជួញដូរ៖**

កិច្ចពិភាក្សាក្រុមត្រូវបានធ្វើឡើងជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ កិច្ចពិភាក្សាក្រុមចំនួន ៩ ត្រូវបានធ្វើឡើងជាមួយជនរងគ្រោះដោយអំពើជួញដូរចំនួនសរុប៥៨នាក់។ ក្រុមស្រាវជ្រាវធ្វើការជាមួយអ្នកផ្តល់សេវាគាំទ្រជនរងគ្រោះដោយផ្ទាល់ដើម្បីកំណត់ជនរងគ្រោះអោយមានការចូលរួម ដែលរួមមានជនរងគ្រោះនៅតាមសហគមន៍ និងនៅមណ្ឌល ទាំងបុរស និងស្ត្រី និងជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីធ្វើអាជីវកម្មផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម។

## ២.៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ( Limitations of Study )

ការសិក្សានេះមានសារៈសំខាន់ក្នុងការកំណត់ព្រំដែននៃការសិក្សាស្រាវជ្រាវទៅតាមប្រភេទនៃទិន្នន័យ ដែលត្រូវបានប្រមូល។ ទិន្នន័យទាំងអស់មានលក្ខណៈជាការរាយការណ៍ដោយខ្លួនឯង និងមិនអាចផ្ទៀងផ្ទាត់ដោយឯករាជ្យបានទេ។ ការកត់ត្រាទុកនូវអ្វីដែលគេបាននិយាយពេលជួបផ្ទាល់ គឺជាការចាំបាច់ណាស់។ ប៉ុន្តែការកត់ត្រាមានឥទ្ធិពលក្នុងការកំហិតការសម្ភាសន៍លើមនុស្សមួយចំនួន សួរសំនួរដូចគ្នា ឬស្រដៀងទៅកាន់ក្រុមអ្នកផ្តល់ពត៌មានផ្សេងៗគ្នា ដើម្បីទទួលបានទិន្នន័យពីប្រភពផ្សេងៗគ្នា។ បន្ថែមពីលើការវិភាគទិន្នន័យ យើងស្វែងរកទំនោរ ឧទាហរណ៍ ការប្រើប្រាស់ប្រភពច្រើនជាងមួយសម្រាប់ជាឧបសគ្គ ឬយោបល់សម្រាប់គម្រូនៃសេវាគាំទ្រ។

## ២.៥. ការពិចារណាប្រកបដោយក្រមសីលធម៌ (Ethical Considerations)៖

កិច្ចពិភាក្សាក្រុម និងការសម្ភាសន៍ជាលក្ខណៈបុគ្គល ត្រូវបានធ្វើឡើងជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវនេះ។ ការប្រាស្រ័យទាក់ទងផ្ទាល់នេះតម្រូវឲ្យមានការពិនិត្យឡើងវិញនៃការពិចារណាប្រកបដោយក្រមសីលធម៌។ បណ្តាញការសិក្សាស្រាវជ្រាវអន្តរជាតិអំពីអំពើហិង្សាលើស្ត្រី និងអង្គការសុខភាពពិភពលោក បានបញ្ជាក់យ៉ាងច្បាស់ពីសារៈសំខាន់នៃការរក្សាការសម្ងាត់ និងសុវត្ថិភាព។ តម្រូវការក្នុងការធានាអោយបានថាការស្រាវជ្រាវមិនបង្កគ្រោះថ្នាក់ដល់អ្នកចូលរួម (រួមមានមិនបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្ត)។ សារៈសំខាន់នៃការធានាអោយបានថាអ្នកចូលរួមត្រូវបានជូនដំណឹងអំពីប្រភពក្នុងការស្វែងរកជំនួយនៅពេលមានបញ្ហា និងតម្រូវការសម្រាប់អ្នកសម្ភាសន៍ក្នុងការគោរពការសម្រេចចិត្ត និងជម្រើសរបស់អ្នកត្រូវបានសម្ភាសន៍។ ការបង្ការមានដូចខាងក្រោម៖

*មិនមានការពិភាក្សាអំពីបទពិសោធន៍របស់ជនរងគ្រោះដោយអំពើជួញដូរ៖* គោលបំណងនៃការស្រាវជ្រាវគឺដើម្បីស្វែងយល់ពីការទទួលបានសេវាគាំទ្រផ្សេងៗរបស់ជនរងគ្រោះ ដែលនេះមិនមែនជាបទពិសោធន៍អំពីមូលហេតុនៃអំពើជួញដូរនោះទេ។ រាល់សំនួរដែលបានសួរគឺទាក់ទងនឹងការទទួលបានសេវាគាំទ្រផ្សេងៗ ហេតុដូច្នេះ វាបានកាត់បន្ថយការបង្កអោយមានការប៉ះទង្គិចផ្លូវចិត្ត ដោយការពិភាក្សាអំពីបទពិសោធន៍នៃអំពើជួញដូរ។

*ការយល់ព្រមជាលក្ខណៈបុគ្គល៖* នៅពេលចាប់ផ្តើមសម្ភាសន៍ជាក្រុម និងបុគ្គលជាមួយជនរងគ្រោះដោយអំពើជួញដូរ អ្នកចូលរួមត្រូវបានជូនដំណឹងផ្ទាល់មាត់អំពីគោលបំណង និងលក្ខណៈនៃការសិក្សាស្រាវជ្រាវ។ ដោយសារតែកម្រិតការចេះអក្សរនៅប្រទេសកម្ពុជា មានកម្រិតទាប និងអារម្មណ៍ភាពភ័យខ្លាចរបស់ប្រជាជនដែលអាចមានចំពោះការកត់ឈ្មោះរបស់ពួកគេ អ្នកសម្ភាសន៍ត្រូវសុំការអនុញ្ញាតពីអ្នកចូលរួមដើម្បីធ្វើការសម្ភាសន៍។ ជាផ្នែកមួយនៃការសុំការអនុញ្ញាត អ្នកចូលរួមត្រូវបានជូនដំណឹងថាទិន្នន័យដែលប្រមូលបាន នឹងរក្សាជាការសម្ងាត់។ អ្នកចូលរួមត្រូវបានសួរថាតើពួកគេមានសំនួរដើម្បីសួរត្រឡប់មកវិញដែរឬទេ ហើយពួកគេអាចបដិសេធក្នុងការឆ្លើយសំនួរ ឬអាចចាកចេញពេលណាក៏បាន។

*ការរក្សាការសម្ងាត់៖*

*ជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖* អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុម ឬការសម្ភាសន៍អំពីការពេញចិត្តរបស់ជនរងគ្រោះមិនត្រូវបានសួរអំពីឈ្មោះពេញរបស់ពួកគេទេ។ អ្នកចូលរួមត្រូវបានគេប្រាប់ថាព័ត៌មានអំពីអត្តសញ្ញាណជាក់លាក់ណាមួយរបស់ពួកគេនឹងមិនត្រូវបានចែករំលែកឡើយ។

*អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗផ្សេងៗទៀត៖* ឈ្មោះត្រូវបានប្រមូលពីអ្នកផ្តល់បទសម្ភាសន៍ ប៉ុន្តែទិន្នន័យទាំងអស់ត្រូវបានបញ្ចូលគ្នា និងមិនមានការផ្តល់យោបល់ពាក់ព័ន្ធ

ជាក់លាក់ចំពោះឈ្មោះណាមួយឡើយ។ ល័ក្ខណ្ឌទាំងនេះ ត្រូវបានបកស្រាយនៅក្នុងដំណើរការនៃការសម្ភាសន៍។

## ២.៦. ការពិនិត្យមើលលើឯកសារដែលមានស្រាប់ (Literature Review)៖

របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក រាយការណ៍ថាប្រទេសកម្ពុជា គឺជាប្រភពជាកន្លែងសំចត និងជាប្រទេសគោលដៅសម្រាប់ស្រ្តី បុរស និងកុមារទាំងឡាយដែលជាអ្នករងគ្រោះដោយការបង្ខំអោយធ្វើការ និងដោយការជួញដូរផ្លូវភេទ។ របាយការណ៍នេះបាននិយាយថា ស្រ្តី បុរស និងកុមារកម្ពុជាជាច្រើនធ្វើចំណាកស្រុកទៅប្រទេសមួយចំនួននៅក្នុងតំបន់ ជាពិសេសទៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ដើម្បីធ្វើការ ហើយមួយចំនួនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ជាខ្ញុំបម្រើតាមផ្ទះ ជាខ្ញុំបម្រើដោយការជំពាក់បំណុល ឬបង្ខំអោយធ្វើការនៅតាមកន្លែងនេសាទ សំណង់ និងកសិកម្ម។[5]

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ និងគោលនយោបាយផ្សេងៗ និងបានកំណត់ឃើញនូវការអនុវត្តប្រកបដោយប្រសិទ្ធិភាព។ ច្បាប់ និងគោលនយោបាយទាំងនេះ រួមមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស បទដ្ឋានអប្បបរមាសម្រាប់ជម្រើសនៃការថែទាំចំពោះកុមារ និងប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល និងគោលនយោបាយភូមិ-ឃុំ/សង្កាត់មានសុវត្ថិភាព ផែនការសកម្មភាពថ្នាក់ជាតិ (២០១១-២០១៣)។ លើសពីនេះទៀត មានគោលនយោបាយផ្សេងៗត្រូវបានកំពុងបង្កើតឡើង ដូចជាគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

អំពើជួញដូរមនុស្សមានឥទ្ធិពលដល់ស្រ្តី បុរស កុមារា និង កុមារី។ ទោះជាបែបនេះក៏ដោយ នៅប្រទេសកម្ពុជាសេវាគាំទ្រភាគច្រើនបានផ្តោតសំខាន់លើស្រ្តី និងកុមារីតែប៉ុណ្ណោះ។ ស្ថានភាពសម្រាប់កុមារាគឺមានការយកចិត្តទុកដាក់តិចតួចនៅឡើយ។ តាមការសិក្សារបស់ **ហ៊ីលតុន** (Hilton) លើប្រធានបទដែលមានចំណងជើងថា ***ខ្ញុំមិនដែលបានគិតថាវាអាចកើតឡើងចំពោះកុមារាទេ*** គាត់បានរាយការណ៍ថាស្ថិតិដែលបានបង្ហាញឲ្យដឹងអំពីការរំលោភបំពានផ្លូវភេទ និងការធ្វើអាជីវកម្មលើកុមារ គឺមានតិចតួចណាស់។ គាត់និយាយថា ការជឿជាក់យ៉ាងប្រាកដក្នុងចំណោមការសម្ភាសន៍ជាមួយមនុស្សពេញវ័យ នៅក្នុងការសិក្សានេះ គឺថាមានជនបរទេស និង/ឬ មនុស្សប្រុសខ្ទើយគឺជាអ្នកទទួលខុសត្រូវដោយមិនអាចអត់ឱនបានចំពោះទង្វើនៃការរំលោភបំពានលើកុមារាទាំងនោះ ហើយវាមានការជាប់ពាក់ព័ន្ធនឹងបញ្ហាដែលកំពុងកើតមានថ្មីៗ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សារបស់គាត់មិនបានគាំទ្រលើទស្សនៈនោះទេ ហើយបានបង្ហាញឲ្យឃើញថាចំនួនដ៏ច្រើននៃកុមារាទាំងនោះ ត្រូវបានរំលោភបំពានផ្លូវភេទដោយជនជាតិកម្ពុជា និងជនបរទេសពេញវ័យ

[5](US Department of State, 2012)

ក្រោមរូបភាពផ្សេងៗគ្នា។ កុមារាក៏ត្រូវបានរំលោភបំពានដោយកុមារដទៃផ្សេងទៀតផងដែរ ហើយករណីខ្លះត្រូវបានរំលោភបំពានដោយស្ត្រីផងដែរ។[6]

អ្នកជំនាញការផ្សេងៗបានរកឃើញថា ប្រភេទនៃជនរងគ្រោះដោយអំពើជួញដូរ ដែលចំនួនដ៏ច្រើនត្រូវការកិច្ចការពារសុវត្ថិភាព និងការស្នាក់នៅរយៈពេលវែង និងសេវាគាំទ្រជាច្រើនមាន សាច់ប្រាក់ដោយផ្ទាល់ ការធ្វើដំណើរ ការប្រឹក្សាព្យាបាលផ្លូវចិត្ត ក្រុមគាំទ្រ ការប្រមូលឯកសារ វគ្គបណ្តុះបណ្តាល ជំនាញបំណិនជីវិត ការថែទាំដោយវេជ្ជសាស្ត្រ (រួមមាន ការថែទាំធ្មេញ និងភ្នែក) សំលៀកបំពាក់ សេវាកម្មទូរស័ព្ទ កម្មវិធីអប់រំក្នុងប្រព័ន្ធ និងកម្មវិធីស្មគ្រ័ចិត្តសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។[7]

នៅប្រទេសកម្ពុជា ការឆ្លើយតបដំបូងក្នុងការផ្តល់ការគាំទ្រទាំងនេះត្រូវបានធ្វើឡើងតាមរយៈកម្មវិធីរបស់មណ្ឌលស្នាក់នៅ ដែលផ្តោតជាសំខាន់លើជនរងគ្រោះដោយអំពើជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ ដែលជាស្ត្រី និងកុមារី។ មានការសិក្សាមួយដែលបានគាំទ្រដោយ USAID បានរកឃើញប្រភេទផ្សេងៗគ្នានៃការបង្កើតមណ្ឌល ដើម្បីឆ្លើយតបនឹងតម្រូវការទៅតាមប្រភេទ និងកាលៈទេសៈរបស់ជនរងគ្រោះដោយអំពើជួញដូរ។ មណ្ឌលទាំងនេះរួមមាន មណ្ឌលសង្គ្រោះបន្ទាន់ មណ្ឌលសំចត មណ្ឌលស្នាក់នៅរយៈពេលខ្លី មណ្ឌលស្នាក់នៅរយៈពេលវែង ផ្ទះសំចត និងមណ្ឌលសមាហរណកម្ម។[8] នៅកម្ពុជាមណ្ឌលដែលបានបង្ហាញខាងលើគឺមានរួចហើយ។

ប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកផ្តល់សេវាគាំទ្រមួយចំជនរងគ្រោះមួយចំនួនត្រូវបានគេធ្វើការវាយតម្លៃ ថាតើសេវាគាំទ្រទាំងនោះ គឺពិតជាជម្រើសដ៏ប្រសើរបំផុតសម្រាប់ការថែទាំក្រោយពេលសង្គ្រោះដល់ជនរងគ្រោះដោយអំពើជួញដូរដែរ ឬទេ។ ដោយយោងទៅតាមចំនួនដ៏ច្រើននៃអ្នកសិក្សាស្រាវជ្រាវ ការផ្តល់ការថែទាំនៅតាមមណ្ឌល ឬស្ថាប័ន គួរតែជាជម្រើសចុងក្រោយសម្រាប់ជម្រើសនៃការថែទាំជាពិសេសចំពោះកុមារ។ កាលពីដើមឆ្នាំ១៩៥៣ **ចន បូលប៊ី** (John Bowlby) បានរកឃើញផលវិបាកអវិជ្ជមាននៃស្ថាប័ន ដែលផ្តល់ការថែទាំសម្រាប់កុមារ។[9]

ការសិក្សាស្រាវជ្រាវស្នើឡើងថា មណ្ឌល ឬស្ថាប័ន ដែលផ្តល់ការស្នាក់នៅសម្រាប់កុមារមិនបានផ្តល់លក្ខខ័ណ្ឌបានគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយភាពវិជ្ជមាននោះទេ។ សិទ្ធិកុមារ និងមនុស្សពេញវ័យ គឺតែងតែត្រូវបានគេបំពាននៅក្នុងមណ្ឌលដែលផ្តល់ការថែទាំ។ ទោះបីជាការផ្តល់ការថែទាំនៅតាមមណ្ឌលមានភាពចាំបាច់ក្នុងការផ្តល់នូវកិច្ចការពារដល់ជនរងគ្រោះក៏ដោយ វាក៏ធ្វើឲ្យពួកគេឃ្លាតឆ្ងាយពីសហគមន៍ មានការរើសអើង ការឈឺចាប់ និងការបាត់បង់ទំនាក់ទំនងពីក្រុមគ្រួសារ។

[6](Hilton, 2008)
[7](Maney, 2011)
[8](Chemonics, 2007)
[9](Sam McLeod, 2007)

យោងទៅតាម **ហ្វាប្បូឡា** (Fabiola) មណ្ឌលថែទាំនៅកម្ពុជាភាគច្រើនមានទីតាំងនៅឆ្ងាយពីសហគមន៍។ គាត់បានរៀបរាប់ថា ពេលខ្លះអ្នកផ្តល់សេវាគាំទ្រក្នុងមណ្ឌលទាំងនោះយល់ឃើញថា ***ការសង្គ្រោះកុមារ*** គឺគ្រាន់តែជាការយកពួកចេញពីស្ថានភាព ដែលពួកគេទទួលរងនូវការរំលោភបំពាន ហើយឲ្យពួកគេស្នាក់នៅក្នុងមណ្ឌលសុវត្ថភាពតែប៉ុណ្ណោះ។ ក្រៅពីការជួយឲ្យពួកគេបានចូលរៀននៅថ្នាក់បឋមសិក្សា ពុំមានកម្មវិធីអ្វីផ្សេងទៀតសម្រាប់ផ្តល់ដល់ពួកគេឡើយ។[10]

នៅក្នុងមេសាឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសង្គមកិច្ច និងយុវនីតិសម្បទាបានបោះផ្សាយគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងបានរកឃើញថា "ការថែទាំតាមគ្រួសារ និងនៅសហគមន៍ គឺជាជម្រើសនៃការថែទាំដ៏ប្រសើរបំផុត ហើយដែលការថែទាំនៅក្នុងមណ្ឌលគួរតែជាកន្លែងពឹងអាស្រ័យចុងក្រោយ និងដំណោះស្រាយបណ្តោះអាសន្នសម្រាប់កុមារ"។[11]

យោងទៅតាម **តូហ្វ្រី** (Toffree) ដែលនៅក្នុងរបាយការណ៍របស់គាត់ ***ការថែទាំនៅសហគមន៍សម្រាប់កុមារដែលបែកបាក់ពីក្រុមគ្រួសារ*** បាននិយាយថានេះជាកម្មវិធីទប់ស្កាត់ដ៏ប្រសើរបំផុតដើម្បីជួយឲ្យកុមារទទួលបាននូវការថែទាំនៅក្រោមណ្ឌល។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺក្រោមរូបភាពជាការគាំទ្រផ្នែកសម្ភារៈ ដែលផ្តល់ដល់ក្រុមគ្រួសារ ជាមួយនឹងការផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ មណ្ឌលថែទាំពេលថ្ងៃ ក្លឹបកុមារ ក្រុមគាំទ្រផ្សេងៗទៀត កម្មវិធីអប់រំទប់ស្កាត់ និងធនធានផ្សេងៗដែលផ្តោតលើម្តាយ សកម្មភាពទាក់ទាញការគាំទ្រមតិ និងការគាំទ្រផ្នែកច្បាប់។[12]

អ្នកសិក្សាស្រាវជ្រាវផ្សេងៗគ្នាបានសម្លឹងមើលវិធីសាស្ត្រក្នុងការផ្តល់សេវាគាំទ្រ ដើម្បីថែទាំជនរងគ្រោះដោយអំពើជួញដូរជាលក្ខណៈអន្តរជាតិ និងជាពិសេសនៅកម្ពុជា។ ដោយផ្អែកលើការសិក្សាថ្មីៗរបស់**ដេវីន** (Devine) ***សេវាគាំទ្រសុខភាពផ្លូវចិត្ត និងសតិបញ្ញាសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ*** ដែលឧបត្ថម្ភដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅកម្ពុជា វិធីសាស្ត្រប៉ាន់ប្រមាណត្រូវបានផ្តល់អត្ថន័យយ៉ាងច្បាស់ ទោះបីជាកម្រិតសមត្ថភាព និងគុណភាពរបស់ទីភ្នាក់ងារទាំងឡាយធ្វើការជួយលើបុគ្គលដែលត្រូវបានគេជួញដូរនៅកម្ពុជាមានលក្ខណៈផ្សេងគ្នាក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ មានស្ថាប័នដែលមានសមត្ថភាពខ្ពស់មួយចំនួនកំពុងតែបំពេញ ការងារយ៉ាងល្អសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ"។ ពួកគេក៏បានរាយការណ៍ដោយមានការកត់សម្គាល់ពីការរីកចម្រើននៃបណ្តាញ ដែលបានជួយក្នុងការសម្របសម្រួលការផ្ទេរចំណេះដឹង វគ្គបណ្តុះបណ្តាល និងជំនាញផ្សេងៗក្នុងចំណោមទីភ្នាក់ងារមួយចំនួន។[13]

---

[10](Tsugami, 2012)
[11](MoSVY, 2006)
[12](Tolfree, 2003)
[13](Devine, 2009)

ការធ្វើសមាហរណកម្ម គឺជាសេវាកម្មមួយផ្សេងទៀតដែលគេបានពិនិត្យឃើញ។ យោងទៅតាមរបាយការណ៍របស់ ILO ស្តីពី ***គោលការណ៍ណែនាំនៃកុមារមេត្រីសម្រាប់ការស្តារ និងសមាហរណកម្មកុមារដែលត្រូវបានគេជួញដូរ*** បានបង្ហាញថាការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ គឺតែងតែមានការពិបាកស្មុគស្មាញ ហើយដំណើរការដោយប្រើរយៈពេលយូរ។ ភាពស្មុគស្មាញកើតឡើងដោយសារវាមានភាពខុសគ្នារវាងជនរងគ្រោះនីមួយៗ ហើយវាពាក់ពន្ធ័មិនត្រឹមតែជនរងគ្រោះនោះទេ គឺថែមទាំងមានការពាក់ពន្ធ័ជាមួយនឹងបរិស្ថានជុំវិញ និងវប្បធម៌នៅទីកន្លែងដែលជនរងគ្រោះត្រូវបានធ្វើសមាហរណកម្ម។ កត្តាសំខាន់មួយចំនួនក្នុងការស្តារនីតិសម្បទា ការស្តារឡើងវិញ និងការធ្វើសមាហរណកម្ម រួមមានអាយុរបស់ជនរងគ្រោះនីមួយៗ សុខភាពផ្លូវកាយ និងផ្លូវចិត្ត សាវតា ជីវិតគ្រួសារ វប្បធម៌ រយៈពេលនៃកេងប្រវ័ញ្ចចំពោះជនរងគ្រោះ និងទស្សនៈរបស់ជនរងគ្រោះអំពីការបំផ្លាញភាពជាបុគ្គល និងអនាគតរបស់ពួកគេដែលពួកគេត្រូវបានគេជួញដូរ ជាពិសេសនៅពេលដែលពួកគេជាជនរងគ្រោះដោយការជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ។

ជនរងគ្រោះកាន់តែងាយទទួលភាពរងគ្រោះមុនពេលត្រូវបានគេជួញដូរ និងក្រោយពេលដែលពួកគេត្រូវបានរំលោភបំពាន និងកេងប្រវ័ញ្ច។ ដូចនេះការជួញដូរជនរងគ្រោះសារជាថ្មីគឺជាគ្រោះថ្នាក់យ៉ាងពិតប្រាកដ។ ការស្តារនីតិសម្បទា និងការស្តារឡើងវិញ និងការធ្វើសមាហរកម្មដែលមានរយៈពេលវែងដល់ជនរងគ្រោះដោយអំពើជួញដូរតម្រូវអោយមានឱកាសអប់រំដ៏សំខាន់ និងឱកាសសេដ្ឋកិច្ចក៏ដូចជាការថែទាំផ្នែកចិត្តសង្គមផងដែរ។ កង្វល់មួយចំពោះមណ្ឌលទាំងអស់ដែលបានផ្តល់សេវាកម្មដល់ក្រុមគោលដៅជាជនរងគ្រោះដោយអំពើជួញដូរទាំងអស់គឺសេចក្តីត្រូវការដើម្បីស្វែងរកមធ្យោបាយក្នុងការសម្រេចបាននិរន្តភាពយូរអង្វែង។[14]

យោងទៅតាមរបាយការណ៍របស់ **ប្រោន** (Brown) "***ចំណងដែលចងវិត ទេសន្តរប្រវេសន៍ និងអំពើជួញដូរស្ត្រី និងកុមារីដើម្បីធ្វើអាជីវកម្មផ្លូវភេទនៅកម្ពុជា***" នៅក្នុងលក្ខខ័ណ្ឌនៃការធ្វើសមាហរណកម្ម វាមានភាពច្បាស់លាស់ដែលថាអតីតជនរងគ្រោះ និងជនរងគ្រោះបច្ចុប្បន្នជាច្រើនមិនទទួលបានសេវាគាំទ្រក្នុងការធ្វើសមាហរណកម្មទេ។[15]

នៅក្នុងរបាយការណ៍ថ្មីៗរបស់អង្គការហាការ (Hagar) និងអង្គការទស្សនៈពិភពលោក ដែលមានចំណងជើង ***ផ្លូវទៅគេហដ្ឋាន*** (*The Road Home*) បានបញ្ជាក់ថាបន្ថែមលើបញ្ហាប្រឈមដែលបានរកឃើញ និងការ កត់សម្គាល់បន្ថែមទាក់ទងនឹងការធ្វើសមាហរណកម្ម គឺមានកត្តាជាច្រើនផ្សេងទៀតទាក់ទងនឹងផ្នែកសេដ្ឋកិច្ច និងសង្គម ក្រៅពីឥទ្ធិពលរបស់បុគ្គល និងអង្គភាព រួមផ្សំជាមួយនិងកត្តាផ្ទាល់ខ្លួនដូចជា សមត្ថភាពជម្រើស និងការទទួលខុសត្រូវ ហើយកត្តាទាំងអស់នេះធ្វើឲ្យមានភាពស្មុគស្មាញក្នុងដំណើការនៃការធ្វើសមាហរណកម្ម។ មានតែការឆ្លើយតបដ៏ត្រឹមត្រូវចំពោះករណីនីមួយៗភ្លាមៗទេ ទើបអាចទទួលបានភាព

[14](ILO, 2006)
[15](Brown, 2007)

ជោគជ័យ។ កម្មវិធីឆ្លើយតបណាមួយដែលមិនបានយកកត្តាទាំងអស់នេះមកពិចារណានោះ គឺមិនធ្វើឲ្យបានជោគជ័យនោះទេ។

ពេលខ្លះកុមារត្រូវបានបញ្ជូនទៅកាន់សហគមន៍កំណើតរបស់ពួកគេ ដោយមិនបានធ្វើអ្វីក្នុងការកែលម្អស្ថានភាពផ្សេងៗ ដែលជំរុញឲ្យពួកគេទទួលរងនូវការកេងប្រវ័ញ្ច។ ការមិនទទួលខុសត្រូវទាំងផ្នែកសីលធម៌ និងការអនុវត្តន៍ជាក់ស្តែងធ្វើឲ្យមានភាពបរាជ័យក្នុងការដោះស្រាយនូវស្ថានភាពនានាមុននឹងបញ្ជូនត្រឡប់ទៅវិញ។[16]

ការសិក្សានេះមានគោលបំណងដើម្បីពិនិត្យមើលប្រព័ន្ធសេវាគាំទ្រដល់ជនរងគ្រោះនាពេលបច្ចុប្បន្ន និងផ្តល់ជាអនុសាសន៍ដើម្បីជំរុញការផ្តល់សេវាគាំទ្រក្នុងទិសដៅវិជ្ជមាន ដែលសាកសមជាមួយនឹងការអនុវត្តល្អៗជាលក្ខណៈអន្តរជាតិសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរ។

# ៣. របកគំហើញសំខាន់ៗ ( KEY FINDINGS )

## ៣.១. តម្រូវការមូលដ្ឋានរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

អ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ ត្រូវបានតម្រូវអោយពណ៌នាពីតម្រូវការមូលដ្ឋានរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សបន្ទាប់ពីចាកផុតពីស្ថានភាពជួញដូរ។ តម្រូវការដែលបានរកឃើញត្រូវបានសង្ខេបហើយដាក់ជាក្រុម។ អ្នកផ្តល់បទសម្ភាសន៍សំខាន់ៗផ្សេងៗបានរកឃើញថាតំម្រូវការរបស់ជនរងគ្រោះទាំងអស់មិនដូចគ្នាទេ ហើយជនរងគ្រោះខ្លះត្រូវការសេវាគាំទ្រមួយចំនួនដែលដែលអ្នកផ្សេងមិនត្រូវការ។ បន្ថែមលើនេះទៀតអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗជាច្រើននាក់ បានលើកឡើងថាជនរងគ្រោះគួរតែមានសិទ្ធក្នុងការបដិសេធន៍មិនទទួលយកសេវាគាំទ្រដែលពួកគេមិនចង់បាន។

[16](Hagar and World Vision, 2007)

| អន្តរាគមន៍វិបត្តិ | ការថែទាំក្រោយសង្គ្រោះនិងការស្តារនីតិសម្បទា | សមាហរណកម្ម ការធ្វើសមាហរណកម្មឡើងវិញ |
|---|---|---|
| • ការកំណត់អត្តសញ្ញាណជនរងគ្រោះទាំងខាងក្នុងប្រទេស និងឆ្លងព្រំដែន<br>• ការធ្វើមាតុភូមិនិវត្ត (ពេលសមស្រប)<br>• សុវត្ថិភាព និងការការពារបន្ទាន់<br>• ការទទួលយក<br>• ការស្នាក់នៅដែលមានសុវត្ថិភាព (មណ្ឌល ចិញ្ចឹមបីបាច់ដោយគ្រួសារចិញ្ចឹម សហគមន៍)<br>• តម្រូវការមូលដ្ឋាន ដូចជាអាហារ សំលៀកបំពាក់<br>• ការថែទាំសុខភាពពេលសង្គ្រោះបន្ទាន់ និងឬសង្គ្រោះបឋម<br>• ព័ត៌មានអំពីច្បាប់<br>• ចំណេះដឹងអំពីសិទ្ធិ ច្បាប់ និងឱកាសផ្សេងៗ | • ការគ្រប់គ្រងករណី<br>• ការប៉ាន់ប្រម៉ាណ (បុគ្គល គ្រួសារ និងសហគមន៍) និងការរៀបចំផែនការករណីបុគ្គល ជាមួយគោលដៅនៃការធ្វើសមាហរណកម្ម<br>• ការរៀបចំផែនការសុវត្ថិភាព<br>• ការគាំទ្រ និងឬការព្យាបាលផ្នែកចិត្តសង្គម<br>• ការតំណាងផ្លូវច្បាប់<br>• បំណិនជីវិត<br>• អក្ខរភាព និងការអប់រំមូលដ្ឋាន<br>• វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ការបង្កើតប្រាក់ចំណូល | • ការវិលត្រឡប់ទៅសហគមន៍កំណើត ឬសហគមន៍មួយផ្សេងទៀតដោយសារសុវត្ថិភាព និងតំរូវការរបស់បុគ្គល<br>• ស្ថេរភាពគ្រួសារ<br>• ការបង្កើតប្រាក់ចំណូល (ដើមទុនក្នុងការទ្រទ្រង់មុខរបរ)<br>• ការតាមដានបន្ទាប់ពីការធ្វើសមាហរណកម្មឡើងវិញ<br>• ភ្ជាប់ជាមួយធនធានក្នុងស្រុក |

## ភាពខុសគ្នា ឬភាពខ្វះចន្លោះដោយផ្អែកលើភេទនិងអាយុ

អ្នកផ្តល់បទសម្ភាសន៍សំខាន់ៗទាំងអស់ ក៏ត្រូវបានអោយពណ៌នាអំពីតម្រូវការខុសៗគ្នារបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយផ្អែកលើភេទ ឬអាយុ។ ខាងក្រោមនេះគឺជាការសង្ខេបអំពីភាពខុសៗគ្នាដែលកំណត់ដោយអ្នកផ្តល់បទសម្ភាសន៍៖

- ជនរងគ្រោះដោយអំពើជួញដូរដែលជាស្ត្រីពេលខ្លះមានការអប់រំតិច និងចាំបាច់ត្រូវរៀនអំពីជំនាញនៃការបង្កើតប្រាក់ចំណូល និងរៀនអក្សរដើម្បីប្រើប្រាស់ក្នុងការប្រកបមុខរបរ។
- ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលជាកុមារត្រូវការការអប់រំមូលដ្ឋាន ជំនាញកុំព្យូទ័រ ភាសាអង់គ្លេស និងបន្តការសិក្សានៅថ្នាក់មហាវិទ្យាល័យប្រសិនធ្វើទៅបាន។
- យុវជនដែលមានអាយុពី១៥ ទៅ ១៨ឆ្នាំ ពេលខ្លះបានបដិសេធន៍ក្នុងការទទួលយកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈព្រោះពួកគេចាំបាច់ត្រូវការរកប្រាក់ចំណូលឱ្យបានលឿន។
- ជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចពលកម្មដែលជាបុរស ចង់ត្រឡប់ទៅធ្វើការភ្លាមៗដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសាររបស់ពួកគេ។

## ៣.២. សេវាគាំទ្រដែលមានដើម្បីផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស




អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះរួមមានស្ថាប័នរដ្ឋាភិបាល និងអង្គការដែលផ្តល់សេវានៅសហគមន៍ត្រូវបានសុំអោយពណ៌នាអំពីសេវាកម្មដែលមានដើម្បីផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

នៅក្នុងប្រទេសកម្ពុជាមានសេវាគាំទ្រជនរងគ្រោះជាច្រើនត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ សេវាគាំទ្រទាំងនេះត្រូវបានបែងចែកជាបីក្រុម ដូចជា ការជួយសង្គ្រោះ ឬការកំណត់អត្តសញ្ញាណជនរងគ្រោះ ការថែទាំក្រោយពេលសង្គ្រោះ ការធ្វើសមាហរណកម្មឡើងវិញ ។

លើសពីនេះទៀតចំពោះសេវាគាំទ្រដែលផ្តល់ដោយផ្ទាល់ គឺមានសម្ព័ន្ធអង្គការមួយចំនួនធ្វើការក្នុងការសម្របសម្រួល និងធ្វើអោយប្រសើរឡើងនូវការផ្តល់សេវាទាំងនោះ។ បណ្តាញសម្ព័ន្ធអង្គការទាំងនេះរួមមានអង្គការកូសេកាំ (COSECAM) អង្គការ ECPAT កម្ពុជា សម្ព័ន្ធចាប់ដៃ (Chab Dai Coalition) អង្គការទាំងនេះផ្តល់នូវការសម្របសម្រួល វគ្គបណ្តុះបណ្តាល និងការគាំទ្រផ្សេងទៀតទៅដល់អង្គការដែលផ្តល់សេវាកម្មដោយផ្ទាល់ដល់ជនរងគ្រោះដោយអំពើជួញដូរ។

### ៣.២.១.ការកំណត់អត្តសញ្ញាណ និងអន្តរាគមន៍វិបត្តិ

គំរូផ្សេងៗនៃការឆ្លើយតបនៅក្នុងការកំណត់អត្តសញ្ញាណ និងអន្តរាគមន៍វិបត្តិដល់ជនរងគ្រោះដោយអំពើជួញដូរត្រូវបានគេអនុវត្តដោយយោងលើប្រភេទនៃអំពើជួញដូរដែលជនរងគ្រោះធ្លាប់ជួបប្រទះ។

ជាងមួយទសវត្សមុន គម្រូមួយដែលដឹកនាំដោយអង្គការសង្គមស៊ីវិល ដោយមានការសហការជាមួយរាជរដ្ឋាភិបាល គឺអនុវត្តការឆែកឆេរផ្ទះបន និងកន្លែងផ្សេងទៀតដែលធ្វើអាជីវកម្មផ្លូវភេទដើម្បី “***កំណត់អត្ត***

*សញ្ញាណ*’ និង “*ជួយសង្គ្រោះ*” ជនរងគ្រោះដោយអំពើជួញដូរមនុស្សសម្រាប់អំពើធ្វើអាជីវកម្មផ្លូវភេទ។ ការកំណត់អត្តសញ្ញាណ និងសង្គ្រោះ គឺស្ថិតក្រោមកិច្ចសហការណ៍ជាមួយនគរបាល។ ពេលត្រូវបានសង្គ្រោះ នគរបាល និងអង្គការសង្គ្រោះបានសហការជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបញ្ជូនជនរងគ្រោះ ជាពិសេសអនីតិជន ទៅកាន់ជម្រកសុវត្ថិភាព ឫបញ្ជូនពួកគេត្រឡប់ទៅកាន់សហគមន៍ និង/ឫ ក្រុមគ្រួសាររបស់ពួកគេ។ ក្នុងរយៈពេលពីបីឆ្នាំកន្លងទៅ វិធីសាស្រ្តនេះពុំសូវមានប្រសិទ្ធភាពទៀតទេ ដោយសារច្បាប់ថ្មីចែងឲ្យបិទផ្ទះ ហើយអំពើពេស្យាចារត្រូវបានធ្វើដោយលួចលាក់។ អង្គការជួយសង្គ្រោះខ្លះកំពុងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្សេងទៀតកំពុងធ្វើការប៉ាន់ប្រមាណវិធីសាស្រ្តផ្សេងៗ ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ។

វិធីសាស្រ្តមួយទៀតក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺតាមរយៈការកំណត់អត្តសញ្ញាណជនរងគ្រោះដែលត្រឡប់មកពីប្រទេសផ្សេងៗ ដែលមានដូចជាប្រទេសម៉ាឡេស៊ី ថៃ និងវៀតណាម។ ជាទូទៅអ្នកត្រឡប់មកវិញធ្លាប់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចពលកម្ម (ឫពេលខ្លះធ្វើទេសន្តប្រវេសន៍មិនមានសុវត្ថិភាព ឫខុសច្បាប់)។ ការកំណត់អត្តសញ្ញាណនេះធ្វើឡើងជាមួយអាជ្ញាធរនៅក្នុងប្រទេសផ្សេងៗនៅពេលដែលធ្វើមាតុភូមិនិវត្តជនរងគ្រោះលក្ខណៈផ្លូវការ ឫតាមការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមព្រំដែនព្រោះជនរងគ្រោះចូលមកវិញ ដោយខ្លួនឯង។ អង្គការខ្លះមានកម្មវិធីនៅតាមចំនុចច្រកចេញចូលព្រំដែនដើម្បីព្យាយាមកំណត់អត្តសញ្ញាណ កុមារ ឫជនរងគ្រោះដោយអំពើជួញដូរមនុស្សផ្សេងទៀត។

បន្ថែមពីនេះពេលខ្លះជនរងគ្រោះ ឫគ្រួសាររបស់ពួកគេស្វែងរកសេវាគាំទ្រដោយផ្ទាល់ពីអង្គការផ្តល់សេវានៅសហគមន៍ ដូចជាកម្មវិធីជំនួយផ្នែកច្បាប់ ឫកម្មវិធីស្តីអំពីការផ្តល់ជម្រក។

### ៣.២.២. ការថែទាំក្រោយពេលជួយសង្គ្រោះ

សេវាថែទាំក្រោយពេលជួយសង្គ្រោះ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សមួយចំនួន ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា។ សេវាគាំទ្រទាំងនោះត្រូវបានប្រតិបត្តិជាដំបូងដោយអង្គការសង្គមស៊ីវិលដោយមានកិច្ចសហការជាមួយរាជរដ្ឋាភិបាល។ សេវាគាំទ្រទាំងនោះភាគច្រើនត្រូវបានផ្តល់នៅក្នុងមណ្ឌល និងមានទីតាំងនៅតបន់គោលដៅសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ។ មណ្ឌលមានច្រើនប្រភេទ ហើយប្រភេទនៃ សេវាគាំទ្រសម្រាប់ផ្តល់ដល់ជនរងគ្រោះ រួមមានមណ្ឌលសម្រាប់ប៉ាន់ប្រមាណដែលមានរយៈពេលខ្លី និងមណ្ឌលបង្អែក មណ្ឌលសម្រាប់ឲ្យជនរងគ្រោះស្នាក់នៅក្នុងរយៈពេលវែង សេវាថែទាំសុខភាព ការគាំទ្រផ្នែកចិត្តសង្គម ការអប់រំ បំណិនជីវិត និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួយផ្នែកច្បាប់ និងការតំណាងការការពារក្តី (សូមមើល សេវាកម្មដែលមានដើម្បីផ្តល់អោយមានរៀបលំអិតនៅខាងក្រោម)។

អង្គការមួយចំនួនផ្តល់សេវាគាំទ្រដោយមានលក្ខណៈទូលំទូលាយ ហើយអង្គការមួយចំនួនទៀតផ្តោតលើតែសេវាជាក់លាក់ណាមួយប៉ុណ្ណោះ។ ឧទាហរណ៍ អង្គការមួយចំនួន ដែលអនុវត្តកម្មវិធីផ្តល់ជម្រកសម្រាប់ជនរងគ្រោះស្នាក់នៅមានការផ្តល់នូវការប្រឹក្សាយោបល ការអប់រំ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណែកអង្គការមួយចំនួនផ្សេងទៀតផ្តល់តែសេវាគាំទ្រផ្នែកច្បាប់ ឬការគាំទ្រផ្នែកចិត្តសង្គម។

សេវាថែទាំក្រោយពេលជួយសង្គ្រោះភាគច្រើនផ្តល់ដល់ស្ត្រី និងកុមារីដែលជាជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។ អង្គការមួយចំនួនដែលមានបេសកកម្មស្រដៀងគ្នា បានបង្កើតនូវបណ្តាញ ឬប្រព័ន្ធបញ្ជូនមិនផ្លូវការដើម្បីជួយដល់ជនរងគ្រោះ។ អង្គការជួយសង្គ្រោះរមែងបញ្ជូនជនរងគ្រោះជាអនីតិជនទៅកាន់មណ្ឌលប៉ាន់ប្រមាណដែលមានរយៈពេលខ្លី ដែលផ្តល់ការប៉ាន់ប្រមាណដ៏ស៊ីជម្រៅមួយអំពីស្ថានភាពទាំងមូលរបស់កុមារី និងអាចធ្វើសមាហរណកម្ម អោយជនរងគ្រោះទៅកាន់គ្រួសារ ឬសហគមន៍ដើមរបស់ពួកគេ ឬបញ្ជូនពួកគេទៅកាន់កន្លែងដែលផ្តល់ការការថែទាំដែលមានរយៈពេលវែងដោយផ្អែកលើតម្រូវការរបស់ជនរងគ្រោះ។ ស្ត្រីដែលពេញវ័យត្រូវបានបញ្ជូនទៅកាន់មណ្ឌល ឬទៅកាន់សហគមន៍របស់ពួកគេ ហើយពួកគេមានសិទ្ធបដិសេដចំពោះសេវា ឬត្រូវបានបញ្ជូនទៅកាន់មណ្ឌលដែលផ្តល់នូវសេវាកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរដែលពេញវ័យ។

សេវាថែទាំក្រោយពេលជួយសង្គ្រោះសម្រាប់កុមារា ដែលមានអាយុក្រោមអាយុ១៨ឆ្នាំ គឺនៅមានកម្រិតជាង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានសេវាគាំទ្រមួយចំនួនសម្រាប់ផ្តល់ដល់ពួកគេ។ អង្គការមួយចំនួនតូចបានបង្កើតមណ្ឌលថែទាំជាពិសេសសម្រាប់ក្មេងប្រុស ហើយអង្គការមួយចំនួនផ្សេងទៀតផ្តល់ជម្រកស្នាក់នៅតាមមណ្ឌលសម្រាប់ជនរងគ្រោះដែលជាក្មេងប្រុស ជាពិសេសកុមារាដែលមានអាយុតិច ឬឲ្យពួកគេស្នាក់នូវក្នុងមណ្ឌលដែលមានការរៀបចំសម្រាប់ក្មេងប្រុស និងក្មេងស្រី។ សេវាថែទាំក្រោយពេលជួយសង្គ្រោះ សម្រាប់ជនរងគ្រោះបុរសដែលមានអាយុពេញវ័យគឺកាន់តែនូវមានកម្រិតជាងសេវាថែទាំសម្រាប់ក្មេងប្រុសទៅទៀត។ មានអង្គការមួយចំនួនកំពុងចាប់ផ្តើមផ្តល់នូវការថែទាំក្រោយពេលជួយសង្គ្រោះសម្រាប់បុរស ជាពិសេសបុរសដែលជួបប្រទះនឹងអំពើជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចពលកម្ម។ សេវាគាំទ្រទាំងនេះជាសេវានៅតាមសសហគមន៍ ហើយផ្តល់នូវការគ្រប់គ្រងករណី និងសេវាតាមដាន រួមមានការគាំទ្របន្ទាន់ ការប្រឹក្សាយោបល់ ការគាំទ្រផ្នែកចិត្តសង្គម និងការបង្កើតប្រាក់ចំណូល។

### ៣.២.៣. ការធ្វើសមាហរណកម្មឡើងវិញ និង/ឬ សមាហរណកម្ម

កម្មវិធីនៃការធ្វើសមាហរណកម្មឡើងវិញ និងសមាហរណកម្ម គឺជាសេវាគាំទ្រដែលបង្កើតឡើងដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងការចូលក្នុងសហគមន៍មួយថ្មី ឬត្រឡប់ចូលសហគមន៍កំណើតរបស់ពួកគេ ន្ទាប់ពីរងគ្រោះដោយអំពើជួញដូរ។

នៅក្នុងប្រទេសកម្ពុជា គម្រូដែលប្រើភាគច្រើននៃសេវាគាំទ្រក្នុងការធ្វើសមាហរណកម្មឡើងវិញ ឬសមាហរណកម្ម គឺត្រូវបានអនុវត្តដោយអង្គការផ្តល់សេវាគាំទ្រនៅសហគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីធ្វើអាជីវកម្មផ្លូវភេទ។ គម្រូនេះគឺការធ្វើសមាហរណកម្មឡើងវិញ ឬសមាហរណកម្មទៅក្នុងសហគមន៍ពីមណ្ឌលថែទាំដែលរមែងជាការពន្យាពេលស្នាក់នៅក្នុងមណ្ឌល។ ក្នុងកំឡុងពេលនៃការស្នាក់នៅក្នុងមណ្ឌល ជនរងគ្រោះទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត និងសេវាគាំទ្រផ្សេងៗ។ ពេលបញ្ចប់កម្មវិធីរបស់មណ្ឌល ជនរងគ្រោះត្រឡប់មកសហគមន៍វិញ។ ជាផ្នែកមួយនៃដំណើរការនៃការធ្វើសមាហរណកម្មឡើងវិញ អង្គការមួយចំនួនបានធ្វើការប៉ាន់ប្រម៉ាណពីស្ថានភាពគ្រួសារ ចំនុចខ្លាំង និងការគាំទ្រក្នុងសហគមន៍ និងផ្តល់ការគាំទ្រដល់ជនរងគ្រោះក្នុងការចាប់ផ្តើមមុខរបរតូចតាចមួយដោយផ្អែកលើជំនាញវិជ្ជាជីវៈដែលពួកគេទទួលបានការបណ្តុះបណ្តាល។

សេវាគាំទ្រក្នុងពេលធ្វើសមាហរណកម្ម និងសមាហរណកម្មឡើងវិញសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីកេញប្រវ័ញ្ចពលកម្មគឺមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ និងជនរងគ្រោះបានលើកឡើងនៅក្នុងកិច្ចសម្ភាសន៍ថាអ្នកដែលទទួលរងគ្រោះដោយអំពើជួញដូរពលកម្មមិនចង់ស្នាក់នៅក្នុងមណ្ឌលទេ ហើយពួកគេចង់ត្រឡប់ទៅសហគមន៍យ៉ាងឆាប់រហ័ស។ ដូច្នេះជនរងគ្រោះដោយអំពើ ជួញដូរពលកម្មនឹងត្រឡប់ទៅសហគមន៍យ៉ាងឆាប់រហ័សដោយទទួលបានការគាំទ្រតិចតួចនៅក្នុងសហគមន៍ ឬមិនទទួលសេវាគាំទ្រជាច្រើនដូចជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលនោះទេ ដែលជាលទ្ធផលធ្វើឲ្យពួកគេងាយរងគ្រោះកាន់តែខ្លាំងក្នុងការជួញដូរម្តងទៀត។

កម្មវិធីនៃការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញភាគច្រើនផ្តល់សេវាកម្មទាំងនេះដោយមានកិច្ចសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅកំរិតថ្នាក់ស្រុក។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈការិយាល័យសង្គមកិច្ចស្រុកមានទំនួលខុសត្រូវពីរដ្ឋាភិបាលក្នុងការអនុវត្តសេវាកម្មនៃការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញសម្រាប់ជនរងគ្រោះ។ ក្រសួងសង្គមកិច្ចមានប្រព័ន្ធនៃការធ្វើសមាហរណកម្មជាក់លាក់មួយដែលមានទម្រង់ស្តង់ដារសម្រាប់ធ្វើការប៉ាន់ប្រមាណ និងធ្វើការចុះសួរសុខទុក្ខ តាមដានសម្រាប់ប្រជាពលរដ្ឋ។ វាជាទំនួលខុសត្រូវសម្រាប់ការធ្វើសមាហរណកម្មឡើងវិញ។ ទោះបីជាយ៉ាងណាក៏ដោយ ធនធានរបស់សង្គមកិច្ចនៅមានកម្រិតក្នុងការអនុវត្តកិច្ចការទាំងនេះ ដូចច្នេះសេវាកម្មទាំងនេះជាទូទៅត្រូវបានផ្តល់ឲ្យដោយអង្គការដែលផ្តល់សេវាគាំទ្រដល់ជនរងគ្រោះនៅតាមសហគមន៍។ ក្រសួងសង្គមកិច្ចបានខិតខំប្រឹងប្រែងធ្វើការត្រួតពិនិត្យរាល់ការធ្វើជាន់គ្នានៅក្នុងទំនួលខុសត្រូវនៃការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញ។

ក្នុងកំឡុងពេលដំណើរការនៃការសិក្សាស្រាវជ្រាវ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា និងអ្នកផ្តល់សេវាកម្មទាំងអស់បានកំណត់ឃើញមានឧបសគ្គដែល

ប្រឈមជាមួយនឹងសេវាកម្មនៃការធ្វើសមាហរណកម្មឡើងវិញ។ ឧបសគ្គទាំងនោះមានដូចជាការចម្ងាយឆ្ងាយពីការិយាល័យអង្គការទៅកាន់សហគមន៍ដែលជនរងគ្រោះត្រូវបានធ្វើសមាហរណកម្ម និងភាពខ្សត់ខ្សោយនៃធនធានរបស់មន្ទីសង្គមកិច្ចក្នុងការអនុវត្តការងារសមាហរណកម្ម។

ជាលទ្ធផលអង្គការដែលផ្តល់សេវាគាំទ្រដល់ជនរងគ្រោះនៅតាមសហគមន៍មួយចំនួនកំពុងខិតខំធ្វើឲ្យប្រសើរឡើងចំពោះសេវាកម្មសមាហរណកម្ម ដោយបង្កើតនូវកម្មវិធីអន្តរកាលសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើសមាហរណកម្ម និងសមាហរណកម្មឡើងវិញ។

### ៣.២.៤. ភាពជាដៃគូ

សេវាគាំទ្រជនរងគ្រោះត្រូវបានផ្តល់ជាប្រចាំ ដោយមានការសហការជាមួយ ឬតាមរយៈអាជ្ញាធរនៃរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងផ្សេងៗ និងអាជ្ញាធរដែលទទួលខុសត្រូវទាំងឡាយ។ អង្គការដែលអនុវត្តសេវាកម្មជួយសង្គ្រោះ និងការកំណត់អត្តសញ្ញាណ បានអនុវត្តការងារនេះដោយមានការសហការជាមួយនគរបាល។ អង្គការដែលទទួលយកជនរងគ្រោះទៅក្នុងមណ្ឌលភាគច្រើន កើតឡើងជារូបភាពបញ្ជូនពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬដោយមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ហើយការធ្វើសមាហរណកម្មឡើងវិញ ធ្វើឡើងក្រោមការសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទានៅថ្នាក់ស្រុក នៅកន្លែងនៃការធ្វើសមាហរណកម្មឡើងវិញ និងការធ្វើសមាហរណកម្ម។

គោលនយោបាយភូមិឃុំ/សង្កាត់មានសុវត្ថិភាពរបស់ក្រសួងមហាផ្ទៃដែលត្រូវបានប្រកាសអោយប្រើប្រាស់នៅក្នុងឆ្នាំ២០១០ ក៏បានផ្តោតជាអាទិភាពក្នុងការកាត់បន្ថយអំពើជួញដូរមនុស្សផងដែរ។ គោលនយោបាយនេះជំរុញឱ្យមានការកាត់បន្ថយបទល្មើសឧក្រិដ្ឋ និងផ្តល់អាទិភាពនានាដល់គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និង កុមារឃុំ/សង្កាត់ដើម្បីធ្វើការងារនេះនៅតាមឃុំ/សង្កាត់ក្នុងមូលដ្ឋានរបស់ពួកគេ។ នេះគឺជាភាពជាដៃគូដែលអាចត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់ និងផ្តល់សេវាកម្មដល់ជនរងគ្រោះនៅសហគមន៍។

អ្នកផ្តល់សេវាគាំទ្រសល់ជនរងគ្រោះ ក៏ពណ៌នាអំពីបណ្តាញបញ្ជូនទៅរកសេវាកម្មរវាងអង្គការសង្គមស៊ីវិល។ អង្គការដែលមានជំនាញនៅក្នុងការផ្តល់សេវាកម្មជាក់លាក់ណាមួយ បានបង្កើតបណ្តាញបញ្ជូនដល់ជនរងគ្រោះដើម្បីឲ្យពួកគេទទួលយកសេវាគាំទ្រ ដែលអង្គការមិនមានសម្រាប់ផ្តល់ឲ្យ។ ឧទាហរណ៍អង្គការខ្លះមិនផ្តល់សេវាកម្មផ្នែកកំណត់អត្តសញ្ញាណ និងមិនបានផ្តល់សេវាជួយសង្គ្រោះទេ ប៉ុន្តែអង្គការទាំងនោះគ្រាន់តែទទួលយកជនរងគ្រោះ ដែលបញ្ជូនមកដែលត្រូវបានគេកំណត់អត្តសញ្ញាណរួចជាស្រេចដោយអង្គការមួយផ្សេងទៀត។ អង្គការខ្លះមិនបានផ្តល់ការគាំទ្រផ្នែកច្បាប់ ឬការតំណាងការការពារក្តី ហើយអង្គការទាំងនេះបានបញ្ជូនជងរងគ្រោះទៅកាន់អង្គការផ្នែកច្បាប់ដើម្បីផ្តល់សេវាគាំទ្រទាំងនេះ។

## ៣.២.៥. សេវាគាំទ្រដែលផ្តល់ដល់ជនរងគ្រោះ

នៅក្នុងការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះត្រូវបានសាកសួរ ថាតើពួកគេបានផ្តល់នូវសេវាគាំទ្រដូចដែលបានបង្ហាញក្នុងបញ្ជីរាយឈ្មោះសេវាកម្មជាក់លាក់ទាំងនេះដែរ ឬទេ។ ពួកគេឆ្លើយថាមាន អត់មាន ឬធ្វើការបញ្ជូនបន្ត។ អង្គការអាចផ្តល់នូវចំលើយច្រើនជាងមួយ ឧទាហរណ៍ ពួកគេអាចឆ្លើយថាមាន យើងផ្តល់នូវសេវាគាំទ្រ ហើយយើងក៏ធ្វើការបញ្ជូនបន្តទៅកាន់អង្គការផ្សេងទៀតដែលផ្តល់សេវាគាំទ្រទាំងនោះដែរ។ អ្នកឆ្លើយសំនួរ ក៏ត្រូវបានសួរអំពីសេវាគាំទ្រផ្សេងទៀតដែលពួកគេផ្តល់ដល់ជនរងគ្រោះ ដែលមិនមាននៅក្នុងបញ្ជី។ ខាងក្រោមជាការសង្ខេបដែលពណ៌នាអំពីសេវាគាំទ្រទាំងអស់ដែលផ្តល់ឲ្យ ហើយសេវាគាំទ្រនីមួយៗត្រូវបានពណ៌នាលំអិតដោយចាត់ជាក្រុម។




### ៣.២.៥.១.ជម្រកសុវត្ថិភាព



ការផ្តល់នូវជម្រកសុវត្ថិភាព ជាសេវាគាំទ្រប្រមូលផ្តុំក្នុងការឆ្លើយតបនឹងអំពើជួញដូរមនុស្សដើម្បីការកេងប្រវ័ញ្ចនៅក្នុងប្រទេសកម្ពុជា។ ជម្រកសុវត្ថភាពគឺស្ថិតនៅតំបន់គោលដៅសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ។ ជម្រកសុវត្ថិភាពត្រូវបានផ្តល់ដោយអង្គការផ្តល់សេវាគាំទ្រចំនួន៤៨% ដែលត្រូវបានសម្ភាសន៍។ អង្គការដែលមិនផ្តល់នូវជម្រក ជាញឹកញាប់បានធ្វើការបញ្ជូនជនរងគ្រោះបន្តទៅអង្គការដទៃទៀត ដែលផ្តល់សេវាកម្មនេះ។

មណ្ឌលមានលក្ខណៈផ្សេងៗគ្នា ដូចជាមណ្ឌលសំចតបណ្តោះអាសន្នរយៈពេលខ្លី និងមណ្ឌលស្តារនីតិសម្បទាដែលមានរយៈពេលវែង។ មណ្ឌលទាំងនេះត្រូវបានពណ៌នាដូចខាងក្រោម។

មណ្ឌលជាច្រើនដែលមាននៅក្នុងប្រទេសកម្ពុជា បានផ្តោតលើក្រុមគោលដៅដែលជាជនរងគ្រោះផ្សេងៗគ្នា។ មណ្ឌលភាគច្រើនផ្តល់សេវាគាំទ្រដល់កុមារី និងស្ត្រី ដែលរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីធ្វើអាជីវកម្មផ្លូវភេទ។ អង្គការមួយចំនួនតូចបានផ្តល់ជម្រកដល់កុមារា ដែលមានអាយុក្រោម១៨ឆ្នាំ។ ក្នុងចំណោមអង្គការដែលត្រូវបានធ្វើបទសម្ភាសន៍ មិនមានអង្គការណាមួយបានផ្តល់ជម្រកដល់ជនរងគ្រោះដែលជាបុរសទេ លើកលែងតែមណ្ឌលសំចតប៉ោយប៉ែត ដែលផ្តល់ការស្នាក់នៅក្នុងរយៈពេលខ្លីដល់ពួកគេ។

ដោយសារតែការមានការថយចុះចំនួនករណីថ្មីៗនៃអំពើជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ មណ្ឌលសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីធ្វើអាជីវកម្មផ្លូវភេទភាគច្រើនមានគ្រែទំនេរ ហើយមណ្ឌលខ្លះកំពុងពិនិត្យលើជម្រើសថ្មីសម្រាប់ការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ។ មណ្ឌលទាំងអស់ក៏បានផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយការរំលោភ និងអំពើហិង្សាក្នុងគ្រួសារផងដែរ។

បច្ចុប្បន្ននេះមានមណ្ឌលជាច្រើនប្រភេទ ហើយប្រព័ន្ធនៃការបញ្ជូនជនរងគ្រោះពីមណ្ឌលមួយទៅកាន់មណ្ឌលមួយផ្សេងទៀតក៏ត្រូវបានធ្វើឡើងក្នុងចំណោមមណ្ឌលទាំងនេះដែរ។ ខាងក្រោមនេះជាឧទាហរណ៍នៃមណ្ឌលដែលមានសម្រាប់ជនរងគ្រោះ៖

- ***មណ្ឌលសំចតរយៈពេលខ្លី៖*** មណ្ឌលសំចតរយៈពេលខ្លីគឺត្រូវបានបង្កើតឡើងនៅតាមតំបន់ព្រំដែនជាប់ប្រទេសថៃ ដូចជានៅតំបន់ប៉ោយប៉ែត។ មណ្ឌលនេះផ្តល់នូវជម្រកមូលដ្ឋានសម្រាប់រយៈពេល១ ឬ២ថ្ងៃ ការធ្វើការប៉ាន់ប្រមាណ និងការបញ្ជូនទៅរកសេវាគាំទ្របន្ត ទាំងការបញ្ជូនទៅកាន់សហគមន៍កំណើត ឬទៅអង្គការដែលផ្តល់សេវាគាំទ្រនៅសហគមន៍ដើម្បីទទួលបាននូវសេវាគាំទ្រផ្សេងៗ និងជម្រករយៈពេលវែង។
- ***មណ្ឌលសម្រាប់ធ្វើការប៉ាន់ប្រមាណសម្រាប់ក្មេងស្រីអនីតិជន ដែលជាជនរងគ្រោះដោយអំពើជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ៖*** នៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប មានមណ្ឌលមួយត្រូវបានបង្កើតឡើងជាមណ្ឌលសម្រាប់ធ្វើការប៉ាន់ប្រមាណ ដែលមានលក្ខណៈទូលំទូលាយសម្រាប់ក្មេងស្រីអនីតិជន ដែលធ្លាប់ទទួលរងគ្រោះដោយអំពើជួញដូរមនុស្ស ឬការរំលោភ។ ជនរងគ្រោះអាចស្នាក់នៅ

ក្នុងមណ្ឌលបានរហូតដល់២ខែ ហើយមណ្ឌលនេះមានតួនាទីជា "បន្ទប់សង្គ្រោះបន្ទាន់" សម្រាប់ក្មេងស្រីដែលធ្លាប់ទទួលរងគ្រោះដោយអំពើជួញដូរ។ អ្នកស្នាក់នៅក្នុងមណ្ឌលត្រូវបានផ្តល់នូវការថែទាំមូលដ្ឋាន ដូចការការផ្តល់អាហារ ជម្រក និង ការទទួលស្គាល់។ ការថែទាំសុខភាពផ្លូវចិត្ត ការប៉ាន់ប្រមាណពីស្ថានភាពគ្រួសារ និងសហគមន៍ ត្រូវបានធ្វើឡើងដើម្បីធ្វើការកំណត់ជម្រើសនៃការស្នាក់នៅដ៏ប្រសើរសម្រាប់ជនរងគ្រោះ ដូចជាការស្នាក់នៅជាមួយក្រុមគ្រួសារ ឬការស្នាក់នៅក្នុងមណ្ឌលដែលមានរយៈពេលវែង។

- ***ការថែទាំនៅក្នុងមណ្ឌលសម្រាប់ក្មេងស្រីអនីតិជន ដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីធ្វើអាជីវកម្មផ្លូវភេទ៖*** អង្គការខ្លះផ្តល់នូវការថែទាំនៅក្នុងមណ្ឌលសម្រាប់តែជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលជាស្ត្រី។ អង្គការទាំងនេះមានសមាសភាពស្រដៀងគ្នា ដែលរួមមាន មណ្ឌលសុវត្ថិភាពដែលផ្តល់ការស្នាក់នៅ អាហារ និងសំលៀកបំពាក់ ការគាំទ្រ និងការប្រឹក្សាផ្នែកចិត្តសង្គម ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មឡើងវិញ។ ប៉ុន្តែអាទិភាពរបស់អង្គការនីមួយៗមានលក្ខណៈខុសៗគ្នា។ អង្គការខ្លះផ្តល់កម្មវិធីថែទាំដោយបែងចែកតាមដំណាក់កាលនីមួយៗដាច់ពីគ្នា ដោយផ្អែកទៅលើកម្រិតនៃភាពសះស្បើយរបស់ជនរងគ្រោះនីមួយៗ ហើយអង្គការខ្លះបានផ្តោតទៅលើសេវាគាំទ្រតែមួយផ្នែក ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីខ្លះត្រូវបានអនុវត្តដោយអង្គការជាតិ និងអង្គការអន្តរជាតិដែលផ្តល់សេវាគាំទ្រនៅតាមសហគមន៍។
- ***ការថែទាំនៅក្នុងមណ្ឌលសម្រាប់ក្មេងប្រុស និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖*** អង្គការខ្លះផ្តល់នូវការថែទាំនៅក្នុងមណ្ឌលសម្រាប់ជនរងគ្រោះជាអនីតិជន ដែលធ្លាប់ជួបប្រទះនូវអំពើជួញដូរមនុស្ស។ សេវាគាំទ្រទាំងនេះអាចធ្វើឡើងយ៉ាងហោចណាស់តាមមធ្យោបាយពីរយ៉ាងដែរ។ មានអង្គការមួយចំនួនផ្សេងទៀតបានបើកជាមណ្ឌលសម្រាប់ក្មេងប្រុស ដើម្បីឆ្លើយតបនឹងកង្វះខាតនៃការផ្តល់សេវាគាំទ្រសម្រាប់ពួកគេ។ អង្គការខ្លះទៀតបានផ្តល់ការថែទាំនៅក្នុងមណ្ឌលសម្រាប់ក្មេងប្រុស និងក្មេងស្រីសម្រាប់រយៈពេលច្រើនឆ្នាំ ជាមួយនិងក្មេងៗជាច្រើនផ្សេងទៀត ដែលពួកគេមិនអាចទទួលបានការថែទាំពីគ្រួសារដោយសារហេតុផលផ្សេងៗជាច្រើន (មិនមែនដោយសារតែគាត់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះទេ)។
- ***ការថែទាំជាមួយគ្រួសារចិញ្ចឹមសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សអាយុក្រោម១៨ឆ្នាំ៖*** ថ្មីៗនេះមានកម្មវិធីជាច្រើនកំពុងចាប់ផ្តើម (ឬកំពុងរៀបចំផែនការ ) ផ្តល់នូវការថែទាំជាមួយគ្រួសារចិញ្ចឹមសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ កម្មវិធីនេះត្រូវបានធ្វើឡើងដោយផ្អែកលើការប៉ាន់ប្រមាណពីសុវត្ថិភាព និងការធ្វើការកំណត់មួយ ដែលអាចធានាថាអនីតិជនមិនស្ថិតក្នុងស្ថានភាពរងគ្រោះខ្លាំង។ អង្គការខ្លះបានកំពុងធ្វើការកំណត់រកក្រុមគ្រួសារ ដែលអាចត្រូវបានបណ្តុះបណ្តាលដើម្បី

ធ្វើជាឪពុកម្ដាយចិញ្ចឹមបណ្ដោះអាសន្នសម្រាប់កុមារ ដូច្នេះកុមារមិនចាំបាច់ទៅស្នាក់នៅក្នុងមណ្ឌលទេ។

- ***ការថែទាំនៅតាមផ្ទះដែលឯករាជ្យ៖*** ថ្មីៗនេះមានកម្មវិធីខ្លះកំពុងចាប់ផ្ដើមបង្កើតផ្ទះដែលរស់នៅឯករាជ្យសម្រាប់អ្នកស្នាក់នៅក្នុងមណ្ឌល ដើម្បីបន្សាំពួកគេពីបរិយាកាសដែលធ្លាប់រស់នៅក្នុងមណ្ឌលឱ្យទៅរស់នៅក្នុងសហគមន៍វិញ។ ស្ថានភាពនេះគឺកើតឡើងជាទូទៅនៅពេលដែលកុមារ ឬមនុស្សពេញវ័យមិនអាចធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍កំណើតរបស់ពួកគេ។ នេះជាការបោះជំហ៊ានមួយពីការស្នាក់នៅក្នុងមណ្ឌលដែលមានការការពារ ទៅជាការរស់នៅដោយឯករាជ្យនៅតាមផ្ទះ។ ស្ថានភាពរស់នៅរបស់ពួកគេគឺមានលក្ខណៈជាក្រុមតូចៗ ដែលពួកគេយ៉ាងហោចណាស់ទទួលបានការគាំទ្រមួយផ្នែកពីអង្គការដែលផ្ដល់សេវាកម្មនៅសហគមន៍ ដើម្បីឲ្យពួកគេអាចទទួលបានការរស់នូវដែលមានឯករាជ្យដ៏ពេញលេញមួយ។

### ៣.២.៥.២.ការគ្រាំទ្រផ្នែកចិត្តសង្គម




៦៩% នៃអង្គការដែលត្រូវបានសម្ភាសន៍បាន ផ្ដល់សេវាកម្មគ្រាំទ្រផ្នែកចិត្តសង្គម។ ប្រភេទនៃការគ្រាំទ្រផ្នែកចិត្តសង្គមមានទាំងការផ្ដល់ដំបូន្មាន និងប្រឹក្សាយោបល់ដោយការបង្គាប់ ឧទាហរណ៍ "អ្នកគួរតែទៅរកកម្មវិធី XX ដើម្បីទទួលបានសេវាកម្ម" និងការព្យាបាលផ្លូវការមួយ។ ក្នុងចំណោមអង្គការចំនួន២៩ ដែលត្រូវបានសម្ភាសន៍ មានអង្គការចំនួន២៤ បានផ្ដល់ការគាំទ្រលើផ្នែកចិត្តសង្គមដោយបុគ្គលិកក្នុងស្រុក ដែលទទួលបានការបណ្ដុះបណ្ដាល។ អង្គការចំនួន៥បានផ្ដល់សេវាកម្មនេះដោយបុគ្គលិកក្នុងស្រុក ដោយមានការគាំទ្រពីទីប្រឹក្សាអន្តរជាតិ។

ក្រុមគោលដៅសម្រាប់ការផ្ដល់ការគ្រាំទ្រផ្នែកចិត្តសង្គមភាគច្រើន គឺជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាស្ត្រី និងកុមារី។ ការគាំទ្រផ្នែកចិត្តសង្គមក៏មានសម្រាប់ជនរងគ្រោះដែលជាកុមារាផងដែរ

ចំពោះមណ្ឌលដែលផ្ដល់ការស្នាក់នៅសម្រាប់ទាំងក្មេងប្រុស និងក្មេងស្រីដែលមានអាយុក្រោម១៨ឆ្នាំ។ មានតែអង្គការមួយប៉ុណ្ណោះដែលត្រូវបានសម្ភាសន៍ ថាបានផ្ដល់ការគាំទ្រផ្នែកចិត្តសង្គមដាច់ដោយឡែកសម្រាប់បុរសពេញវ័យ។

ទំនោរកើនឡើងនៅក្នុងអង្គការអន្តរជាតិខ្លះ គឺជាគម្រូនៃការធ្វើអន្តរាគមន៍ ដែលហៅថាការថែទាំករណីការប៉ះទង្គិចផ្លូវចិត្ត ហើយបែងចែកផ្នែកនៃការគ្រប់គ្រងករណីដាច់ពីគ្នា និងផ្នែកប្រឹក្សាយោបល់ជាមួយមនុស្សផ្សេងគ្នាដើម្បីទទួលខុសត្រូវសកម្មភាពនីមួយៗ។

### ៣.២.៥.៣.ការថែទាំសុខភាពផ្លូវកាយ




ការថែទាំសុខភាពផ្លូវកាយត្រូវបានផ្ដល់ដោយ ៤៥% នៃអង្គការដែលត្រូវបានស្ទាបស្ទង់មតិ។ អង្គការដែលធ្វើការលើការផ្ដល់ជម្រក និងសង្គ្រោះបានផ្ដល់ជំនួយសង្គ្រោះបឋម និងការថែទាំសុខភាពបន្ទាន់។ មណ្ឌលក៏បានផ្ដល់ការពិនិត្យសុខភាពជាទៀងទាត់នៅនឹងកន្លែង ឬបញ្ជូនទៅកាន់សេវាគាំទ្រសុភាពក្នុងមូលដ្ឋាន។

អង្គការដែលមិនផ្ដល់ការថែទាំសុខភាព គឺអង្គការដែលផ្ដល់សេវាគាំទ្រផ្នែកច្បាប់ ឬសេវាកម្មផ្សេងទៀតដែលមិនផ្ដល់ជាជម្រក។

នៅក្នុងឆ្នាំ២០១២ អង្គការ ECPAT បាន ផ្ដួចផ្ដើមគម្រោងការថែទាំសុខភាពដោយផ្ដល់នូវថវិការគាំទ្រដល់មណ្ឌលចំនួន៣ ដើម្បីពង្រឹងសេវាថែទាំសុខភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ជាផ្នែកមួយនៃការផ្ដួចផ្ដើមនេះ អង្គការ ECPAT ក៏បានផ្ដល់នូវសំភារៈសម្រាប់បង្កើនការយល់ដឹងលើតម្រូវការការថែទាំសុខភាពរបស់ជនរងគ្រោះដោយអំពើជួញដូរ ដល់អ្នកផ្ដល់នូវការថែទាំសុខភាពរបស់រាជរដ្ឋាភិបាល។

### ៣.២.៥.៤.អាហាររូបត្ថម្ភ




អាហាររូបត្ថម្ភត្រូវបានផ្តល់ជាអាហារនៅក្នុងមណ្ឌល ឬនៅពេលជនរងគ្រោះត្រូវបានសង្គ្រោះ ឬក៏នៅពេលដែលពួកគេមកទទួលសេវាគាំទ្រលើកដំបូង។ ជាង៦០% នៃអង្គការដែលបានធ្វើការសិក្សាបានផ្តល់ការគាំទ្រផ្នែកអាហាររូបត្ថម។ មានអង្គការចំនួន២ បានបញ្ជាក់ថាមានការពិបាកក្នុងការផ្តល់ការគាំទ្រផ្នែកអាហាររូបត្ថម្ភដោយសារម្ចាស់ជំនួយមិនចង់ចំណាយប្រាក់លើផ្នែកអាហារ។ អង្គការមួយបាននិយាយថាពួកគេមានលទ្ធភាពផ្តល់អាហារសម្រាប់អ្នកស្នាក់នៅក្នុងមណ្ឌលតែមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។

### ៣.២.៥.៥. បំណិនជីវិត និង បណ្តុះបណ្តាលវិជ្ជាជីវៈ




៥០% នៃអង្គការដែលបានធ្វើការសិក្សា បានផ្តល់ការគាំទ្រផ្នែកជំនាញបំនិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅនឹងកន្លែង ហើយកម្មវិធីបណ្តុះបណ្តាលភាគច្រើន គឺសម្រាប់ជនរងគ្រោះដោយអំពើជួញដូរដែលជាស្ត្រី។ ប្រធានបទផ្សេងៗទាក់ទងនិងជំនាញបំនិនជីវិត រួមមាន ការរៀបចំផែនការជីវិត ការ

គ្រប់គ្រងហិរញ្ញវត្ថុ សុវត្ថិភាព និងការការពារដើម្បីបង្ការភាពរងគ្រោះដោយអំពើជួញដូរនៅថ្ងៃខាងមុខ។ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ជាច្រើនដែលបានផ្តល់ដល់ជនរងគ្រោះមានដូចជា ជំនាញកាត់សក់ កាត់ដេរ សំអាងការ រដ្ឋបាលការិយាល័យ និងផ្នែកកសិកម្មមួយចំនួន។

អង្គការមួយចំនួន ជាទូទៅបានបញ្ជូនជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌល ទៅអង្គការផ្សេងទៀត ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការធ្វើការបញ្ជូននេះ ជាទូទៅត្រូវបានធ្វើឡើងនៅពេលដែលជនរងគ្រោះ ស្នាក់នៅក្នុងមណ្ឌលចង់ទទួលបានការបណ្តុះបណ្តាលជំនាញណាមួយ ដែលមិនមាននៅក្នុងមណ្ឌល។ ការបញ្ជូនក៍ត្រូវបានធ្វើឡើងទៅកាន់មណ្ឌលមួយចំនួនផងដែរ ជាពិសេសនៅពេលដែលជនរងគ្រោះត្រូវការកន្លែងស្នាក់នៅក្នុងរយៈពេលវែង ដើម្បីបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយ។

នៅក្នុងអង្គការចំនួន២ នៅពេលដែលជនរងគ្រោះមានសុវត្ថភាព និងជាសះស្បើយពេញលេញ ពួកគេអាចទទួលបាននូវកម្មវិធីគាំទ្របន្តទៀតដែលផ្តោតសំខាន់លើការផ្តល់ជំនាញ ដើម្បីឲ្យពួកគេអាចមានលទ្ធភាពរកប្រាក់ចំណូលបាន។ ទោះជាយ៉ាងណាក៏ដោយ អង្គការភាគច្រើនពុំបានធ្វើការបែងចែកឲ្យដាច់ពីគ្នា រវាងមណ្ឌលសុវត្ថិភាពសង្គ្រោះបន្ទាន់ និងនិងមណ្ឌលផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកស្នាក់នៅដែលមានរយៈពេលវែងឡើយ គឺពួកគេរស់នៅជាមួយគ្នានៅក្នុងបរិវេណផ្ទះតែមួយ។

### ៣.២.៥.៦. សុវត្ថិភាពសេដ្ឋកិច្ច




៤៧% នៃអង្គការដែលបានធ្វើការសិក្សាបានបញ្ជាក់ថា ពួកគេបានផ្តល់នូវការគាំទ្រផ្នែកសុវត្ថភាពសេដ្ឋកិច្ច។ នៅពេលដែលត្រូវបានធ្វើការសាកសួរថាតើអង្គការបានផ្តល់នូវការគាំទ្រផ្នែកសុវត្ថភាពសេដ្ឋកិច្ចដែរឬទេ អង្គការមួយចំនួនបាន បកស្រាយថាបានផ្តល់នូវជម្រក និងការចំណាយលើការស្នាក់នៅក្នុងមណ្ឌល។ អង្គការមួយចំនួនផ្សេងទៀត បានបញ្ជាក់ថាបានផ្តល់អាហារជាបន្ទាន់ វគ្គបណ្តុះបណ្តាលរយៈពេលវែង ឬកម្មវិធីបង្កើតប្រាក់ចំណូលផ្សេងៗ។ ពុំមានអង្គការណាមួយបានបញ្ជាក់ថាបានផ្តល់ជំនួយហិរញ្ញវត្ថុជាបន្ទាន់

នោះទេ។ មានអង្គការមួយចំនួនតូចមានការយល់ដឹងច្រើនទាក់ទងនិងជម្រើសផ្សេងៗនៃការផ្តល់ការគាំទ្រផ្នែកសុវត្ថភាពសេដ្ឋកិច្ច។

### ៣.២.៥.៧.ការអប់រំ




ក្នុងចំណោមអង្គការទាំងអស់ដែលបានធ្វើការសិក្សា មានអង្គការចំនួន ៥០% បានផ្តល់នូវកម្មវិធីអប់រំដល់ជនរងគ្រោះ។ ពេលខ្លះការអប់រំត្រូវបានផ្តល់ជាលក្ខណៈក្រៅប្រព័ន្ធដើម្បីជួយឲ្យជនរងគ្រោះអាចតាមទាន់កម្រិតថ្នាក់ដែលសមស្របសម្រាប់ពួកគេ។

អង្គការផ្សេងទៀតបានផ្តល់នូវការអប់រំដែលមានលក្ខណៈក្នុងប្រព័ន្ធ ហើយមានការអនុញ្ញាតពីក្រសួងអប់រំដើម្បីផ្តល់នូវការអប់រំដល់ពួកគេ។ អង្គការភាគច្រើនបានសហការជាមួយប្រព័ន្ធអប់រំសាធារណៈដើម្បីផ្តល់ការអប់រំដល់ជនរងគ្រោះនៅពេលដែលពួកគេមានសុវត្ថភាពពេញលេញ។ ក្នុងនោះក៏មានអង្គការជាច្រើនបានផ្តល់នូវការបង្រៀនជាភាសាអង់គ្លេសសម្រាប់ពួកគេផងដែរ។

### ៣.២.៥.៨. ឯកសារកំណត់អត្តសញ្ញាណ



៤៨% នៃអង្គការទាំងអស់ដែលបានធ្វើការសិក្សា បានផ្តល់នូវការគាំទ្រទាក់ទងនឹងឯកសារកំណត់អត្តសញ្ញាណ។ អង្គការទាំងនេះបានផ្តល់នូវការគាំទ្រដើម្បីទទួលបាននូវឯកសារលិខិតស្នាមផ្សេងៗដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬឯកសារផ្សេងទៀត។ អង្គការបានធ្វើការផ្តល់ការគាំទ្រលើផ្នែកនេះដោយមានការសហការជាមួយអាជ្ញាធររដ្ឋាភិបាលដើម្បីសម្រេចបាននូវកិច្ចការទាំងនេះ។ មានអង្គការជាច្រើនបានបញ្ជូនជនរងគ្រោះទៅអង្គការផ្សេងទៀតដើម្បីទទួលបានការគាំទ្រលើផ្នែកនេះផងដែរ។

### ៣.២.៥.៩. ពត៌មានផ្នែកច្បាប់




៥៩% នៃអង្គការដែលត្រូវបានសម្ភាសន៍បានផ្តល់នូវព័ត៌មានផ្នែកច្បាប់សម្រាប់ជនរងគ្រោះ។ ព័ត៌មាននោះគឺទាក់ទងនឹងសិទ្ធិ និងជម្រើសផ្នែកច្បាប់អាស្រ័យលើរូបភាពនៃការរងគ្រោះ។ ព័ត៌មានផ្នែកច្បាប់ក៏ត្រូវបានផ្តល់ក្នុងកំឡុងពេលសកម្មភាពនៃការធ្វើអន្តោគមន៍ផងដែរ។ ឧទាហរណ៍ ច្បាប់ទាក់ទងនឹងការជួញដូរមនុស្ស ឬការត្រៀមខ្លួនធ្វើចំណាកស្រុករបស់ពលករ។ ជនរងគ្រោះមែងត្រូវបានបញ្ជូនទៅកាន់អង្គការជំនួយផ្នែកច្បាប់ដើម្បីទទួលបានព័ត៌មានទាំងនេះ។ ជាង ៦០% នៃអង្គការដែលបានធ្វើការសិក្សាបានបញ្ជូនជនរងគ្រោះទៅអង្គការ ឬកន្លែងផ្សេងទៀតដើម្បីទទួលបានព័ត៌មានផ្នែកច្បាប់។

### ៣.២.៥.១០. នីតិវិធីច្បាប់



តិចជាង ៥០% នៃអង្គការដែលបានធ្វើការសិក្សាបានផ្តល់នូវការគាំទ្រក្នុងកំឡុងពេលនីតិវិធីច្បាប់។ អង្គការមួយចំនួនបានផ្តោតទាំងស្រុងទៅលើកិច្ចការផ្លូវច្បាប់សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយអង្គការទាំងនោះផ្តល់តែសេវាគាំទ្រផ្នែកច្បាប់តែប៉ុណ្ណោះ។ អង្គការមួយចំនួនទៀតដែលផ្តល់មណ្ឌលស្នាក់នៅដល់ជនរងគ្រោះក៏មានបុគ្គលិកជាមេធាវី និងផ្តល់ការគាំទ្រសម្រាប់នីតិវិធីច្បាប់ផងដែរ។

អង្គារដែលផ្តល់ជំនួយផ្នែកច្បាប់រាយការថាមានការការចំណាយលើផ្នែកផ្សេងៗជាច្រើនទាក់ទងទៅនឹងដំណើរការនីតិវិធីច្បាប់។ ការចំណាយទាំងនេះរួមមាន ថ្លៃដាក់ពាក្យបណ្តឹង និងរបាយការណ៍នគរបាល។ ថ្លៃធ្វើដំណើរក៏ជាខ្ទង់នៃការចំណាយមួយផងដែរ ជាពិសេសនៅពេលដែលជនរងគ្រោះត្រឡប់ទៅសហគមន៍ ហើយតម្រូវអោយត្រឡប់ទៅកាន់តុលាការនៅទីប្រជុំជន។

### ៣.២.៦. នរណាផ្សេងទៀតដែលអាចទទួលសេវាគាំទ្រទាំងនេះ?

ភាគច្រើននៃសេវាកម្មសព្វថ្ងៃគឺត្រូវបានបង្កើតឡើងសម្រាប់ក្រុមគោលដៅជាស្ត្រី ដែលជាជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ។ ប៉ុន្តែផ្ទុយទៅវិញ ស្ទើតែទាំងអស់នៃជនរងគ្រោះដែលទទួលបានសេវាគាំទ្រពីអង្គការទាំងនេះគឺជាជនរងគ្រោះដោយការចាប់រំលោភ ដោយអំពើហឹង្សាក្នុងគ្រួសារ ឬជាអ្នកដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។

បន្ទាប់ពីផ្ទះបនត្រូវបានបិទនៅក្នុងប្រទេសកម្ពុជា មានជនរងគ្រោះថ្មីមួយចំនួនតូចប៉ុណ្ណោះកំពុងត្រូវបានរកឃើញ ដូចច្នេះវាធ្វើឲ្យចំនួនជនរងគ្រោះដែលទទួលសេវាគាំទ្របន្ទាប់ពីបានសង្គ្រោះកាន់តែមានចំនួនតិច។ អ្នកផ្តល់សេវាគាំទ្រស្ទើតែទាំងអស់បានរាយការណ៍ថាមានការថយចុះនៃចំនួនករណីថ្មីៗបើប្រៀបធៀបនិងឆ្នាំកន្លងទៅ។ មណ្ឌលសម្រាប់ធ្វើការប៉ាន់ប្រមាណមួយបានបង្ហាញថាមានតែ ២០% ប៉ុណ្ណោះ នៃជនរងគ្រោះថ្មីៗដែលស្នាក់នៅក្នុងមណ្ឌលក្នុងឆ្នាំនេះគឺជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ អង្គការផ្នែកជួយសង្គ្រោះមួយបានរាយការណ៍ថាមានជនរងគ្រោះថ្មីៗដោយអំពើជួញដូរផ្លូវភេទតែ៣នាក់ប៉ុណ្ណោះនៅក្នុងឆ្នាំនេះ។

អង្គការផ្តល់សេវាគាំទ្រនៅតាមសហគមន៍ខ្លះ កំពុងពិចារណាក្នុងការទទួលយកជនរងគ្រោះប្រភេទផ្សេងទៀត។ អង្គការមួយដែលផ្តល់សេវាគាំទ្រដល់ស្ត្រី និង កុមារី បានពង្រីកកម្មវិធីរបស់ខ្លួនដើម្បីគាំទ្រដល់ជនរងគ្រោះបុរសដោយអំពើជួញដូរដើម្បីកេងប្រវញ្ច័កម្លាំងពលកម្ម។ មណ្ឌលប៉ាន់ប្រមាណមួយកំពុងបង្កើតគំរូកម្មវិធីថ្មីមួយក្នុងការធ្វើការប៉ាន់ប្រមាណយ៉ាងរហ័សលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រឡប់ពីប្រទេសផ្សេងៗ។ អង្គការផ្សេងទៀតកំពុងពិនិត្យមធ្យោបាយថ្មីដើម្បីស្វែងរកជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ព្រោះពួកគេបានរាយការណ៍ថាបញ្ហានៅតែមាន ហើយវាពិបាកក្នុងការកំណត់អត្តសញ្ញាណ។

### ៣.២.៧. តើមានការចំណាយប៉ុន្មានសម្រាប់សេវាគាំទ្រ?

នៅក្នុងការស្ទាបស្ទង់ជាមួយអ្នកផ្ដល់បទសម្ភាសន៏សំខាន់ៗដែលជាអាជ្ញាធររដ្ឋាភិបាល និងអ្នកផ្ដល់សេវាកម្ម អ្នកផ្ដល់ចំលើយត្រូវបានសុំអោយពណ៍នាអំពីការចំណាយរបស់សេវាគាំទ្រដែលផ្ដល់ឲ្យ ហើយថាតើមានការចំណាយណាផ្សេងទៀតដែលជនរងគ្រោះត្រូវចំណាយដោយខ្លួនឯងសម្រាប់សេវាគាំទ្រដែរ ឬទេ។ ក្នុងកំឡុងពេលនៃការសម្ភាសន៍ មានទិន្នន័យតិចតួចត្រូវបានប្រមូល ព្រោះអ្នកផ្ដល់ព័ត៌មានមិនមានព័ត៌មានថវិកានៅក្នុងដៃ។

ការស្ទាបស្ទង់ថវិកាសង្ខេបមួយផ្សេងទៀត ត្រូវបានផ្ញើតាមសារអេឡិចត្រូនិចទៅកាន់អ្នកផ្ដល់សេវាកម្ម ដើម្បីស្នើសុំពត៌មានថវិការ។ មានអង្គការចំនួន៥បានឆ្លើយតប ដែលក្នុងនោះមានអង្គការចំនួន៤ផ្ដល់សេវាគាំទ្រនៅមណ្ឌល ហើយអង្គការមួយទៀតផ្ដល់សេវាគាំទ្រនៅតាមសហគមន៍ដល់ជនរងគ្រោះដោយការរំលោភ។ អង្គការទាំងអស់តំណាងអោយអង្គការជាតិ និងអន្តរជាតិដែលផ្ដល់សេវាគាំទ្រនៅតាមសហគមន៍។

| **ការចំណាយប្រចាំឆ្នាំសម្រាប់អ្នកទទួលសេវាកម្មក្នុងម្នាក់** | | |
|---|---|---|
| | ការចំណាយទាបបំផុតក្នុងមួយឆ្នាំ | ការចំណាយខ្ពស់បំផុតក្នុងមួយឆ្នាំ |
| **ជម្រក** | ៤២០ដុល្លារ | ៤.៦៩៩ដុល្លារ |
| **ការប្រឹក្សាផ្នែកចិត្តសង្គម** | ៦០ដុល្លារ | ១.៧៥៥ដុល្លារ |
| **វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ** | ២៤០ដុល្លារ | ១.៣៨០ដុល្លារ |
| **ការអប់រំ** | ៦៥ដុល្លារ | ៦៦០ដុល្លារ |
| **ការធ្វើសមាហរណកម្មឡើងវិញ** | ១០០ដុល្លារ | ១.២៧០ដុល្លារ |

ការចំណាយសម្រាប់សេវាគាំទ្រដល់ជនរងគ្រោះមានលក្ខណៈខុសៗគ្នា។ អង្គការមួយចំនួនមានការចំណាយខ្ពស់លើប្រភេទនៃសេវាគាំទ្រដែលទាក់ទងនឹងអាទិភាព និងជំនាញនៃកម្មវិធីរបស់អង្គការ។ អង្គការដូចគ្នាមិនតែងតែមានការចំណាយខ្ពស់បំផុតសម្រាប់សេវាកម្មនោះទេ។ ឧទាហរណ៍ អង្គការដែលផ្ដល់ការប្រឹក្សាផ្នែកចិត្តសង្គមមានការចំណាយខ្ពស់បំផុតដោយសារមានការផ្ដោតយកចិត្តទុកដាក់លើការព្យាបាល និងមានអ្នកប្រឹក្សាបរទេស។ អង្គការដែលមានការចំណាយខ្ពស់បំផុតលើការធ្វើសមាហរណកម្មឡើងវិញគឺដោយសារវាជាកម្មវិធីដ៏សំខាន់សម្រាប់អង្គការ។

- មណ្ឌលចំណាយចាប់ពី ៤២០ដុល្លា ដល់ ៤៦៩៩ដុល្លា សម្រាប់ជនរងគ្រោះម្នាក់ដែលស្នាក់នៅក្នុងមណ្ឌលក្នុងរយៈពេលមួយឆ្នាំ។ មណ្ឌលដែលមានការចំណាយទាបភាគច្រើនមានទីតាំងនៅឆ្ងាយពីទីក្រុង ពីព្រោះមានការចំណាយទាបសម្រាប់អាគារ និងបុគ្គលិក។ មានតែការចំណាយសម្រាប់អ្នកថែទាំនៅក្នុងមណ្ឌលប៉ុណ្ណោះដែលបានដាក់បញ្ចូលក្នុងខ្ទង់ចំណាយសម្រាប់បុគ្គលិក។ មណ្ឌលដែលមានដី និងអាគារគ្រប់គ្រាន់មានការចំណាយទាប ប៉ុន្តែនៅមានការខ្វះខាតផ្នែកសម្ភារៈផ្ទះបាយ និងបង្គន់។ មណ្ឌលដែលមានការចំណាយខ្ពស់ គឺជាមណ្ឌលដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ

ហើយមានការចំណាយខ្ពស់លើផ្នែកសម្ភារៈ និងឧបករណ៍ផ្សេងៗដែលឆ្លើយតប និងលើសពីការកំណត់នៃបទដ្ឋានអប្បបរមា និងបទដ្ឋានអន្តរជាតិ។ ជាទូទៅមណ្ឌលទាំងនេះមានទីប្រឹក្សាជនជាតិបរទេស (បានបញ្ចូលការចំណាយផ្សេងៗ) មានប្រព័ន្ធវីដេអូតាមដាន២៤ម៉ោង មានសម្ភារៈបរិក្ខាគុទូគ្រប់គ្រាន់ និងមានសម្ភារៈបរិក្ខាផ្សេងៗដូចជា បង្គន់ ផ្កាឈូកងូតទឹក និងសម្ភារៈបរិក្ខាសម្រាប់គេង។

- ការប្រឹក្សាផ្នែកចិត្តសង្គមមានការចំណាយចាប់ពី ៦០ដុល្លា ដល់ ១៧៥៥ដុល្លា សម្រាប់ជនរងគ្រោះម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ មណ្ឌលដែលមានការចំណាយទាបលើផ្នែកនេះគឺជាមណ្ឌលដែលមានតែបុគ្គលិកជាតិ និងអ្នកប្រឹក្សាអន្តរជាតិដែលធ្វើការមិនពេញម៉ោង។ អង្គការមួយចំនួនមានការចំណាយខ្ពស់ដោយសារមានបុគ្គលិកជំនាញដែលទទួលបានការបណ្តុះបណ្តាល មានទីប្រឹក្សា និងអ្នកគ្រប់គ្រងជាជនជាតិបរទេស។
- វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមានការចំណាយចាប់ពី ២៤០ដុល្លា ដល់ ១៣៦០ដុល្លាសម្រាប់ជនរងគ្រោះម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ អង្គការមួយចំនួនមានការចំណាយទាបជាងលើផ្នែកនេះដោយសារតែអង្គការបានផ្តល់នូវថវិការដល់ជនងរគ្រោះឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដោយខ្លួនឯង ឬបានកំហិតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈខ្លះៗនៅនឹងកន្លែង។ ផ្ទុយមកវិញ អង្គការមួយចំនួនផ្សេងទៀតមានការចំណាយខ្ពស់ ដោយសារអង្គការបានផ្តល់នូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានលក្ខណៈស៊ីជម្រៅ និងទូលំទូលាយ ព្រមទាំងមានជម្រើសផ្សេងៗនៃការបណ្តុះបណ្តាលជាច្រើនផងដែរ។
- ការធ្វើសមាហរណកម្មឡើងវិញមានការចំណាយចាប់ពី ១០០ដុល្លា ដល់១២៧០ដុល្លា សម្រាប់ជនរងគ្រោះម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ អង្គការមួយចំនួនមានការចំណាយទាបក្នុងការធ្វើសមាហរណកម្មឡើងវិញដល់ជនរងគ្រោះ ដោយសារតែអង្គការបានផ្តល់នូវការគាំទ្រមានកម្រិតសម្រាប់ជួយឲ្យជនរងគ្រោះអាចត្រឡប់ទៅរស់នៅក្នុងសហគមន៍ដើមរបស់គេវិញ។ ការគាំទ្រទាំងនេះជាទូទៅរួមមានការចំណាយលើការធ្វើដំណើរ និងថវិការមួយចំនួនតូចដើម្បីជួយឲ្យជនរងគ្រោះអាចប្រកបមុខរបរដើម្បីបង្កើតប្រាក់ចំណូលដោយខ្លួនឯងបាន។ ផ្ទុយមកវិញ អង្គការមួយចំនួនផ្សេងទៀតបានធ្វើការចំណាយខ្ពស់លើកម្មវិធីសមាហរណកម្មឡើងវិញ ពីព្រោះអង្គការបានបញ្ជូនបុគ្គលិកឲ្យជួយក្នុងដំណើការនៃការធ្វើសមាហរណកម្ម ថ្លៃធ្វើដំណើរសម្រាប់ជនរងគ្រោះក្នុងការវិលត្រឡប់ទៅសហគមន៍របស់ពួកគេ ការចំណាយលើការចុះតាមដាន និងថវិការសម្រាប់ធ្វើជាដើមទុនដើម្បីបង្កើតមុខរបរផ្សេងៗ។

មិនមានអង្គការណាមួយគិតប្រាក់ពីជនរងគ្រោះដើម្បីការទទួលសេវាគាំទ្រនោះទេ ប៉ុន្តែមានសេវាគាំទ្រមួយចំនួនទាមទាឲ្យមានការចូលរួមថ្លៃចំណាយពីជនរងគ្រោះ។ សេវាគាំទ្រដែលទាមទាឲ្យមានការចូលរួមក្នុង

ការចំណាយពីជនរងគ្រោះ ជាទូទៅគឺសេវាគាំទ្រដែលទាក់ទងនិងផ្នែកច្បាប់។ ការចំណាយទាំងនេះធ្វើឡើងនៅពេលមានការគិតប្រាក់មិនផ្លូវការពីនគរបាល ការចំណាយក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ និងការចំណាយសម្រាប់ការធ្វើដំណើរ។

មានការចំណាយបន្ថែមមួយចំនួនដែលចាំបាច់ត្រូវយកមកពិចារណាដើម្បីបង្កើតសេវាគាំទ្រដល់ជនរងគ្រោះនៅតាមសហគមន៍ឲ្យមានប្រសិទ្ធិភាពដូចជា៖

- ការចំណាយលើកការធ្វើដំណើររបស់បុគ្គលិកដើម្បីទៅសួរសុខទុក្ខជនរងគ្រោះនៅផ្ទះរបស់ពួកគេដើម្បីធ្វើការប៉ាន់ប្រមាណ ការប្រឹក្សាយោបល់ ការគ្រប់គ្រងករណី និងការប្រឹក្សាយោបល់ដល់ក្រុមគ្រួសារ ក៏ដូចជាការបង្កើតផែនការសុវត្ថិភាពសហគមន៍សម្រាប់ជនរងគ្រោះដែលនឹងត្រឡប់ទៅស្នាក់នៅផ្ទះវិញ និង/ឬជួលគ្រូបង្រៀនដើម្បីជួយពួកគេក្នុងការគាំទ្រជនរងគ្រោះនៅពេលពួកគេត្រឡប់ទៅសាលាវិញ។ល។
- ការចំណាយលើការធ្វើដំណើរសម្រាប់ជនរងគ្រោះដើម្បីជួបមេធាវី ទៅរកសេវាកម្មវិជ្ជសាស្ត្រសម្រាប់ការព្យាបាល ទៅរកអង្គការសម្រាប់ទទួលការប្រឹក្សាយោបល់ ឫជំនួបផ្សេងៗ និងការចំណាយសម្រាប់សមាជិកក្រុមគ្រួសារមកសួរសុខទុក្ខនៅមណ្ឌល និងការចំណាយសម្រាប់ឲ្យពួកគេទៅលេងផ្ទះដើម្បីសួរសុខទុក្ខក្រុមគ្រួសារ។
- គំនិតផ្តួចផ្តើម និងបន្តការសាងសមត្ថភាពសម្រាប់បុគ្គលិក។
- បន្តអភិបាលកិច្ចដែលមានគុណភាពខ្ពស់៖ មានបុគ្គលិកជាតិតិចតួចមានសមត្ថភាពអាចផ្តល់នូវអភិបាលកិច្ចលើការងារសង្គម។ ការងារសង្គមគឺថ្មីនៅក្នុងប្រទេសនេះ ហើយមានមនុស្សតិចតួចដែលមានពេលគ្រប់គ្រាន់ក្នុងការបង្កើនសមត្ថភាពសម្រាប់ប្រភេទអភិបាលកិច្ចជំនាញនេះ ហើយពេលខ្លះទាមទាអោយមានទីប្រឹក្សាបរទេស។
- ការចំណាយលើសេវាសុខភាពសម្រាប់ព្យាបាលជម្ងឺ និងការរងរបួសដែលពាក់ព័ន្ធនឹងការរងគ្រោះរបស់ពួកគេ។
- ការចំណាយផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងការទៅតុលាការ។
- ការចំណាយលើការពិនិត្យនិងវាយតម្លៃ ដើម្បីវាយតម្លៃដំណើរការ។

## ៣.៣. កង្វះខាតនិងបញ្ហាប្រឈម

### កង្វះខាតក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះអោយច្បាស់លាស់

មានកង្វះខាតពីភាពស៊ីសង្វាក់គ្នាក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ មាន ៨០% នៃអង្គការដែលបានសិក្សបាននិយាយថាពួកគេបានប្រើប្រាស់សេចក្តីណែនាំ ឫឧករណ៍ស្វែងរកព័ត៌មានក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយ

អំពើជួញដូរ។ អង្គការទាំងនេះបានប្រើប្រាស់សេចក្តីណែនាំប៉ាឡឺម៉ូ **“PalermoProtocol”**[17] ដែលអាចជាឈ្មោះ ឬដោយការលើកយកធាតុផ្សំមួយចំនួននៅក្នុងសេចក្តីណែនាំដែលកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ។ ប៉ុន្តែទោះបីជាប្រើប្រាស់វិធីសាស្ត្រនេះក៏ដោយ ក៏នៅតែមានភាពមិនដូចគ្នានៅពេលអនុវត្តសេចក្តីណែនាំនេះសម្រាប់ប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

### ភាពពិបាកក្នុងការទទួលសេវាគាំទ្រនៅសហគមន៍កំណើតរបស់ជនរងគ្រោះ

សព្វថ្ងៃនេះសេវាគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្សភាគច្រើននៅក្នុងប្រទេសកម្ពុជាភាគច្រើនត្រូវបានបង្កើតឡើងនៅក្នុងទីប្រជុំជនដែលជាទីសដៅនៃអំពើជួញដូរមនុស្ស។ សេវាគាំទ្រភាគច្រើនមាននៅទីក្រុងភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកោះកុង និងខេត្តសៀមរាប។ ស្រុកកំណើតរបស់ជនរងគ្រោះរមែងឆ្ងាយពីកន្លែងផ្តល់សេវាកម្មទាំងនេះ។

ការផ្តល់នូវសេវាគាទ្រនៅតំបន់គោលដៅ គឺដើម្បីជួយក្នុងការជួយសង្គ្រោះ ការកំណត់អត្តសញ្ញាណ និងការប៉ាន់ប្រមាណពីតម្រូវការនៃសេវាគាំទ្រសម្រាប់ជនរងគ្រោះ ប៉ុន្តែការអនុវត្តបែបនេះបានបង្ហាញនូវឧបសគ្គសម្រាប់ការផ្តល់សេវាគាំទ្រដែលមានរយៈពេលវែងដូចជា ការស្តារសម្បទា និងការធ្វើសមាហរណកម្មឡើងវិញ។ អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលរាយការណ៍ថាមានការលំបាកក្នុងការធ្វើការប៉ាន់ប្រម៉ាណចំពោះគ្រួសារដែលមានសាច់ញាតិច្រើន ការលំបាកក្នុងការគាំទ្រលើការធ្វើសមាហរណកម្មឡើងវិញ និងការលំបាកក្នុងការឲ្យជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌល ទៅសួសុខទុក្ខគ្រួសាររបស់ពួកគេដោយសារតែសហគមន៍កំនើតរបស់ពួកគេនៅឆ្ងាយពីមណ្ឌល ហើយផ្លូវថ្នល់មានការលំបាកក្នុងការធ្វើដំណើរ។ ជនរងគ្រោះដោយអំពើជួញដូរមនុស្សរាយការណ៍ថាពួកគេមានការពេញចិត្តខ្លាំងចំពោះសេវាគាំទ្រផ្សេងៗ ដែលបានផ្តល់ ប៉ុន្តែចំពោះក្រុមជនរងគ្រោះដែលបានសម្ភាសន៍នៅក្នុងក្រុមពិភាក្សាបានបញ្ជាក់ថាពួកគេចង់បានសេវាគាំទ្រនៅតាមសហគមន៍ជាងនៅមណ្ឌល។

### សេវាកម្មមិនមានភាពជោគជ័យក្នុងការធ្វើអោយសុវត្ថិភាពសេដ្ឋកិច្ចរបស់ជនរងគ្រោះមានភាពនឹងនរ

---

[១]Palermo Protocol: នៅក្នុងឆ្នាំ២០០០ អង្គការសហប្រជាជាតិត្រូវបានសម្រេចនូវការយល់ព្រមលើនិយមន័យ ដែលកំណត់ធាតុផ្សំសំខាន់ចំនួនបីសម្រាប់អំពើជួញដូរមនុស្ស៖ **សកម្មភាព មធ្យោបាយ** និង**គោលបំណង**។ សកម្មភាពមួយ រួមបញ្ចូល សកម្មភាពជាច្រើនដូចជា “ការជ្រើសរើសការបញ្ជូន ការផ្ទេរ ការបង្ខាំង ឬការទទួលនរណាម្នាក់”។ មធ្យោបាយរួមមានការប្រើប្រាស់ “ការគំរាមកំហែង ឬប្រើប្រាស់កំលាំងបាយ បង្ខិតបង្ខំ ចាប់ពង្រត់ ក្លែងបន្លំ បោកបញ្ឆោត ប្រើអំណាចរំលោភបំពាន ឬទៅលើអ្នកដែលទុនខ្សោយ ឬផ្តល់ប្រាក់ ឬអត្ថប្រយោជន៍”។ គោលបំណងគឺមួយក្នុងចំណោមការកេងប្រវ័ញ្ចដែលមានឥទ្ធិពលជាងគេ រួមមាន “ការប្រព្រឹត្តអំពើពេស្យាចារទៅ លើអ្នកផ្សេង ការកេងប្រវ័ញ្ចផ្លូវភេទ ការបង្ខំអោយធ្វើការ ទាសភាព ឬការប្រព្រឹត្តស្រដៀងនេះ ការវះកាត់យកសរីរាង្គ ឬប្រភេទផ្សេងទៀតនៃការកេងប្រវ័ញ្ច”។

http://www.palermoprotocol.com/general/the-palermo-protocol

ភាពក្រីក្របង្កើនភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាចឈានទៅរកភាពរងគ្រោះម្តងទៀត។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ អ្នកផ្តល់សេវាគាំទ្រ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស បានបង្ហាញភាពចាំបាច់ក្នុងការរកប្រាក់ចំណូលឲ្យបានឆាប់រហ័សថាជាឧបសគ្គ ឬតម្រូវការដ៏ចំបងមួយ។ ក្រុមទាំងពីរនេះក៏បានបង្ហាញពីការជម្រុញពីក្រុមគ្រួសារដើម្បីទៅរកប្រាក់យ៉ាងឆាប់រហ័ស។ មូលហេតុទាំងនេះហើយ ដែលធ្វើឲ្យជនរងគ្រោះខ្លះបដិសេធចំពោះការផ្តល់សេវាគាំទ្រនៅក្នុងមណ្ឌល ឬបដិសេធការចូលរួមនៅក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជនរងគ្រោះទាំងនៅក្នុងកិច្ចពិភាក្សាក្រុម និងនៅក្នុងការសម្ភាសន៍ បានបង្ហាញការព្រួយបារម្ភអំពីភាពដែលអាចប្រើប្រាស់បានចំពោះវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដែលពួកគេកំពុងទទួលបាន។ ពួកគេមានការបារម្ភចំពោះលទ្ធភាពក្នុងការយកជំនាញដែលទទួលបានពីវគ្គបណ្តុះបណ្តាលដើម្បីរកប្រាក់ចំណូលនៅក្នុងសហគមន៍កំណើតរបស់ពួកគេ ហើយក៏មានការបារម្ភផងដែរចំពោះធនធានដែលគេមានដើម្បីយកមកប្រកបមុខរបរឲ្យស្របទៅតាមជំនាញដែលពួកគេទទួលបាន។ អ្នកខ្លះបាននិយាយថាវគ្គបណ្តុះបណ្តាលមានលក្ខណៈលំបាកផងដែរ។

**កង្វះធនធានក្នុងការអនុវត្តការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញ**

ការផ្តល់នូវសេវាគាំទ្រក្នុងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍កំណើតរបស់ជនរងគ្រោះត្រូវបានរកឃើញថាជាចំនុចខ្សោយរបស់អង្គការជាច្រើនពីព្រោះសេវាគាំទ្រភាគច្រើនគឺមានតែនៅកន្លែងគោលដៅសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ ហើយនៅឆ្ងាយពីសហគមន៍កំណើតរបស់ជនរងគ្រោះ។ កត្តាទាំងនេះ ធ្វើអោយអង្គការផ្តល់សេវាគាំទ្រនៅសហគមន៍ព្យាយាមផ្តល់ការគាំទ្រសម្រាប់ការធ្វើសមាហរណកម្មឡើងវិញពីកន្លែងឆ្ងាយ ដែលនេះជាមូលហេតុធ្វើឲ្យមានការកើនឡើងនូវការចំណាយលើពេលវេលារបស់បុគ្គលិក និងការចំណាយសម្រាប់ការធ្វើដំណើរ។ អង្គការខ្លះខ្វះបុគ្គលិកដែលមានជំនាញ និងធនធានដែលត្រូវការសម្រាប់ផ្តល់សេវាគាំទ្រនៅតាមសហគមន៍។

ម៉្យាងវិញទៀត ពុំសូវមានការគាំទ្រណាមួយត្រូវបានធ្វើឡើងដើម្បីជួយដល់គ្រួសាររបស់ជនរងគ្រោះនោះទេ ដូចច្នេះជនរងគ្រោះមិនគួរត្រូវបានបញ្ជូនទៅកាន់ស្ថានភាពដែលងាយរងគ្រោះដដែលឡើយ ពីព្រោះវាអាចធ្វើឲ្យពួកគេងាយប្រឈមមុខនឹងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស។ ចំពោះជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលក្នុងរយៈពេលវែង ពួកគេត្រូវបានកាត់ផ្តាច់ពីការគាំទ្រនៅក្នុងសហគមន៍ ហើយមានការពិបាកក្នុងការវិលត្រឡប់ទៅវិញ។

ក្រសួងសង្គមកិច្ច តាមរយៈការិយាល័យស្រុក (DoSVY) មានតួនាទីសំខាន់ក្នុងការធ្វើសមាហរណកម្មជនរងគ្រោះគ្រប់ប្រភេទឲ្យត្រឡប់ទៅកាន់សហគមន៍ដើមរបស់ពួកគេវិញ។ ជាក់ស្តែងក្រសួងមានសេចក្តីណែនាំជាច្រើនក្នុងការធ្វើសមាហរណកម្មឡើងវិញដល់ជនរងគ្រោះ ហើយថ្មីៗនេះដោយមានការគាំទ្រពីអង្គការ

យូនីសេហ្វ (UNICEF) ក្រសួងបានកំណត់យកកម្មវិធីនេះដើម្បីធ្វើការពិនិត្យ និងបានកំពុងបង្កើតគណៈកម្មធិការមួយដើម្បីពិនិត្យឡើងវិញ និងសម្របសម្រួលសេចក្តីណែនាំផ្សេងៗនៃការធ្វើសមាហរណកម្មឡើងវិញ។

ការិយាល័យសង្គមកិច្ចបានបង្កើតទម្រង់ការដែលមានគុណភាព ប៉ុន្តែខ្វះនូវធនធានក្នុងការអនុវត្តការងារនេះអោយមានប្រសិទ្ធិភាព។ ដូចគ្នានេះដែរ អង្គការផ្តល់សេវាគាំទ្រនៅសហគមន៍ដែលជាដៃគូរសហការរបស់ក្រសួងក្នុងការអនុវត្តការងារនេះមិនមានការិយាល័យនៅក្នុងសហគមន៍ទេ ដូចច្នេះមានអង្គការជាច្រើនបានកំពុងបង្កើតកម្មវិធីថ្មីមួយនេះ និងកំពុងពិនិត្យលើមធ្យោបាយក្នុងការបំពេញកង្វះខាតទាំងនេះ។

## ការកាត់ទោសមិនមានភាពស៊ីសង្វាក់គ្នា

អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះក៏បានបង្ហាញពីបញ្ហាប្រឈមនៅក្នុងប្រព័ន្ធច្បាប់ផងដែរ ដែលជាកត្តាធ្វើឲ្យមានការរារាំង ឬបង្អាក់ក្នុងការធ្វើការកាត់ទោសជនល្មើស។ បញ្ហាប្រឈមទាំងនេះមានដូចជា ករណីនៅតុលាការត្រូវបានច្រានចោលជាញឹកញាប់ ហើយភ័ស្តុតាងភាគច្រើនមិនមានលក្ខណៈគ្រប់គ្រាន់។ ម៉្យាងវិញទៀត ការយកថ្លៃឈ្នួល និងការចំណាយផ្សេងៗទាក់ទងនឹងការងារកាត់ទោសជនល្មើសបានធ្វើឲ្យជនរងគ្រោះមិនអាចយកជនល្មើសទៅធ្វើការកាត់ទោសបាន។ របាយការណ៍នេះមិនផ្តោតលើការអន្តរាគមន៍ផ្នែកនេះទេ ប៉ុន្តែវាក៏ត្រូវបានរាប់បញ្ចូលដោយសារតែបញ្ហាទាំងនេះត្រូវបានរកឃើញនៅក្នុងការសិក្សស្រាវជ្រាវ។

## គុណភាពនៃសេវាកម្មមិនដូចគ្នា

កង្វះខាតមួយដែលត្រូវបានលើកឡើងម្តងហើយម្តងទៀត គឺគុណភាពនៃសេវាគាំទ្រដែលផ្តល់ដល់ជនរងគ្រោះ។ អង្គការមួយចំនួនបានដឹងអំពីបទដ្ឋានអប្បបរមា និងកំពុងធ្វើការដើម្បីសម្រេចការងារនេះ។ ប៉ុន្តែត្រូវកត់សម្គាល់ថាបទដ្ឋានអប្បបរមាគឺមានកម្រិត "**អប្បបរមា**" ហើយជាទូទៅមិនបានបញ្ជាក់ពីគុណភាពនៃសេវាគាំទ្រដែលផ្តល់ដល់ជនរងគ្រោះនោះទេ។ អ្នកផ្តល់សេវាគាំទ្រក៏បានបង្ហាញពីការព្រួយបារម្ភចំពោះកម្រិតគុណភាពនៃសេវាគាំទ្រដែលផ្តល់ដោយអ្នកផ្តល់សេវាគាំទ្រដ៏ទៃទៀត។

អង្គការមួយចំនួនមិនអាចផ្តល់តម្រូវការមូលដ្ឋានដល់ជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលដូចជាអាហារ សំលៀកបំពាក់ និងគ្រែកេង ដោយសារតែថវិការមានកំណត់។ ឧទាហរណ៍មួយទៀតដែលត្រូវបានលើកឡើងជាញឹកញាប់គឺគុណភាពនៃការគាំទ្រ និងប្រឹក្សាផ្នែកចិត្តសង្គម។ ការងារសង្គមគឺជាការងារមួយដែលថ្មីនៅក្នុងប្រទេសកម្ពុជា ហើយមានបុគ្គលិកជាតិតិចតួចណាស់ដែលមានសមត្ថភាពក្នុងការអនុវត្តការងារនេះឲ្យមានភាពជោគជ័យ។ មិនមានការឯកភាពច្បាស់លាស់ណាមួយត្រូវបានធ្វើឡើងដើម្បីកំណត់យកគំរូនៃការប្រឹក្សាយោបលដ៍ប្រសើរបំផុតដើម្បីផ្តល់ដល់ជនរងគ្រោះនោះទេ ក៏ប៉ុន្តែវាមានលំដាប់ផ្សេងៗគ្នានៃគុណភាពសេវាគាំទ្រសម្រាប់ផ្តល់ដល់ជនរងគ្រោះ។ គំរូល្អៗទាក់ទងនឹងគុណភាពនៃសេវាគាំទ្រដល់ជនរងគ្រោះគួរតែត្រូវបានចម្លងតាមដើម្បីអនុវត្តតាមរយៈភាពជាដៃគូរ និងវគ្គបណ្តុះបណ្តាល។

### សមត្ថភាពរបស់អង្គការពេលខ្លះនៅមានកម្រិត

អង្គការមួយចំនួនបានបង្ហាញថាសមត្ថភាពរបស់បុគ្គលិកមួយចំនួននៅមានកម្រិត និងមានបុគ្គលិកមិនគ្រប់គ្រាន់ បុគ្គលិកខ្លះមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ហើយបុគ្គលិកត្រូវបានគេរំពឹងទុកថានឹងធ្វើការច្រើនម៉ោងដោយគ្មានពេលឈប់សម្រាក។ ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញផងដែរថាបុគ្គលិកត្រូវការការបណ្តុះបណ្តាលជំនាញទាក់ទងនឹងវិធីសាស្រ្តផ្សេងៗក្នុងការធ្វើអន្តរាគមន៍។

### កង្វះខាតសម្រាប់ជនរងគ្រោះមួយចំនួន

អ្នកផ្តល់សេវាគាំទ្រជនរងគ្រោះ និងអាជ្ញាធររដ្ឋាភិបាលក៏បានបង្ហាញពីកង្វះខាតទីកន្លែងក្នុងការបញ្ជូនជនរងគ្រោះមួយចំនួនទៅរកសេវាគាំទ្រផ្សេងៗ។ បញ្ហាដែលបានកត់សម្គាល់មានដូចជា៖

- សេវាគាំទ្រសម្រាប់ជនរងគ្រោះដែលជាបុរស និងក្មេងប្រុសមានចំនួនតិចតួច ទោះបីជាចំនួនជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលជាបុរស និងក្មេងប្រុសមានចំនួនច្រើនគួរឲ្យកត់តសម្គាល់ក៏ដោយ។
- ពុំសូវមានអ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលមានពិការភាព និងអ្នកដែលមានជម្ងឺផ្លូវចិត្ត ឬបញ្ហាការបំពានផ្សេងៗ។

## ៣.៤. ចំនុចខ្លាំង និងចំនុចខ្សោយ រវាងសេវាគាំទ្រជនរងគ្រោះនៅមណ្ឌល និងនៅសហគមន៍

នៅក្នុងដំណើរការនៃកិច្ចសម្ភាសន៍ អ្នកផ្តល់សេវាគាំទ្រ និងអាជ្ញាធររដ្ឋាភិបាលត្រូវបានសួរពីគំរូកម្មវិធី (មណ្ឌល ឬ សហគមន៍) នឹងសុំអោយពណ៌នាអំពីចំនុចខ្លាំង និងចំនុចខ្សោយរបស់ពួកគេ។ អង្គការជាច្រើនមិនបានឃើញគំរូសេវាគាំទ្រប្រភេទណាមួយដែលសមស្រប ទាំងនៅមណ្ឌល ឬនៅសហមគន៍។

តម្រូវការសម្រាប់សេវាគាំទ្រភាគច្រើនត្រូវបានពណ៌នាជាលក្ខណៈបន្តបន្ទាប់គ្នាដូចជា ការកំណត់អត្តសញ្ញាណ អន្តរាគមន៍វិបត្តិ និងការថែទាំក្រោយពេលជួយសង្គ្រោះដែលរួមមានការប៉ាន់ប្រម៉ាណការត្រឡប់ទៅសហគមន៍ ឬបញ្ជូនទៅមណ្ឌល (អាស្រ័យលើសុវត្ថិភាព និងការប៉ាន់ប្រម៉ាណធនធាន) ការផ្តល់សេវាកម្មការគាំទ្រផ្សេងៗ និងការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ពេលមានសុវត្ថិភាព និង/ឬមានជាផែនការណាមួយ។ ជាក់ស្តែងអ្នកផ្តល់សេវាគាំទ្រសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវការសេវាគាំទ្រដែលអាស្រ័យលើស្ថានភាពបុគ្គល រួមមាន សុវត្ថិភាព និងធនធាន និងការអនុញ្ញាតិឲ្យជនរងគ្រោះអាចធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញពេលមានសុវត្ថិភាព និងសមស្របសម្រាប់ជនរងគ្រោះម្នាក់ៗ។

សេចក្ដីសង្ខេបនៃចំនុចខ្លាំង និងចំនុចខ្សោយនៃគំរូនីមួយៗមានដូចខាងក្រោមៈ

| | មណ្ឌល | សហគមន៍ |
|---|---|---|
| ចំនុចខ្លាំង | មណ្ឌលផ្ដល់នូវកន្លែងដែលមានសុវត្ថិភាព សម្រាប់កុមារី និងស្ត្រី ហើយពួកគេត្រូវបានការពារពីការរំលោភបំពាន | ជនរងគ្រោះភាគច្រើនចង់រស់នៅជាមួយគ្រួសារ ឬនៅក្នុងសហគមន៍។ |
| | គ្រួសារខ្លះបានចូលដៃក្នុងការប្រព្រឹត្តការបំពានលើអនីតិជន ហើយករណីបែបនេះក៏ធ្លាប់កើតមានជារឿយៗផងដែរ។ ដូចច្នេះ វាចាំបាច់ត្រូវតែធ្វើការប៉ាន់ប្រមាណដ៏ម៉ត់ចត់មួយលើស្ថានភាពគ្រួសារមុនពេលបញ្ជូនជនរងគ្រោះដែលជាកុមារត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ពួកគេវិញ។ មណ្ឌលផ្ដល់នូវកន្លែងស្នាក់នៅដ៏មានសុវត្ថភាពសម្រាប់ជនរងគ្រោះនៅពេលដែលពួកគេជួបនូវករណីដូចខាងលើ។ ជនរងគ្រោះដែលជាកុមារនឹងមិនត្រូវបានបញ្ជូនត្រឡប់ទៅក្រុមគ្រួសារវិញទេ លុះត្រាតែគ្រប់បញ្ហាដែលបង្កគ្រោះថ្នាក់ដល់ពួកគេទាំងអស់ត្រូវបានដោះស្រាយ។ | សេវាគាំទ្រនៅសហគមន៍ជួយឲ្យការធ្វើសមាហរណកម្មបានជោគជ័យទៅក្នុងសហគមន៍។ |
| | ងាយស្រួលក្នុងការផ្ដល់សេវាគាំទ្រផ្សេងៗ ដូចជា សេវាគាំទ្រផ្នែកច្បាប់ ការព្យាបាលដល់ជនរងគ្រោះជាក្រុម ដែលអាចជួយកាត់បន្ថយការចំណាយលើការធ្វើដំណើរ។ | ជនរងគ្រោះដោយអំពើជួញដូរដើម្បីកម្លាំងពលកម្មចង់ត្រឡប់ទៅសហគមន៍កំណើតរបស់ពួកគេវិញភ្លាមៗ ព្រោះពួកគេមានតម្រូវការខ្ពស់ក្នុងការរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ហើយពួកគេមានការប៉ះទង្គិចផ្លូវចិត្តគឺខុសគ្នាពីជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ។ |
| | ក្រៅពីការផ្ដល់នូវជម្រកសុវត្ថភាព មណ្ឌលក៏បានផ្ដល់សេវាគាំទ្រក្នុងការស្ដារសម្បទារយៈពេលវែងដូចជា ការប្រឹក្សាយោបល់ វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ការអនុវត្តល្អជាលក្ខណៈអន្តរជាតិបានបង្ហាញថាការថែទាំនៅក្នុងមណ្ឌលគួរតែជាជម្រើសចុងក្រោយសម្រាប់ជម្រើសក្នុងការថែទាំ ព្រោះវាអាចរំលោភសិទ្ធិមនុស្ស និងធ្វើឲ្យជនរងគ្រោះរស់នៅក្នុងទីកន្លែងមិនមានលក្ខណៈធម្មជាតិ។ |

| | | |
|---|---|---|
| ចំណុចខ្សោយ | ពេលខ្លះ នៅពេលដែលជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរយៈពេលយូរ ពួកគេបាត់បង់ទំនាក់ទំនង ជាមួយក្រុមគ្រួសារ និងសហគមន៍ ហើយជួប ឧបសគ្គខ្លាំងពេលធ្វើសមាហរណកម្មឡើងវិញ។ | នៅក្នុងសហគមន៍ជាច្រើន មានកង្វះខាតសេវាគាំទ្រដើម្បីធ្វើសមាហរណកម្មឡើងវិញឲ្យបានជោគជ័យ។ |
| | សេវាគាំទ្រនៅតាមមណ្ឌលភាគច្រើនមានទីតាំងចំបងនៅតំបន់គោលដៅសម្រាប់អំពើជួញដូរ ហើយមិនមាននៅក្នុងសហគមន៍កំណើតរបស់ជនរងគ្រោះឡើយ ដែលជាបញ្ហាធ្វើឲ្យពួកគេមានការពិបាក និងចំណាយច្រើនក្នុងការទំនាក់ទំនងជាមួយក្រុមគ្រួសារ។ ជនរងគ្រោះដោយអំពើជួញដូរពលកម្មមិនចង់រស់នៅក្នុងមណ្ឌលទេ ហើយជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទចង់ត្រឡប់ទៅរស់នៅសហគមន៍វិញនៅពេលមានសុវត្ថិភាព។ | វាមិនមានសុវត្ថិភាពសម្រាប់កុមារ ឬស្ត្រីក្នុងការត្រឡប់ទៅសហគមន៍របស់ពួកគេ ព្រោះអ្នកប្រព្រឹត្តល្មើសអាចជាសមាជិកគ្រួសារ ឬសហគមន៍។ |
| | មណ្ឌលមិនអាចផ្តល់នូវការថែទាំជាលក្ខណៈបុគ្គលដែលក្រុមគ្រួសារអាចផ្តល់ជូនបាន។ | អង្គការភាគច្រើនដែលផ្តល់នូវសេវាគាំទ្រលើការធ្វើសមាហរណកម្មជនរងគ្រោះទៅសហគមន៍វិញមិនមានការិយាល័យនៅក្បែរសហគមន៍ជនរងគ្រោះទេ។ |
| | មានការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា មានអត្រាខ្ពស់នៃការបំពាននៅក្នុងមណ្ឌល ដែលអាចធ្វើឲ្យអ្នកស្នាក់នៅក្នុងមណ្ឌលក្លាយជាជនរងគ្រោះម្តងទៀត។ | ជនរងគ្រោះអាចនឹងរងគ្រោះដោយអំពើជួញដូរម្តងទៀតនៅក្នុងសហគមន៍ប្រសិនបើពួកគេមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ ឬពុំមានការគាំទ្រផ្សេងៗនោះទេ។ |

### ៣.៥. ភាពពេញចិត្តរបស់ជនរងគ្រោះចំពោះការផ្តល់សេវាគាំទ្រ

ជនរងគ្រោះត្រូវបានសួរនៅក្នុងកិច្ចពិភាក្សាក្រុម និងនៅក្នុងការស្ទាបស្ទង់មតិនៃភាពពេញចិត្តរបស់ជនរងគ្រោះម្នាក់ៗទៅលើសេវាគាំទ្រដែលពួកគេបានទទួល។ លទ្ធផលទាំងស្រុងនៃការស្ទាបស្ទង់មតិនៃភាពពេញចិត្តរបស់ជនរងគ្រោះមាននៅក្នុងរបាយការណ៍សូចនាករទិន្នន័យជាមូលដ្ឋានឆ្នាំ២០១២។

ជាទូទៅ ជនរងគ្រោះដែលត្រូវបានសម្ភាសន៍មានការពេញចិត្តជាខ្លាំងចំពោះសេវាគាំទ្រដែលពួកគេទទួលបាន ទោះបីជានៅពេលមានចំលើយវិជ្ជមានដែលបានគិតទុកមានភាពលំអៀងទៅលើការពេញចិត្តកម្រិត

ខ្ពស់ក៏ដោយ។ ជនរងគ្រោះមួយចំនួនតូចបានរាយការណ៍ថាពួកគេមិនមានការពេញចិត្តចំពោះប្រភេទនៃសេវាគាំទ្រមូលដ្ឋានមួយចំនួន។ នៅកន្លែងខ្លះ សំលៀកបំពាក់ អាហារ ការអប់រំ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានលើកឡើងថាជាសេវាគាំទ្រដែលមានការពេញចិត្តតិចតួច ឬពុំមានការពេញចិត្តតិចតួចចំពោះជនរងគ្រោះមួយចំនួនតូចដែលបានសម្ភាសន៍។ អ្នកខ្លះបានលើកឡើងពីបញ្ហាទាក់ទងនឹងលក្ខខណ្ឌរបស់អគារឬការគេង។

សេវាគាំទ្រមួយទៀតដែលជនរងគ្រោះរាយការណ៍ថាមានការពេញចិត្តតិចតួចគឺការចូលរួម។ ជនរងគ្រោះភាគច្រើន មានអារម្មណ៍ថាពួកគេមិនមានជម្រើសសម្រាប់អនាគត ប៉ុន្តែអ្នកខ្លះមានអារម្មណ៍ថាពួកគេមិនអាចបដិសេធនឹងសេវាគាំទ្រដែលផ្តល់ឲ្យ ហើយអ្នកខ្លះទៀតមានអារម្មណ៍ថាពួកគេមានការគ្រប់គ្រងតិចតួចចំពោះបរិស្ថានរស់នៅ និងសមត្ថភាពក្នុងការចាកចេញពីមណ្ឌល សូម្បីតែមនុស្សពេញវ័យ។

ជនរងគ្រោះក៏បានរាយការណ៍ដែរថាពួកគេមានការពេញចិត្តខ្លះៗចំពោះការដាក់ពិន័យនៅក្នុងមណ្ឌល។ ពុំមាននណាលើកឡើងពីការទណ្ឌកម្មលើរូបរាងកាយទេ ប៉ុន្តែជនរងគ្រោះជាច្រើននាក់បានលើកឡើងថាពួកគេមានការពេញចិត្តតិចតួចចំពោះការដាក់ពិន័យន័យប្រើប្រាស់នៅក្នុងមណ្ឌល។

នៅក្នុងកិច្ចពិភាក្សាក្រុម ជនរងគ្រោះបានលើកឡើងពីការនឹករលឹកក្រុមគ្រួសារ ឬការនៅឆ្ងាយពីសហគមន៍របស់ពួកគេ ដែលជាបញ្ហាដ៏លំបាកបំផុតក្នុងការស្នាក់នៅក្នុងមណ្ឌល។ នៅពេលត្រូវបានសួរចំៗថាតើអ្នកចង់រស់នៅក្នុងមណ្ឌល ឬនៅសហគមន៍ ភាគច្រើននិយាយថាពួកគេចង់រស់នៅក្នុងសហគមន៍ជាងប្រសិនបើមានសុវត្ថិភាព។

## ៤. អនុសាសន៍

គោលបំណងនៃការធ្វើអន្តរាគមន៍សម្រាប់ជនរងគ្រោះដែលធ្លាប់ជួបប្រទះអំពើជួញដូរដើម្បីធ្វើការកេងប្រវ័ញ្ច គឺដើម្បីសង្គ្រោះពួកគេឲ្យចេញពីស្ថានភាពនៃការកេងប្រវ័ញ្ច ហើយបញ្ជូនពួកគេទៅកាន់កន្លែងសុវត្ថិភាពដែលអាចជាសហគមន៍កំណើត ឬសហគមន៍មួយផ្សេងទៀតដែលជាជម្រើសរបស់ពួកគេ។ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់នោះទេដោយគ្រាន់តែបញ្ជូនអ្នកនោះទៅសហគមន៍។ យើងមានកាតព្វកិច្ចក្នុងការការពារពួកគេ និងផ្តល់នូវជំនាញ និងធនធានដែលចាំបាច់សម្រាប់ការពារការកេងប្រវ័ញ្ចម្តងទៀត។

## ៤.១. គោលការណ៍ណែនាំសម្រាប់កែលម្អការអន្តរាគមន៍នានា

គេបានបង្កើតឡើងនូវគោលការណ៍ទូទៅមួយចំនួនសម្រាប់កែលម្អការអន្តរាគមន៍នានា ដើម្បីបន្តនូវការកែលម្អសេវាគាំទ្រសម្រាប់ជួយដល់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងប្រទេសកម្ពុជា។ គោលការណ៍ទាំងនោះរួមមានដូចខាងក្រោម៖

- លើកកម្ពស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឲ្យមានការចូលរួមនៅគ្រប់ដំណាក់កាលនៃការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ។ ឧទាហរណ៍ដូចជា ការចូលរួមក្នុងការធ្វើការប៉ាន់ប្រមាណ ការបង្កើតផែនការករណីរបស់ជនរងគ្រោះនីមួយៗ និងការផ្តល់សេវាគាំទ្រផ្សេងៗដើម្បីការពារដល់សិទ្ធិមនុស្សជាមូលដ្ឋាន។ ជនរងគ្រោះគួរតែផ្តល់សិទ្ធិអំណាចអោយចូលរួមក្នុងការឆ្លើយតបនៃការបង្កើត និងផ្តល់សេវាគាំទ្រ។
- ជនរងគ្រោះដោយអំពើជួញដូរគួរត្រូវបានគោរព និងផ្តល់នូវព័ត៌មានគ្រប់បែបយ៉ាងចាប់តាំងពីពេលទំនាក់ទំនងជាលើកដំបូង។ ពួកគេគួរត្រូវបានផ្តល់នូវតម្រូវការចាំបាច់ជាមូលដ្ឋាន មណ្ឌលសុវត្ថិភាព និងការគាំទ្រក្នុងការបញ្ជូនត្រឡប់ ឬស្នាក់នៅក្នុងសហគមន៍របស់ពួកគាត់ ឬសហគមន៍មួយផ្សេងទៀតឲ្យបានឆាប់រហ័សនៅពេលដែលមានសុវត្ថិភាព។
- ការធ្វើការប៉ាន់ប្រមាណ និងការធ្វើការប៉ាន់ប្រមាណឡើងវិញពីតម្រូវការ និងសុវត្ថិភាព គួរត្រូវបានធ្វើជាបន្ត នៅគ្រប់ដំណាក់កាលនៃការអន្តរាគមន៍ ហើយលទ្ធផលនៃការធ្វើការប៉ាន់ប្រមាណនេះនឹងត្រូវយកធ្វើជាមូលដ្ឋានសម្រាប់ការកសាងផែនការករណី ។
- ការបន្តផ្តល់សេវាគាំទ្រនានាដូចជា អន្តរាគមន៍វិបត្តិ ការថែទាំក្រោយពីសង្គ្រោះ (កន្លែងស្នាក់នៅ អាហា ការគាំទ្រផ្នែកចិត្តសង្គម ការបង្កើតប្រាក់ចំណូល និងរក្សាស្ថេរភាពប្រាក់ចំណូល ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួយផ្នែកច្បាប់) និងសមាហរណកម្ម និងសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ដល់ជនរងគ្រោះដោយអំពើជួញដូរគ្រប់វ័យ គ្រប់ភេទ ព្រមទាំងការគាំទ្រដល់ជនរងគ្រោះដែលមានពិការភាពផងដែរ។
- ជម្រើសនៃការផ្តល់សេវាថែទាំ ( នៅពេលចាំបាច់ ) គួរត្រូវបានផ្តល់អោយក្នុងបរិយាកាសមួយដោយមិនសូវមានភាពតឹងរឹងពេក និងមានបរិយាកាសដូចនៅក្នុងក្រុមគ្រួសារ។

- ត្រូវមានការកែលម្អគុណភាពនៃការថែទាំនៅតាមមណ្ឌលបណ្ដោះអាសន្ន ដោយការផ្ដល់នូវសេវាគាំទ្រឲ្យបានសមស្របលើអន្តរាគមន៍វិបត្តិ និងការកំណត់អត្តសញ្ញាណ រួមមានកន្លែងស្នាក់នៅ ចំណីអាហារ សំលៀកបំពាក់ និងការគ្រប់គ្រងករណី ការគាំទ្រផ្នែកចិត្តសង្គម ការថែទាំក្រោយសង្គ្រោះ និងការគាំទ្រក្នុងរយៈពេលវែងដើម្បីជួយឲ្យជនរងគ្រោះដោយអំពើជួញដូរមានលំនឹងក្នុងជីវភាពរស់នៅ។
- ពង្រីកឲ្យបានទូលំទូលាយចំពោះសេវាគាំទ្រនៅតាមសហគមន៍ ដើម្បីធ្វើឲ្យជនរងគ្រោះមានភាពងាយស្រួលក្នុងការទទួលបាននូវសេវាគាំទ្រទាំងនេះ។
- ជនរងគ្រោះដោយអំពើជួញដូរ គួរត្រូវបានធ្វើសមាហរណកម្ម ឬធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ឲ្យបានកាន់តែឆាប់កាន់តែល្អ នៅពេលដែលសហគមន៍នោះត្រូវបានប៉ាន់ប្រមាណថាមានសុវត្ថិភាព ឬនៅពេលណាដែលពួកគេជ្រើសរើសទៅរស់នៅក្នុងសហគមន៍វិញ។ ប្រសិនបើពួកគេរស់នៅក្នុងមណ្ឌល គេត្រូវធ្វើការប៉ាន់ប្រមាណឡើងវិញតាមរយៈពេលកំណត់ណាមួយដើម្បីកំណត់ថាតើវានៅតែចាំបាច់ក្នុងការបន្តរស់នៅក្នុងមណ្ឌល ឬយ៉ាងណា ។
- នៅពេលដែលអាចធ្វើទៅបាន ការអន្តរាគមន៍ទាំងឡាយគួរតែអាចដោះស្រាយនូវមូលហេតុចំបងមួយក្នុងចំណោមមូលហេតុចំបងនានាដែលបង្កឲ្យមានអំពើជួញដូរ ដូចជាភាពក្រីក្រ និងការស្វែងរកប្រាក់ចំណូលសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ។ យន្តការពង្រឹងស្ថេរភាពប្រាក់ចំណូលគួរត្រូវបានពិចារណាដើម្បីគាំទ្រដល់ក្រុមគ្រួសាររបស់ជនរងគ្រោះ ខណៈពេលដែលពួកគេកំពុងទទួលនូវការបណ្ដុះបណ្ដាលជំនាញរយៈពេលវែង ។
- នៅពេលសមស្រប និងមានសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរត្រូវបានផ្ដល់នៅក្នុងសហគមន៍របស់ជនរងគ្រោះ ឬប្រសិនជនរងគ្រោះស្នាក់នៅក្នុងមណ្ឌល ពួកគេគួរត្រូវបានបែងចែកឲ្យដាច់ដោយឡែកពីសេវាគាំទ្របន្ទាន់។ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរត្រូវបានផ្ដល់ជូនដោយផ្អែកតាមការប៉ាន់ប្រមាណពីតម្រូវការទីផ្សារ មានន័យថាផ្ដល់នូវការបណ្ដុះបណ្ដាលដល់ជនរងគ្រោះដោយអំពើជួញដូរឲ្យស្របតាមតម្រូវការទីផ្សារ។
- ផ្ដោតសំខាន់លើការកែលម្អគុណភាពសេវាគាំទ្រនៅគ្រប់កម្រិតដូចជា៖
    - បង្កើនជំនាញឯកទេសសម្រាប់បុគ្គលិកដែលត្រូវផ្ដល់សេវាគាំទ្រដោយផ្ទាល់ទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអន្តរាគមន៍វិបត្តិ ការគាំទ្រផ្នែកចិត្តសង្គម និងសកម្មភាពបង្កើតប្រាក់ចំណូល ។
    - បង្កើនសមត្ថភាព ធនធាន និងភាពជាដៃគូជាមួយអាជ្ញាធររាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្ស រួមមានអន្តរាគមន៍វិបត្តិ ការថែទាំក្រោយពេលសង្គ្រោះ និងសមាហរណកម្មឡើងវិញ ។
- សេវាគាំទ្រទាំងអស់ដែលត្រូវផ្ដល់ជូនដល់ជនរងគ្រោះត្រូវស្របតាម ឬលើសពីអ្វីដែលមានចែងនៅក្នុងគោលនយោបាយ និងបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស បទដ្ឋានអប្បបរមាសម្រាប់ការថែទាំក្រោយពេលជួយសង្គ្រោះសម្រាប់កុមារ និងប្រកាសស្ដីពីបទដ្ឋាន

អប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល។

- ការវាយតម្លៃពីសេវាគាំទ្រគួរតែត្រូវធ្វើឲ្យបានទៀងទាត់ ដើម្បីកំណត់ថាតើសេវាគាំទ្រទាំងអស់នោះនឹងឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរឬទេ ។

## ៤.២. ការបន្តផ្តល់សេវាគាំទ្រ




សេវាគាំទ្រដែលគួរតែផ្តល់បន្តដល់ជនរងគ្រោះមានដូចជា ការកំណត់អត្តសញ្ញាណ និងអន្តរាគមន៍វិបត្តិ ការថែទាំក្រោយពេលជួយសង្គ្រោះ និងសមាហរណកម្ម ឬសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍។ គោលបំណងនៃការទំនាក់ទំនងលើកដំបូង គឺដើម្បីជួយដល់ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្ស ក្នុងការកំណត់នូវជំនាញ ភាពខ្លាំង និងតម្រូវការរបស់ពួកគេដើម្បីបង្កើតផែនការផ្ទាល់ខ្លួនផ្អែកតាមគោលបំណងផ្ទាល់ខ្លួនរបស់ពួកគេ។ ផែនការមួយចំនួនត្រូវបានអនុវត្តដោយជនរងគ្រោះដោយអំពើជួញដូរមនុស្សអាស្រ័យទៅតាមអាយុរបស់ពួកគេ និងសិទ្ធិក្នុងការបដិសេធមិនទទួលសេវាគាំទ្រនានា ។

បុគ្គលគ្រប់រូបដែលធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្សមានតម្រូវការ ចំនុចខ្លាំង និងឧបសគ្គផ្សេងៗគ្នា។ ការឆ្លើយតបល្អបំផុតគឺការផ្តល់នូវការថែទាំបន្តបន្ទាប់ដូចជា សេវាគាំទ្រក្នុងការអន្តរាគមន៍វិបត្តិដើម្បីកំណត់អត្តសញ្ញាណ និងសង្គ្រោះជនរងគ្រោះ ការថែទាំក្រោយពេលជួយសង្គ្រោះដើម្បីផ្តល់នូវសុវត្ថភាព និងបំពេញនូវតម្រូវការមូលដ្ឋាន កាគាំទ្រ និងប្រឹក្សាផ្លូវចិត្ត ការផ្តល់ពត៌មានអំពីច្បាប់ និងតំណាងការពារក្តី និងការគាំទ្រក្នុងការអភិវឌ្ឍន៍ជំនាញបំណិនជីវិត និងការបង្កើតសុវត្ថិភាពប្រាក់ចំណូលសម្រាប់ក្រុមគ្រួសារដើម្បីការពារកុំអោយរងគ្រោះម្តងទៀត និងផ្តល់សេវាគាំទ្រក្នុងការធ្វើសមាហរណកម្ម និង/ឬ សមាហរណកម្មឡើងវិញ ដើម្បីជួយដល់ជនរងគ្រោះអាចរស់នៅក្នុងសហគមន៍របស់ពួកគេវិញ ប្រសិនជាពួកគេបានចាកចេញពីសហគមន៍នោះ។ ជនរងគ្រោះនីមួយៗនឹងមិនត្រូវការសេវាគាំទ្រទាំងអស់នោះទេ ហើយជនរងគ្រោះនឹងត្រូវការសេវាគាំទ្រផ្សេងៗគ្នាអាស្រ័យទៅតាមពេលវេលា។ ជនរងគ្រោះគួរតែត្រូវបានអនុញ្ញាតិឲ្យជ្រើសរើសសេវាគាំទ្រដោយខ្លួនឯង ដោយផ្អែកលើស្ថានភាពរបស់គេម្នាក់ៗ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។

### ៤.២.១. កំណត់អត្តសញ្ញាណ និងសេវាកម្មអន្តរាគមន៍វិបត្តិ

នៅពេលខ្លះលក្ខណៈបង្ខិតបង្ខំនៃអំពើជួញដូរ និងការភ័យខ្លាចរបស់ជនរងគ្រោះបានធ្វើឲ្យមានការលំបាកក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ជនរងគ្រោះកម្រចែករំលែក

ពត៌មាននៅពេលធ្វើការសាកសួរលើកដំបូងណាស់ ហើយវាជាការពិតដែលពួកគេបដិសេធពីការរំលោភបំពាន ឬកុហកពីស្ថានភាពរបស់ពួកគេ។ ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាដំណើរការមួយដែលទាមទារឲ្យមានការទាក់ទងច្រើនដងដើម្បីកសាងទំនុកចិត្តរបស់ជនរងគ្រោះទៅលើអ្នកផ្តល់សេវាគាំទ្រ និងឲ្យពួកគេផ្តល់ពត៌មានក្នុងការកំណត់ឲ្យបានច្បាស់លាស់ពីការរំលោភបំពាន។

អង្គការភាគច្រើនបានប្រើប្រាសពិធីសារប៉ាឡឺម៉ូ (Palermo Protocol) សម្រាប់កំណត់និយមន័យនៃអំពើជួញដូរមនុស្ស ប៉ុន្តែអង្គការខ្លះមិនដឹងពីការប្រតិបត្តិសេចក្តីណែនាំនេះសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាគាំទ្រនោះទេ។ ម៉្យាងវិញទៀត អង្គការភាគច្រើនក៏ផ្តល់សេវាគាំទ្រដល់ក្រុមងាយរងគ្រោះប្រភេទផ្សេងទៀត ដូចជាជនរងគ្រោះដោយការរំលោភ ជនរងគ្រោះដោយអំពើហិង្សា ឫជនងាយរងគ្រោះផ្សេងទៀត។ អង្គការខ្លះក៏ចាត់ទុកមនុស្សពេញវ័យដែលប្រកបរបររកស៊ីផ្លូវភេទដោយស្ម័គ្រចិត្តថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរ។ កង្វះខាតនៃការកំណត់ក្រុមគោលដៅនេះ ពេលខ្លះធ្វើឲ្យការរាយការណ៍នៃចំនួនជនរងគ្រោះដោយអំពើជួញដូរមនុស្សមានភាពមិនច្បាស់លាស់។

រហូតដល់ប៉ុន្មានឆ្នាំកន្លងទៅនេះ វិធីសាស្រ្តដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាសម្រាប់ការកំណត់អត្តសញ្ញាណ និងជួយសង្គ្រោះជនរងគ្រោះ ធ្វើឡើងតាមរយៈការចុះឆែកឆេរផ្ទះបន កំឡុងពេលដែលជនរងគ្រោះត្រឡប់ពីប្រទេសមួយទៀត ឫការកំណត់អត្តសញ្ញាណដោយខ្លួនឯងតាមរយៈការស្វែងរកជំនួយរបស់ជនរងគ្រោះដោយផ្ទាល់ទៅកាន់អាជ្ញាធររដ្ឋាភិបាល ឫតាមរយៈអង្គការផ្តល់សេវាគាំទ្រនៅសហគមន៍។ អាស្រ័យទៅតាមការផ្លាស់ប្តូរថ្មីៗនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ផ្ទះបនកម្រត្រូវបានគេចុះឆែកឆេណាស់ ហើយអង្គការនានាកំពុងព្យាយាមស្វែងរកវិធីសាស្រ្តផ្សេងៗសម្រាប់ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ។ អង្គការមួយកំពុងគូសផែនទីកត់សម្គាល់ពីការបង្កើតនូវក្រុមអ្នករកស៊ីផ្លូវភេទ ដែលអាចនឹងកើតមាន ហើយអង្គការផ្សេងទៀតកំពុងផ្តោតសំខាន់លើទៅលើក្រុមគោលដៅថ្មី ដូចជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីកម្លាំងពលកម្ម។ នេះគឺជាផ្នែកមួយដែលគំរូកម្មវិធីថ្មីនឹងត្រូវបានបង្កើតនៅប៉ុន្មានខែខាងមុខនេះ។

ជាលទ្ធផលនៃបញ្ហាប្រឈមទាំងនេះ វាជាការសំខាន់ក្នុងការកំណត់នូវអន្តរាគមន៍ថ្មីៗ៖

- ផ្តល់ពត៌មានឆាប់រហ័សដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពន្យល់ពីអ្វីដែលបានកើតឡើងនៅក្នុងសកម្មភាពជួយសង្គ្រោះ និង/ឬអន្តរាគមន៍ និងមូលហេតុ។ ពត៌មានគួរត្រូវបានផ្តល់ឲ្យដោយផ្ទាល់មាត់ ឫជាលាយលក្ខណ៍អក្សរដែលអាចយកទៅបាន។ ពត៌មានត្រូវបញ្ចូលនូវពត៌មានទាក់ទងនឹងអំពើជួញដូរ និងសេវាកម្មដែលមានដើម្បីឲ្យជនរងគ្រោះអាចពិចារណារជ្រើសរើសយកសេវាគាំទ្រនៅពេលក្រោយទៀតបាន ប្រសិនបើពួកគេមិនបានជ្រើសរើសសេវាគាំទ្រណាមួយភ្លាមៗនោះទេ។

- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាកម្ម និងអ្នកអន្តរាគមន៍បឋមពីបច្ចេកទេសនៃការសម្ភាសន៍ដែលសមស្រប និងការប្រើប្រាស់វិធីសាស្ត្រក្នុងការកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់។ គេត្រូវផ្តោតសំខាន់ទៅលើការសម្តែងនូវឥរិយាបថមិនរើសអើងដែលបង្ហាញពីការទទួលយក និងយល់ពីស្ថានភាពរបស់ជនរងគ្រោះ។ ដំណើរការនេះនឹងអប់រំដល់ជនរងគ្រោះ ហើយជួយពួកគេឲ្យទទួលបានធនធានប្រសិនបើគេត្រូវការ ។
- ទោះបីជាគម្រោងនេះមិនបានដោះស្រាយនូវបញ្ហានេះដំដោយ វាមានការលំបាកក្នុងការទទួលបាននូវការយល់ដឹងច្បាស់លាស់ពីទិដ្ឋភាពនៃបញ្ហាទាក់ទងនឹងអំពើជួញដូរ ទាំងប្រភេទនៃអំពើជួញដូរមនុស្សដែលកើតមាន និងទំហំនៃបញ្ហា។ ការព្យាយាមក្នុងការកំណត់ និងបញ្ជាក់ពីបញ្ហាគួរត្រូវបានគាំទ្រផងដែរ ។

**យុទ្ធសាស្ត្រកម្មវិធីដែលមានស្រាប់គួរធរាយកត់សំគាល់**

- អ្នកផ្តល់សេវាគាំទ្រដល់ជនរងគ្រោះធ្វើការជិតស្និទ្ធជាមួយអាជ្ញាធរព្រំដែនក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ព្រោះពួកគេត្រឡប់ពីប្រទេសមួយទៀតដោយស្ម័គ្រចិត្ត។ ជនរងគ្រោះដោយអំពើជួញដូរជាច្រើនមិនបានកត់សម្គាល់ថាខ្លួនជាជនរងគ្រោះ ហើយក៏មិនដឹងពីសេវាគាំទ្រសម្រាប់ផ្តល់ដល់ពួកគេនោះទេ។ អង្គការមួយចំនួនកំពុងបញ្ជូនបុគ្គលិកទៅកាន់តំបន់ព្រំដែន ដើម្បីសាកសួរប្រជាជនដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ។
- អង្គការសង្គ្រោះបានធ្វើការកំណត់សម្គាល់ចំពោះអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ដែលអាចនឹងកើតមានឫសេវាកម្មបញ្ជូនអ្នករកស៊ីផ្លូវភេទដើម្បីធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយជួញដូរមនុស្ស។
- មណ្ឌលសំចតនៅតាមតំបន់ព្រំដែនដើម្បីបញ្ជូនជនរងគ្រោះដោយអំពើជួញដូរឲ្យត្រឡប់មកវិញ។

## ៤.២.២. ការថែទាំក្រោយពេលជួយសង្គ្រោះ

### ៤.២.២.១.ការធ្វើផែនការ ការប៉ាន់ប្រមាណនិងការថែទាំ

ប្រព័ន្ធនៃការធ្វើការប៉ាន់ប្រមាណ និងផែនការថែទាំគឺជាផ្នែកមួយដែលមានការអភិវឌ្ឍន៍បានល្អប្រសើរនៅក្នុងសេវាថែទាំក្រោយពេលជួយសង្គ្រោះនៅកម្ពុជា។ ក្នុងករណីដែលត្រូវបានសង្គ្រោះដោយនគរបាល ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្សត្រូវបានបញ្ជូនទៅស្ថាប័ ឬអង្គការដែលផ្តល់សេវាគាំទ្រនៅតាមសហគមន៍ តាមរយៈក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រោយពីការបញ្ជូន ស្ថាប័ន/អង្គការមួយចំនួនផ្តល់ឲ្យជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្សនូវការវាយតម្លៃដ៏ច្បាស់លាស់មួយ ដើម្បីកំណត់ពីភាពខ្លាំង និងតម្រូវការរបស់ពួកគេ និងរៀបចំផែនការផ្ទាល់ខ្លួន និងអ្នកផ្សេងទៀតដែលយល់ព្រមទទួលនូវការផ្តល់សេវាគាំទ្រពីកម្មវិធីប្រកបដោយស្តង់ដារ ដែលជាទូទៅត្រូវបានផ្តល់ជូននៅតាមមណ្ឌល ។

ដើម្បីធ្វើការកែលម្អការប៉ាន់ប្រមាណ និងផែនការថែទាំ ជំហ៊ានដំបូងដើម្បីធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្សគឺការស្វែងយល់ពីស្ថានភាពបុគ្គលរបស់ជនរងគ្រោះ (ការកំណត់អត្តសញ្ញាណ) ផ្តល់ព័ត៌មាន និងធ្វើការប៉ាន់ប្រមាណចំនុចខ្លាំង និងតម្រូវការរបស់បុគ្គល។ ការប៉ាន់ប្រមាណដែលមានគុណភាពមួយអាចកំណត់ថាតើប្រភេទនៃអន្តរាគមន៍ណាដែលត្រូវការ ហើយប្រភេទនៃការស្វែងរកទីតាំងស្នាក់នៅ (ប្រសិនបើមាន) មួយណាដែលស័ក្តសមសម្រាប់ជនរងគ្រោះ។ កន្លែងស្នាក់នៅជំនួសមិនគួរជ្រើសរើសយកតែមណ្ឌលដោយស្វ័យប្រវត្តនោះទេ។

មានគោលការណ៍មួយចំនួនដែលគួរតែអនុវត្តតាម ដើម្បីធ្វើការប៉ាន់ប្រមាណឲ្យមានគុណភាព។ ការប៉ាន់ប្រមាណតម្រូវការបុគ្គលរបស់ជនរងគ្រោះគួរតែចាប់ផ្តើមក្នុងកំឡុងពេលអន្តរាគមន៍វិបត្តិ និងដំណាក់កាលនៃការកំណត់អត្តសញ្ញាណ និងបន្តរហូតដល់ការថែទាំក្រោយពេលជួយសង្គ្រោះ និងក្នុងពេលធ្វើសមាហរណកម្មឡើងវិញ។ ការប៉ាន់ប្រមាណផ្សេងគ្នាចាំបាច់ត្រូវតែធ្វើ ហើយពេលវេលាសម្រាប់ការធ្វើការប៉ាន់ប្រមាណអាចខុសគ្នាអាស្រ័យលើអាយុ និងតម្រូវការរបស់ជនរងគ្រោះ។ ប្រភេទនៃការប៉ាន់ប្រមាណដែលអាចមាន និងគួរតែបង្កើតឲ្យមានភ្លាមៗមានដូចជា៖

- ការកំណត់អត្តសញ្ញាណលើប្រវត្តិរបស់បុគ្គល
- ការប៉ាន់ប្រមាណគ្រួសារ និងសហគមន៍ក្នុងការកំណត់កត្តាការពារ និងហានិភ័យ
- ការប៉ាន់ប្រមាណសុខភាព
- ការប៉ាន់ប្រមាណផ្នែកចិត្តសង្គម
- ការប៉ាន់ប្រមាណសុវត្ថិភាព និងការគំរាមកំហែងពីជនល្មើសចំពោះជនរងគ្រោះ គ្រួសាររបស់ពួកគេ និងអ្នកផ្តល់សេវាគាំទ្រ
- សម្រាប់អនីតិជន ដំណាក់កាលនៃការរៀបចំផែនការប៉ាន់ប្រមាណ និងករណីទាមទារការដាក់អោយមានជម្រើសនៃការថែទាំសម្រាប់រយៈពេលមួយនៅពេលដែលជនរងគ្រោះ គ្រួសារ និងសុវត្ថិភាពរបស់ជនរងគ្រោះត្រូវបានធ្វើការប៉ាន់ប្រមាណ។ វាអាចត្រូវការរយៈពេលយូរ ព្រោះជនរងគ្រោះមិនរស់នៅក្បែរកន្លែងសង្គ្រោះ ហើយវាទាមទារការធ្វើដំណើរ និងពេលវេលាក្នុងការស្វែងយល់ស្ថានភាពនោះ។
- ពត៌មានពីការប៉ាន់ប្រមាណទាំងនេះគួរតែត្រូវបានបញ្ចូលនៅក្នុងផែនការការគ្រប់គ្រងករណីដើម្បីបង្កើតផែនការមួយដែលមានគោលដៅ និងគោលបំណងច្បាស់លាស់ដោយផ្អែកលើតម្រូវការរបស់បុគ្គល ចំណុចខ្លាំងរបស់ពួកគេ និងសេចក្តីប្រាថ្នាផ្ទាល់ខ្លួន។ ផែនការគួរតែត្រូវបានវាយតម្លៃឡើងវិញជាទៀងទាត់ និងបន្ថែមព័ត៌មានថ្មីៗដោយផ្អែកលើការរីកចំរើនជាក់ស្តែង ជាមួយនឹងគោលដៅ និងព័ត៌មានថ្មី។
- សេវាគាំទ្រត្រូវឆ្លើយតបទៅនឹងតម្រូវការភ្លាមៗ និងតម្រូវការរយៈពេលវែងរបស់ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្ស។ សេវាគាំទ្រទាំងនេះអាចរួមបញ្ចូល ការថែទាំសុខភាពបន្ទាន់ កន្លែងស្នាក់នៅបណ្តោះអាសន្ន ការគាំទ្របន្ទាន់ដូចជា អាហារ និងសំលៀកបំពាក់ ការគាំទ្រ

និងពត៌មានផ្នែកច្បាប់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតប្រាក់ចំណូល។ ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្ស មិនមែនត្រូវតែស្នាក់នៅក្នុងមណ្ឌលដើម្បីទទួលបានសេវាគាំទ្រទាំងនេះនោះទេ ។

- ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្ស ត្រូវមានសិទ្ធិក្នុងការជ្រើសរើស ឬបដិសេធនូវសេវាគាំទ្រនានាប្រសិនបើគេគឺជាមនុស្សពេញវ័យ ប៉ុន្តែចំពោះអនីតិជន ពួកគេត្រូវមានការផ្តល់យោបល់ចំពោះសេវាគាំទ្រនានាដែលពួកអាចទទួល។
- ដើម្បីបំពេញតាមស្តង់ដាទាំងនេះ ការបណ្តុះបណ្តាលត្រូវការធ្វើឡើងតាមរយៈវិធីសាស្រ្តនៃការវាយតម្លៃ និងការរៀបចំផែនការទៅតាមករណីផ្សេងៗ។

## យុទ្ធសាស្រ្តកម្មវិធីបច្ចុប្បន្ន ដែលគួរអោយកត់សម្គាល់

- មណ្ឌលសំចតះ មណ្ឌលសំចតត្រូវបានកំណត់ទីតាំងជាយុទ្ធសាស្រ្តនៅតាមចំណុចព្រំដែន ដើម្បីឆ្លើយតបនឹងតម្រូវការភ្លាមៗសម្រាប់អាហារ និងជម្រក (រយៈពេលយ៉ាងខ្លី) និងដើម្បីបំពេញនូវសេចក្តីណែនាំក្នុងការកំណត់អត្តសញ្ញាណ ការប៉ាន់ប្រមាណអោយបានឆាប់រហ័សនៃតំរូវការព័ត៌មាន និងដើម្បីបញ្ជូនត្រឡប់ទៅកាន់គេហដ្ឋាន ឬបញ្ជូនទៅរកសេវាគាំទ្រផ្សេងៗ។
- មណ្ឌលសម្រាប់ការធ្វើការប៉ាន់ប្រមាណរយៈពេលខ្លី គឺជាមណ្ឌលដែលផ្តល់នូវការធ្វើការប៉ាន់ប្រមាណយ៉ាងឆាប់រហ័ស (និងម៉ត់ចត់) មណ្ឌលសម្រាប់ផ្តល់ពត៌មាន និងបញ្ជូនទៅរកសេវាគាំទ្រផ្សេងៗដែលសមស្របសម្រាប់ជនរងគ្រោះ។
- បុគ្គលិកសង្គមទទួលបន្ទុកការប៉ាន់ប្រមាណត្រូវបានបណ្តុះបណ្តាលអោយធ្វើការប៉ាន់ប្រមាណនូវសេវាគាំទ្រដែលស្នើសុំដោយជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងឥរិយាបទឆាប់រហ័ស។ ការប៉ាន់ប្រមាណលើសុវត្ថិភាពធ្វើឡើងភ្លាមៗ ហើយប្រសិនបើការប៉ាន់ប្រមាណលើភាពគ្រោះថ្នាក់មានកម្រិតទាប ជនរងគ្រោះត្រូវបានបញ្ជូនទៅស្នាក់នៅក្នុងសហគមន៍ជាជាងជម្រើសស្នាក់នៅក្នុងមណ្ឌល។

## ៤.២.២.២. ជម្រើសនៃកការថែទាំ

ការថែទាំនៅក្នុងមណ្ឌលត្រូវគេមើលឃើញទូទៅថាជាជម្រើសដែលផ្តល់ផលប្រយោជន៍តិចតួចសម្រាប់ជម្រើសនៃការថែទាំ ទោះបីជាភាគច្រើនចម្រើសនៃការថែទាំសម្រាប់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងប្រទេសកម្ពុជាគឺការថែទាំនៅក្នុងមណ្ឌល។ ជម្រើសការថែទាំនៅក្នុងមណ្ឌលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការផ្តល់ការការពារសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ បន្ទាប់ពីការកំណត់អត្តសញ្ញាណ និង/ឬការជួយសង្គ្រោះ។ ជម្រើសនៃការថែទាំនៅក្នុងមណ្ឌលគឺត្រូវបានអនុវត្តជាទូទៅដើម្បីផ្តល់សេវាគាំទ្រដល់ស្រ្តីនិងក្មេងស្រីដែលរងគ្រោះដោយសារអំពើជួញដូរមនុស្សដើម្បីធ្វើអាជីវកម្មផ្លូវភេទ និងសម្រាប់ទាំងកុមារានិងកុមារីដែលធ្លាប់ជួបប្រទះអំពើជួញដូរសម្រាប់ការកេងប្រវ័ញ្ចពលកម្ម។ បច្ចុប្បន្ន គ្រែនៅក្នុងមណ្ឌល

ភាគច្រើនមានមានសម្រាប់ស្ត្រី និងកុមារី ប៉ុន្តែមានតែមួយចំនួនតូចប៉ុណ្ណោះសម្រាប់ជនរងគ្រោះដែលជាបុរស និងកុមារា។ ដោយសារតែគំរូសេវាកម្មមានវត្តមានយូរ និងមានស្ថេរភាព អង្គការផ្តល់សេវាកម្មសហគមន៍កំពុងធ្វើការពិសោធក្នុងមធ្យោបាយផ្សេងៗដើម្បីផ្តល់ការជម្រើសនៃថៃទាំនៅសហគមន៍ ឬកាថៃទៃដែលមានលក្ខណៈដូចជានៅក្នុងគ្រួសារ។ តម្រូវការមណ្ឌលស្នាក់នៅជាបន្ទាន់ដើម្បីរក្សាសុវត្ថភាព និងការការពារពិតជាមានសម្រាប់ជនរងគ្រោះ ប៉ុន្តែវាក៏ចាំបាច់ត្រូវមានជម្រើសផ្សេងផងដែរ ពីព្រោះជនរងគ្រោះជាច្រើនពុំសូវចង់ស្នាក់នៅក្នុងមណ្ឌលនោះទេ ពួកគេចង់ទទួលបាននូវសេវាគាំទ្រនៅតាមសហគមន៍វិញ។

## ជម្រើសនៃការថៃទាំនៅក្នុងមណ្ឌល

ការថៃទាំនៅក្នុងមណ្ឌលនៅតែមន្តជាជម្រើសនៃការសមស្រប និងចាំបាច់ដើម្បីផ្តល់សេវាគាំទ្រក្រោយពេលសង្គ្រោះសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមួយចំនួនដែលត្រូវការនូវការការពារ។ ការថៃទាំនៅក្នុងមណ្ឌលអាចផ្តល់នូវការការពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបាននូវកន្លែងស្នាក់នៅ និងសេវាគាំទ្រផ្សេងៗដើម្បីធ្វើការស្តាឡើងវិញ ដូចជាការថៃរក្សាសុខភាព ការផ្តល់អាហារបំប៉ន ការប្រឹក្សាផ្នែកចិត្តសង្គម ការផ្តល់ពត៌មាន និងគាំទ្រផ្នែកច្បាប់ ហើយជួនការអាចមានការផ្តល់នូវការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សេវាគាំទ្រនៅតាមមណ្ឌលគឺត្រូវបានប្រើប្រាស់ច្រើនលើសលប់នៅកម្ពុជា ដូចច្នេះហើយវាគួរតែត្រូវបានកាត់បន្ថយខ្លះ ហើយជ្រើសរើសជម្រើសមួយផ្សេងទៀតដែលមានលក្ខណៈប្រសើរជាង ដោយការបង្កើតសេវាគាំទ្រនៅតាមសហគមន៍។ ម៉្យាងវិញទៀត ការផ្តល់នូវការថៃទាំនៅក្នុងមណ្ឌលគួរតែមានលក្ខណៈផ្សេងៗគ្នា ពីព្រោះតម្រូវការរបស់ជនរងគ្រោះដែលទើបរួចផុតពីស្ថានភាពនៃការជួញដូរមានភាពខុសគ្នាំពីស្ថានភាពជនរងគ្រោះដែលបានរួចផុតពីការជួញដូរក្នុងរយៈពេលយូ ហើយពួកគេកំពុងត្រៀមខ្លួនវិលត្រឡប់ទៅកាន់សហគមន៍វិញ។

- ការថៃទាំក្នុងមណ្ឌល គួរត្រូវបានផ្តល់ដល់ជនរងគ្រោះដោយមានការកាត់បន្ថយនូវការដាក់កំហិតបន្តិចម្តងៗ និងពីដំណាក់កាលមួយទៅដំណាក់កាលមួទៀត ដោយផ្អែកលើសុវត្ថភាព និងតម្រូវការផ្សេងៗរបស់ពួកគេ។ នៅពេលដែលមានសុវត្ថិភាព និងត្រៀមខ្លួនរួចរាល់ ជនរងគ្រោះត្រូវបានផ្លាស់ទៅកន្លែងស្នាក់នៅដែលមានការដាក់កំហិតតិចតួច ឬការថៃទាំនៅតាមសហគមន៍ ។
- ពេលវេលាដែលទទួលបានការថៃទាំនៅក្នុងមណ្ឌល នឹងមានភាពខុសគ្នាសម្រាប់ជនរងគ្រោះម្នាក់ៗ ហើយគេមិនអាចធ្វើឡើងដោយកំណត់ពេលវេលាណាមួយជាក់លាក់នោះទេ។ ការបញ្ជូនត្រឡប់ទៅវិញ គួរត្រូវបានធ្វើការវាយតម្លៃឡើងវិញយ៉ាងហោចណាស់រៀងរាល់៦ខែម្តងដើម្បីកំណត់ថាការបញ្ជូនត្រឡប់ទៅរស់នៅក្នុងសហគមន៍វិញអាចធ្វើទៅបាន។ កាវាយតម្លៃគួរត្រូវបញ្ចូលទាំងការប៉ាន់ប្រមាណទៅលើស្ថានភាពគ្រួសារ និងសហគមន៍ផងដែរ។

- កម្មវិធីថែទាំក្នុងមណ្ឌលមួយចំនួនក៏បានផ្តល់នូវសេវាកម្មរយៈពេលវែងដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជំនាញបំណិនជីវិតផ្សេងៗទៀត។ នៅពេលសមស្រប ការបណ្តុះបណ្តាលវិជ្ជាជីវៈគួរត្រូវផ្តល់នៅតាមសហគមន៍ ឬកន្លែងស្នាក់នៅដែលមិនសូវមានដាក់កំហិត។ កម្មវិធីបណ្តុះបណ្តាលក្នុងមណ្ឌល ត្រូវធ្វើការប៉ាន់ប្រមាណពីសុវត្ថិភាពនៃការស្នាក់នៅ និងការអនុញ្ញាតិឲ្យមានសេរីភាពក្នុងការបំលាស់ទី។
- ភាពខ្វះខាតនៃគុណភាពនៃការថែទាំក្នុងមណ្ឌល គួរត្រូវបានដោះស្រាយដើម្បីកែលម្អតម្រូវការជាមូលដ្ឋាន អាហារ កន្លែងស្នាក់នៅ សំលៀកបំពាក់ផ្តល់នូវការបណ្តុះបណ្តាលដល់បុគ្គលិកនូវគំរូនៃការផ្តល់សេវាគាំទ្រផ្សេងៗគ្នាដូចជា ការគ្រប់គ្រងករណីនីមួយៗ ការប៉ាន់ប្រមាណសុវត្ថិភាព និងការធ្វើផែនការ ឬជំនាញឯកទេស និងគោលនយោបាយក្នុងការគ្រប់គ្រងការងារសង្គម ដល់អ្នកស្នាក់នៅក្នុងមណ្ឌល។ វគ្គបណ្តុះបណ្តាល ដែលមានការអនុវត្តល្អៗ គួរត្រូវបានផ្តល់ឲ្យអ្នកផ្តល់សេវាគាំទ្រ ដូច្នេះអ្នកផ្តល់សេវាគាំទ្រទាំងនោះអាចមានទុនក្នុងការកែលម្អរ ជំនាញក្នុងការផ្តល់សេវាកម្មរបស់ពួកគេ។
- ជម្រើសនៃការថែទាំបន្ទាន់នៅក្នុងមណ្ឌល គួរត្រូវបានធ្វើឡើងសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ប្រភេទ រួមទាំងជនរងគ្រោះដែលជាក្មេងប្រុសផងដែរ។

## ការថែទាំនៅសហគមន៍

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតគោលនយោបាយស្តីអំពីជម្រើសនៃការថែទាំចំពោះកុមារ និងបានរកឃើញថាការថែទាំដោយក្រុមគ្រួសារ និងនៅសហគមន៍គឺជាជម្រើសល្អបំផុតសម្រាប់ជម្រើសនៃការថែទាំ[18]។ នៅក្នុងការប៉ាន់ប្រមាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក៏បានប្រាប់ពីបំណងប្រាថ្នារបស់ពួកគេក្នុងការរស់នៅក្នុងសហគមន៍។ អ្នកផ្តល់សេវាគាំទ្រក៏បានរាយការណ៍ថាជនរងគ្រោះខ្លះនឹងត្រឡប់ទៅសហគមន៍របស់ខ្លួនដោយខ្លួនឯង ហើយបដិសេធន៍ទទួលយកសេវាគាំទ្រនៅក្នុងមណ្ឌល។ នៅក្នុងការវាយតម្លៃថ្មីមួយដោយកម្មវិធីនៅសហគមន៍សម្រាប់ជនរងគ្រោះដោយការរំលោភ ៨១%នៃជនរងគ្រោះបាននិយាយថាពួកគេចង់រង់នៅក្នុងសហគមន៍ជាង[19]។ ជាក់ស្តែងការថែទាំនៅសហគមន៍ គឺជាការសមស្របបំផុតនៅពេលដែលជនរងគ្រោះមានសុវត្ថិភាព ហើយនៅពេលដែលជនរងគ្រោះចង់បាន។

ដើម្បីឆ្លើយតបនឹងការកើនឡើងពីការយល់ដឹងអំពីបំណងប្រាថ្នាសម្រាប់ការថែទាំនៅសហគមន៍ដល់ជនរងគ្រោះដោយអំពើជួញដូរ មានអង្គការផ្តល់សេវាគាំទ្រនៅសហគមន៍ខ្លះកំពុងបង្កើតជម្រើសនៃការថែទាំដែលមិនមានលក្ខណៈជាមណ្ឌល ឬបើសិនជាមានលក្ខណៈជាមណ្ឌល ក៏មណ្ឌលនោះមានទ្រង់ទ្រាយតូចដែលមានទីតាំងនៅក្នុងសហគមន៍។ កម្មវិធីថ្មីៗទាំងនេះបាននាំឲ្យមានការផ្លាស់ប្តូរដ៏សមស្របមួយឆ្ពោះទៅរកការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះនៅតាមសហគមន៍ច្រើននៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយគួរត្រូវ

---

18(MoSVY, May 2008)

[៣] (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែឧសភា ឆ្នាំ២០០៨)
[19](SSC, 2011)

បានគេលើកកម្ពស់ ដែលបន្តដល់ការបង្កើនជម្រើសផ្សេងៗនៃការថែទាំនៅសហគមន៍។ សកម្មភាពដែលសំដៅដល់ការថែទាំនៅតាមសហគមន៍នេះ គឺទំនងជាមានការកើនឡើងជាបន្តបន្ទាប់នៅពេលសេវាគាំទ្រនៅតាមសហគមន៍ត្រូវបានបង្កើតឡើងកាន់តែប្រសើរ ហើយក៏មានក្តីសង្ឃឹមថាតម្រូវការសម្រាប់ការថែទាំនៅក្នុងមណ្ឌលនឹងមានការថយចុះ។

- ការអនុវត្តល្អៗបានបង្ហាញថា ជម្រើសទីមួយនៃការថែទាំចំពោះកុមារគួរតែជាការថែទាំដោយឲ្យស្នាក់នៅក្នុងគ្រួសាររបស់គេ (ប្រសិនជាមានសុវត្ថិភាព) បន្ទាប់មកគឺការថែទាំនៅជាមួយសាច់ញាតិតាមរយៈគ្រួសារដែលមានសាច់ញាតិច្រើន ហើយជម្រើសចុងក្រោយគឺការថែទាំជាមួយឪពុកម្តាយចិញ្ចឹម។ ជម្រើសថែទាំសម្រាប់ជនរងគ្រោះគ្រប់រូប គួរត្រូវបានផ្តល់នូវបរិយាកាសដែលស្រដៀងទៅនឹងបរិយាកាសនៅក្នុងគ្រួសារប្រសិនបើអាចធ្វើទៅបាន។
- សុវត្ថិភាពគឺជាកត្តាដែលត្រូវយកមកធ្វើការពិចារណាមុនគេ នៅពេលបញ្ជូនកុមារ ឬមនុស្សពេញវ័យឲ្យស្នាក់នៅទីកន្លែងដែលមានលក្ខណៈដូចជាក្រុមគ្រួសារ ឬនៅតាមសហគមន៍។ សុវត្ថិភាពរបស់ជនរងគ្រោះត្រូវតែត្រូវបានធ្វើការប៉ាន់ប្រមាណដើម្បីកំណត់ថាតើក្រុមគ្រួសារ ឬសហគមន៍សម្រាប់ផ្តល់នូវការថែទាំដល់ជនរងគ្រោះនោះអាចធានានូវសុវត្ថភាពសម្រាប់ពួកគេដែរ ឬទេ?
- វគ្គបណ្តុះបណ្តាលគួរតែត្រូវបានផ្តល់សម្រាប់អង្គការក្នុងការប៉ាន់ប្រមាណលើសុវត្ថិភាពក្នុងស្ថានភាពជួញដូរ ដើម្បីកែលម្អជំនាញនៃការប៉ាន់ប្រមាណរបស់អ្នកផ្តល់សេវាគាំទ្រឲ្យកាន់តែប្រសើរ។
- គាំទ្រដល់ការចំណាយផ្សេងៗ ដូចជាការចំណាយលើការធ្វើដំណើរដើម្បីឲ្យជនរងគ្រោះធ្វើកិច្ចការទាក់ទងនឹងដំណើរការផ្លូវច្បាប់ និងផ្តល់នូវសេវាគាំទ្រផ្សេងៗដែលមានភាពចាំបាច់ ក៏ដូចការធ្វើដំណើរទៅសហគមន៍ផងដែរ។

## យុទ្ធសាស្ត្រកម្មវិធីបច្ចុប្បន្នដែលគួរអោយកត់សម្គាល់

- ការផ្តល់ការថែទាំជាមួយសាច់ញាតិរបស់ជនរងគ្រោះ ដែលត្រូវបានបញ្ជាក់អោយឃើញថាអាចថែទាំជនរងគ្រោះក្នុងអាកប្បកិរិយាប្រកបដោយសុវត្ថិភាព និងមិនមានការកេងប្រវ័ញ្ច។
- ការថែទាំចិញ្ចឹមបណ្តោះអាសន្នដែលផ្តល់ដោយគ្រួសារដែលត្រូវបានការបណ្តុះបណ្តាល និងដែលអាចផ្តល់បរិយាកាសបែបគ្រួសារដល់ជនរងគ្រោះដែលមិនមានការបារម្ភពីការការពារ។
- ផ្ទះជាលក្ខណៈក្រុមតូចដែលមានអ្នកស្នាក់នៅតិចជាង២៥នាក់ ជាជាងកន្លែងដែលមានអ្នកស្នាក់នៅច្រើន។
- ផ្ទះរស់នៅបែបឯករាជ្យសម្រាប់បុគ្គលទាំងឡាយ ដែលមិនទាន់រួចរាល់ក្នុងការរស់នៅដោយឯករាជ្យ

### ៤.២.៣. ការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញ

សមាហរណកម្មទៅសហគមន៍ ឬសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍កំណើតរបស់ជនរងគ្រោះ គឺជាគោលបំណងនៃផែនការករណីទាំងអស់សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ជនរងគ្រោះភាគច្រើនត្រូវបានដាក់ឲ្យនៅដាច់ពីសហគមន៍កំណើតរបស់ពួកគេ ដោយសារពួកគេពួកគេងាយនឹងទទួលការរងគ្រោះដោយសារអំពើជួញដូរមនុស្ស។ គម្រូចំបងនៃសេវាគាំទ្រជនរងគ្រោះនានានៅកម្ពុជា គឺការផ្តល់ការថែទាំនៅតាមមណ្ឌល និងកាផ្តល់សេវាគាំទ្រផ្សេងៗទៀត។ នៅពេលដែលជនរងគ្រោះបានបញ្ចប់នូវកម្មវិធីនៅក្នុងមណ្ឌល អង្គការ/ស្ថាប័ននឹងធ្វើការបញ្ជូនពួកគេទៅសហគមន៍វិញ ។

កិច្ចប្រឹងប្រែងនៃការធ្វើសមាហរណកម្ម និងការធ្វើសមាហរណកម្មឡើងវិញ ត្រូវបានអនុវត្តដោយអង្គការផ្តល់សេវាគាំទ្រនៅតាមសហគមន៍ ដោយមានការគាំទ្រពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមរយៈការិយាល័យសង្គមកិច្ចស្រុក (DoSVY)។ នៅក្នុងការប៉ាន់ប្រម៉ាណនេះ អ្នកផ្តល់សេវាគាំទ្រ និងមន្ត្រីសង្គមកិច្ចស្រុក (DoSVY) បានរកឃើញកង្វះខាតនៃធនធានសហគមន៍ ថាជាឧបសគ្គសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងការការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសហគមន៍ និងពេលខ្លះហេតុផលដែលចង់មន្តការស្នាក់នៅក្នុងមណ្ឌលក៏ជាឧបសគ្គក្នុងការធ្វើសមាហរណកម្មផងដែរ។

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក៏បានបង្ហាញពីបំណងប្រាថ្នាក្នុងការត្រឡប់ទៅកាន់សហគមន៍ ឬទទួលសេវាគាំទ្រនៅសហគមន៍ប្រសិនជាអាច។ ជនរងគ្រោះពេញចិត្តនឹងសវាគាំទ្រដែលពួកគេបានទទួលនៅក្នុងមណ្ឌល ប៉ុន្តែពួកគេចង់បានសេវាគាំទ្រនោះនៅសហគមន៍ប្រសិនបើមានសុវត្ថិភាព។ ប៉ុន្តែមានឧបសគ្គមួយចំនួនដែលបានរកឃើញ ដូចជាកង្វះខាតនូវរចនាសម្ព័ន្ធទ្រទ្រង់សហគមន៍នៅក្នុងសហគមន៍កំណើតរបស់ជនរងគ្រោះក្នុងការទ្រទ្រង់ការធ្វើសមាហរណកម្មឡើងវិញ និងការវិលត្រឡប់ប្រកបដោយសុវត្ថិភាព និងជោគជ័យ។

សព្វថ្ងៃនេះ អ្នកផ្តល់សេវាគាំទ្រខ្លះកំពុងពង្រីកជម្រើសសេវាកម្មអោយបានច្រើន ដើម្បីផ្តល់នៅសហគមន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប៉ុន្តែជួបនូវឧបសគ្គមួយចំនួន ព្រោះជនរងគ្រោះមកពីប្រទេសផ្សេងៗ ហើយសេវាគាំទ្រត្រូវតែផ្តោតការយកចិត្តទុកដាក់នៅតំបន់គោលដៅសម្រាប់អំពើជួញដូរ។

សមាហរណកម្មទៅក្នុងសហគមន៍គឺជាដំណើរការ មិនមែនជាព្រឹត្តិការណ៍នោះទេ។ វាទាមទារនូវពេលវេលា និងការគាំទ្រដ៏សមស្របដើម្បីទទួលបានជោគជ័យ។ វាមិនមែនគ្រាន់តែជាការបញ្ជូនជនរងគ្រោះត្រឡប់ទៅសហគមន៍វិញនោះទេ។ ភាពងាយរងគ្រោះត្រូវតែកាត់បន្ថយ ហើយស្ថានភាពបុគ្គល ឬគ្រួសារត្រូវមានស្ថេរភាព។ នៅពេលខ្លះ ជនរងគ្រោះអាចត្រូវបញ្ជូនទៅសហគមន៍ថ្មីដែលមានឱកាសច្រើនជាង ។

យុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ឬការទប់ស្កាត់នូវការបញ្ជូនទៅមណ្ឌលស្នាក់នៅមានដូចជាៈ

- ផ្តល់នូវការបណ្តុះបណ្តាលដែលស្របតាមតម្រូវការទីផ្សារ សមត្ថភាព និងជំនាញរបស់មនុស្សម្នាក់ៗ ។
- កម្មវិធីពង្រឹងស្ថេរភាពប្រាក់ចំណូល ដូចជាការផ្ទេរប្រាក់ដោយមានលក្ខខ័ណ្ឌ ឬជំនួយបន្ទាន់ដែលអាចបំពេញនូវតម្រូវការបន្ទាន់របស់គ្រួសារ រហូតដល់ពួកគេអាចបង្កើតប្រាក់ចំណូលបានដោយជោគជ័យ។
- ផ្តល់ការគាំទ្រដល់ជនរងគ្រោះឲ្យធ្វើសមាហរណកម្ម (ធ្វើចំណាកស្រុក) ប្រកបដោយសុវត្ថភាពទៅកាន់ទីកន្លែងផ្សេងៗ ដែលមានសក្តានុពលក្នុងការបង្កើនប្រាក់ចំណូល។ កម្មវិធីមួយចំនួនដូចជាការរស់នៅដោយឯករាជ្យ ឬការគាំទ្រមានកម្រិតរហូតដល់មនុស្សម្នាក់នោះអាចការពារខ្លួនពីការក្លាយខ្លួនទៅជាជនរងគ្រោះម្តងទៀត ។
- ការពង្រឹងជម្រើសនៃការគាំទ្រសម្រាប់ជនរងគ្រោះ ដែលបានរួចផុតពីអំពើជួញដូរមនុស្សនៅក្នុងសហគមន៍កំណើតរបស់ពួកគេតាមរយៈការបង្កើតសេវាគាំទ្រនៅតំបន់ដែលមានធនធានខ្ពស់។ សេវាគាំទ្រផ្សេងៗ រួមមានសេវាគាំទ្រលើការពារ ដូចជាផ្តល់ពត៌មានស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការបង្កើតប្រាក់ចំណូល និងសេវាគាំទ្រផ្សេងៗដើម្បីពង្រឹងស្ថានភាពគ្រួសារ។
- សហការជាមួយអង្គការផ្តល់សេវាគាំទ្រនៅតាមសហគមន៍ ដែលមានទីតាំងស្ថិតនៅក្នុងសហគមន៍កំណើតរបស់ជនរងគ្រោះដែលបានរួចផុតពីអំពើជួញដូរមនុស្ស ក្នុងការផ្តល់នូវសេវាគាំទ្រផ្សេងៗបន្ទាប់ពីសមាហរណកម្មឡើងវិញ ។
- បង្កើតជម្រើសនៃការផ្តល់សេវាគាំទ្រចល័ត ដើម្បីតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅសហគមន៍កំណើតរបស់ពួកគេ ដើម្បីពង្រឹងដំណើរការសមាហរណកម្ម/សមាហរណកម្មឡើងវិញ និងកាត់បន្ថយពេលវេលាដែលជនរងគ្រោះត្រូវការសម្រាប់ការថែទាំក្នុងមណ្ឌល ។
- ធ្វើការងារជាដៃគូជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (CCWC) ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាព និងផ្តល់នូវធនធាន ដើម្បីឲ្យពួកគេអាចផ្តល់នូវសេវាគាំទ្រក្នុងការធ្វើសមាហរណកម្ម និងសមាហរណកម្មឡើងវិញប្រកបដោយភាពជោគជ័យ។
- បង្កើតក្រុមគាំទ្រដែលមានវ័យដូចគ្នានៅក្នុងសហគមន៍ ដូច្នេះជនរងគ្រោះដោយអំពើជួញដូរមនុស្សអាចជួបពិភាក្សាគ្នាដើម្បីផ្តល់នូវការគាំទ្រចំពោះគ្នាទៅវិញទៅមក និងចែករំលែកនូវពត៌មានផ្សេងៗ ។

## យុទ្ធសាស្ត្រកម្មវិធីបច្ចុប្បន្នដែលគួរអោយកត់សម្គាល់

- ដំណើរការប៉ាន់ប្រមាណសុវត្ថិភាពក្នុងការធ្វើការប៉ាន់ប្រមាណបុគ្គល គ្រួសារ និងសហគមន៍សម្រាប់កត្តាងាយរងគ្រោះ និងសុវត្ថិភាព។ បង្កើតផែនការសុវត្ថិភាពសម្រាប់ជនរងគ្រោះ ដែលរួមមានការអប់រំអំពីកត្តាប្រថុយប្រថាន និង ធនធានផ្សេងៗ។
- ការគ្រប់គ្រងករណី ឬការបញ្ជូនក្រុមអន្តរាគមន៍ទៅកាន់សហគមន៍ជនរងគ្រោះ ដើម្បីសម្របសម្រួលសេវាគាំទ្រការធ្វើការប៉ាន់ប្រមាណ និងការធ្វើសមាហរណកម្មឡើងវិញ។

## ៤.៣. ការពិចារណាពិសេសសម្រាប់ក្រុមគោលដៅផ្សេងគ្នា

ប្រភេទនៃអំពើជួញដូរមនុស្ស ដែលមានច្រើនបំផុតនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ គឺអំពើជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ និងពលកម្ម។ នៅពេលដែលភាពរងគ្រោះនេះមានភាពដូចគ្នាច្រើន ការឆ្លើយតបចំពោះការថែទាំក្រោយពេលជួយសង្គ្រោះត្រូវការវិធីសាស្ត្រខុសៗគ្នា។ វិធីសាស្ត្រខុសៗគ្នាក៏តម្រូវឲ្យអនុវត្តចំពោះក្រុមដែលមានវ័យ និងភេទខុសគ្នា។

- ចំពោះជនរងគ្រោះដោយអំពើជួញដូរ ដើម្បីធ្វើអាជីវកម្មផ្លូវភេទ ការថែទាំយកចិត្តទុកដាក់ជាពិសេសគួរតែផ្តល់ដល់ពួកគេដើម្បីធ្វើការប៉ាន់ប្រមាណបុគ្គល គ្រួសារ និងសហគមន៍ ក្នុងគោលបំណងធានាសុវត្ថិភាពមុនពេលធ្វើសមាហរណកម្មឡើងវិញ។ កត្តាប្រថុយប្រថានគួរតែដោះស្រាយ ហើយផែនការសុវត្ថិភាពត្រូវបានបង្កើតឡើងមុនការវិលត្រឡប់របស់ជនរងគ្រោះ។
- ជនរងគ្រោះដោយអំពើជួញដូរ ដើម្បីកេងប្រវ័ញ្ចពលកម្ម មានបំណងចង់ត្រឡប់ទៅផ្ទះយ៉ាងឆាប់រហ័ស។ បំណងប្រាថ្នារបស់ពួកគេត្រូវបានផ្តល់ឲ្យ ដោយសារតែជនរងគ្រោះភាគច្រើនជាមនុស្សពេញវ័យ ហើយសេវាគាំទ្រក្នុងពេលវិលត្រឡប់ទៅវិញក៏ត្រូវបានផ្តល់ឲ្យយ៉ាងឆាប់រហ័សផងដែរ។ ប៉ុន្តែឱកាសនៃការទាក់ទងគួរតែត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ពត៌មានទាក់ទងនឹងសេវាគាំទ្រ និងធនធានដែលមាន។ សម្ភារៈដែលត្រូវបានសសេរ (សម្រាប់អ្នកមានចំណេះដឹងទាប) គួរតែត្រូវបានផ្តល់ ដើម្បីយកទៅផ្ទះ ប្រសិនបើជនរងគ្រោះមិនស្នាក់នៅក្នុងមណ្ឌលដើម្បីទទួលសេវាគាំទ្រ។
- ជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចពលកម្ម មានតម្រូវការខ្ពស់សម្រាប់ការគាំទ្របន្ទាន់រហូតដល់ពេលដែលប្រាក់ចំណូលរបស់គ្រួសារមានស្ថេរភាព បើមិនដូច្នេះទេ ភាពអសុវត្ថិភាព ឬការធ្វើចំណាកស្រុកឡើងវិញ អាចកើតឡើងយ៉ាងឆាប់រហ័សដើម្បីរកប្រាក់ចំណូល។ អង្គការគួរតែយកបញ្ហានេះមកពិចារណា ហើយបង្កើតយន្តការក្នុងការធ្វើអោយប្រាក់ចំណូលមានលំនឹងយ៉ាងឆាប់ រហ័ស។
- សេវាគាំទ្រមនុស្សពេញវ័យគួរតែត្រូវបានផ្តល់នៅសហគមន៍ នៅពេលដែលអាចធ្វើទៅបាន និងមានសុវត្ថិភាព។ សេវាគាំទ្រទាំងនេះគួរតែដាក់បញ្ចូល ការប៉ាន់ប្រមាណបែបមូលដ្ឋាន ការរៀបចំផែនការ

ករណី ជំនួយបន្ទាន់ ការប្រឹក្សាផ្នែកចិត្តសង្គម ការគាំទ្រនិងផ្តល់ព័ត៌មានផ្នែកច្បាប់ ការរកប្រាក់ចំណូល និងការធ្វើអោយប្រាក់ចំណូលមានលំនឹង និងការបញ្ជូនទៅកាន់ធនធានសហគមន៍។

- ចំពោះជនរងគ្រោះដែលជាកុមារ ស្ថានភាពគ្រួសារគួរតែត្រូវបានប៉ាន់ប្រមាណ មុននឹងបញ្ជូនកុមារទៅកាន់គ្រួសារ ព្រោះគ្រួសារមួយចំនួនបានចូលរួមចំណែកក្នុងការបញ្ជូនកុមារទៅធ្វើការ ធ្វើឲ្យមានការកេងប្រវ័ញ្ចផ្លូវភេទ ឬមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់នូវការថែទាំដល់កុមារ។ វាមិនមែនជាករណីដែលប្លែក ដែលកុមារចាំបាច់ត្រូវរកជម្រើសនៃការថែទាំនៅកន្លែងផ្សេងនោះទេ ប្រសិនបើស្ថានភាពនៃក្រុមគ្រួសាររបស់ពួកគេមិនមានភាពនឹងនរ។

## ៤.៤. ការទប់ស្កាត់

ទោះបីជាការសិក្សាស្រាវជ្រាវនេះមិនបានផ្តោតលើយុទ្ធសាស្រ្តនៃការការពារទប់ស្កាត់ក៏ដោយ វាក៏មានសារៈសំខាន់ក្នុងការកត់សម្គាល់ពីការងារមួយចំនួនដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែង ដើម្បីធ្វើការកាត់បន្ថយនូវអំពើជួញដូរមនុស្ស។ យុទ្ធសាស្រ្តនៃការការពារទប់ស្កាត់មួយចំនួន ត្រូវបានកំណត់ឡើងតាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលយុទ្ធសាស្រ្តទាំងនេះរួមមានដូចជា៖

- ផ្តល់សេវាគាំទ្រទាំងឡាយណា ដែលអាចជួយកាត់បន្ថយនូវភាពងាយរងគ្រោះ ដល់អ្នកដែលប្រឈមនឹងការរងគ្រោះដោយអំពើជួញដូរ ដូចជាសេវាគាំទ្រដែលអាចជួយក្នុងការកាត់បន្ថយភាពក្រីក្រ និងសេវាគាំទ្រដែលលើកកម្ពស់នូវការយល់ដឹងពីតួនាទីយែនឌ័ររបស់ក្មេងប្រុស និងក្មេងស្រី។
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំពលករ ដើម្បីឲ្យមានបទពិសោធន៍ក្នុងការធ្វើចំណាកស្រុក ដូចជាជួយគាំទ្រក្នុងការរៀបចំឯកសារផ្លូវច្បាប់ឲ្យបានសមស្រប ផ្តល់នូវលេខទូរសព្ទទំនាក់ទំនងពេលមានអាសន្ន និងជួយឲ្យមានការយល់ដឹងច្បាស់លាស់ពីកិច្ចសន្យាការងារ។

## ៥. សេចក្តីសន្និដ្ឋាន

ការប៉ាន់ប្រមាណចំពោះការថែទាំនៅក្នុងមណ្ឌល និងនៅតាមសហមគមន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស បានរកឃើញនូវការអនុវត្តល្អៗដ៏មានប្រសិទ្ធិភាពរបស់អ្នកផ្តល់សេវាគាំទ្រ និងឱកាសដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការពង្រឹងនូវវិធីសាស្ត្រឯកទេស ដើម្បីគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូររួមទាំងជនរងគ្រោះដែលជាបុរសផងដែរ។

ដំណើរការនៃការសិក្សាស្រាវជ្រាវនេះមានលក្ខណៈបែបគុណភាព ដោយរួមបញ្ចូលនូវការពិនិត្យឡើងវិញទៅលើការសិក្សាស្រាវជ្រាវថ្មីៗ ការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗដូចជា អាជ្ញាធររាជរដ្ឋាភិបាលនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ការសម្ភាសន៍ជាមួយអង្គការ/ស្ថាប័នដែលផ្តល់សេវាគាំទ្រដោយផ្ទាល់នៅតាមសហគមន៍ ការសម្ភាសន៍ជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងដៃគូអភិវឌ្ឍន៍នានាដែលផ្តល់អាទិភាពទៅលើការអន្តរាគមន៍លើអំពើជួញដូរមនុស្ស ។

នៅប្រទេសកម្ពុជា ការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើងជាចំបងនៅតាមមណ្ឌល ហើយផ្តោតលើក្រុមគោលដៅជាស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។ មណ្ឌលជាច្រើនមានទីតាំងនៅតាមតបន់គោលដៅនៃអំពើជួញដូរ ជាពិសេសនៅតាមទីក្រុង ឬទីប្រជុំជន ដើម្បីផ្តល់នូវសេវាគាំពារ និងសេវាថែទាំក្រោយពេលសង្គ្រោះដល់ជនរងគ្រោះ។

ការសិក្សាស្រាវជ្រាវលើការអនុវត្តដ៏មានប្រសិទ្ធិភាពទាក់ទងនឹងជម្រើសនៃការថែទាំ បានបង្ហាញថាការថែទាំនៅតាមមណ្ឌល គឺជាគម្រូនៃការថែទាំដែលមានការចូលចិត្តតិចតួចបំផុត ពីព្រោះវាមិនអាចបំពេញនូវតម្រូវការរបស់បុគ្គលម្នាក់ៗដែលជាជនរងគ្រោះ ហើយអាចធ្វើឲ្យខូចប្រយោជន៍ដល់ការអភិវឌ្ឍន៍ និងការរីកចម្រើន។ ជនរងគ្រោះដោយអំពើជួញដូរ បានរាយការណ៍ថាពួកគេចង់ទទួលសេវាគាំទ្រនៅតាមសហគមន៍ប្រសិនបើពួកគេមានសុវត្ថភាព។ ជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម កម្រនឹងស្នាក់នៅក្នុងមណ្ឌលណាស់ ហើយជាទូទៅពួកគេចង់វិលត្រឡប់ទៅសហគមន៍កំណើតវិញយ៉ាងឆាប់រហ័ស។

ទោះបីជាយ៉ាងណាក៏ដោយ តម្រូវការនៃសុវត្ថិភាព និងកិច្ចការពារភ្លាមៗ បានធ្វើឲ្យជម្រើសនៃការថែទាំនៅក្នុងមណ្ឌលក្លាយជាជម្រើសដ៏មានសារៈសំខាន់មួយ ជាពិសេសសម្រាប់កុមារ ឬជនរងគ្រោះដែលរួចផុតពីអំពើជួញដូរមនុស្ស ដែលស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដើម្បីធ្វើការប៉ាន់ប្រមាណលើស្ថានភាព និងបង្កើតផែនការរយៈពេលវែង។

អង្គការដែលមានមណ្ឌល ដែលមានទីទាំងនៅតាមតំបន់ទីប្រជុំជន ឬនៅតាមទីក្រុង ក៏មានបញ្ហាប្រឈមក្នុងការធ្វើសមាហរណកម្មជនរងគ្រោះទៅកាន់សហគមន៍របស់ពួកគេវិញ ពីព្រោះដោយសារអង្គការមានការិយាល័យនៅឆ្ងាយពីសហគមន៍កំណើតរបស់ជនរងគ្រោះ។ អង្គការក៏បានចាប់ផ្តើមពិនិត្យមើលវិធី

សាស្ត្រក្នុងការផ្តល់នូវសេវាគាំទ្រដែលមានលក្ខណៈប្រសើរជាង ដើម្បីផ្តល់ដល់ជនរងគ្រោះ ជាពិសេសនៅពេលដែលពួកគេមានសុវត្ថិភាព។ អង្គការជាច្រើនកំពុងផ្តល់នូវជម្រើសនៃការថែទាំដល់ជនរងគ្រោះ ដែលមានលក្ខណៈដូចជាក្រុមគ្រួសារ តាមរយៈការឲ្យកុមារដែលជាជនរងគ្រោះស្នាក់នៅជាមួយគ្រួសារចិញ្ចឹម ឬឲ្យជនរងគ្រោះស្នាក់នៅជាក្រុមតូចនៅក្នុងផ្ទះនៅតាមសហគមន៍។

អង្គការមួយចំនួនបានផ្តល់នូវសេវាគាំទ្រផ្សេងៗដល់ជនរងគ្រោះនៅតាមសហគមន៍របស់ពួកគេតែម្តង ។ អង្គការមួយចំនួនផ្សេងទៀតបានផ្តល់មណ្ឌល ដើម្បីធ្វើការប៉ាន់ប្រមាណរយៈពេលខ្លី និងបញ្ជូនបន្ត និងផ្តល់ពត៌មានទាក់ទងនឹងធនធានផ្សេងៗដល់ជនរងគ្រោះ មុនពេលបញ្ជូនពួកគេត្រឡប់ទៅសហគមន៍វិញ។

អ្វីដែលសំខាន់នោះគឺការបន្តនូវការផ្តល់ជម្រើសនៃការថែទាំដែលគួរតែមានសម្រាប់ជនរងគ្រោះដោយអំពើជួញដូរដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងធ្វើអាជីវកម្មផ្លូវភេទ។

ជម្រើសនៃការផ្តល់សេវាគាំទ្រ ឬការផ្តល់សេវាគាំទ្រនៅក្នុងមណ្ឌល គួរតែផ្តល់ដល់ជនរងគ្រោះក្នុងបរិយាកាសមួយដែលមិនមានភាពតឹងរឹងខ្លាំងពេក ប៉ុន្តែមានលក្ខណៈដូចជានៅក្នុងក្រុមគ្រួសារ។ កត្តាដែលធ្វើឲ្យជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលក្នុងរយៈពេលយូ គឺដោយសារការខ្វះខាតនូវការផ្តល់សេវាគាំទ្រនៅតាមសហគមន៍។ កាលណាជម្រើសនៃការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះនៅតាមសហគមន៍កាន់តែមានភាពប្រសើរ និងរឹងមាំ នោះតម្រូវការនៃមណ្ឌលសម្រាប់ជនរងគ្រោះនឹងមានការថយចុះ។ ហើយអ្វីដែលជារការពិតនោះគឺថាជនរងគ្រោះមួយចំនួនមិនចង់វិលត្រឡប់ទៅកាន់សហគមន៍ដើមរបស់ពួកគេវិញទេ ប៉ុន្តែពួកគេនឹងធ្វើចំណាកស្រុកទៅកាន់សហគមន៍ថ្មីដើម្បីស្វែងរកការងារធ្វើនៅទីនោះ។

ការចូលរួមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គួរតែត្រូវបានលើកកម្ពស់នៅគ្រប់ដំណាក់កាលនៃការផ្តល់សេវាគាំទ្រ។ ជនរងគ្រោះក៏គួរត្រូវបានទទួលនូវការគោរព និងផ្តល់នូវពត៌មានផ្សេងៗទាំងអស់ចាប់តាំងពីពេលដែលមានទំនាក់ទំនងដំបូង។ ការប៉ាន់ប្រមាណ និងការការប៉ាន់ប្រមាណឡើងវិញពីតម្រូវការ និងសុវត្ថិភាពគួរតែត្រូវបានធ្វើជាបន្តបន្ទាប់គ្រប់ដំណាក់កាលនៃការអន្តរាគមន៍ ហើយយកលទ្ធផលនៃការប៉ាន់ប្រមាណនេះដើម្បីធ្វើជាមូលដ្ឋាននៃការធ្វើផែនការករណីទាំងអស់។

# ឧបសម្ព័ន្ធក: ឯកសារយោង

Bassett, M. A. (2008). *What is the Potential of Cash Transfers to Strengthen Families impacted by HIV and AIDS.* Washington, DC: Joint Learning Initiative on Children and HIV/AIDS JLICA.

Bihler, M. (2010). *Report on Data Collection and Monitoring of Violence Against Women.* Phnom Penh: Ministry of Women's Affairs and GIZ.

Brown, E. (2007). *The Ties That Bind, Migration and Trafficking of Women and Girls for Sexual Exploitation in Cambodia.* Phnom Penh: IOM.

Caliber. (2007). *Evaluation of Comprehensive Services for Victims of Human Trafficking.* Washington: National Institute of Justice.

Chemonics. (2007). *The Rehabilitation of Trafficking Victims in Group Residential Facilities in Foreign Countries.* Washington: USAID.

Chemonics International. (2009). *USAID Anti Trafficking in Persons in Asia: A Synthesis.* Washington: USAID.

Clawson, H. J. (2009). *Study of HHS Programs Serving Human Trafficking Victims.* Washington: US Health and Human Services.

Derkes, A. (2006). *Review of a Decade of Research on Trafficking in Persons, Cambodia.* Phnom Penh: The Asia Foundation.

Devine, S. (2009). *Psychosocial and Mental Health Services for Survivors of Trafficking.* Bangkok: IOM.

Diokno, M. I. (2008). *Finding Justice: Legal Aid for Victims of Human Trafficking in Cambodia.* Phnom Penh: National Task Force Against Trafficking in Persons.

Duvvury, N. (2005). *Gender Based Violence and HIV AIDS in Cambodia.* Eschborn: GTZ.

ECPAT. (2012). *ECPAT Recent Publications*. Retrieved July 2012, from ECPAT: http://www.ecpatcambodia.org/index.php?menuid=1

GTZ. (2009). *Counter Human Trafficking in Cambodia.* Phnom Penh: GTZ.

Hagar and World Vision. (2007). *The Road Home.* Phnom Penh: Hagar & World Vision.

Hilton, A. (2008). *I Never Thought It Could Happen to Boys.* Phnom Penh: SSC.

Human Trafficking.org. (2012, July). *Combat Trafficking Protection*. Retrieved 2012, from Human Trafficking : http://www.humantrafficking.org/combat_trafficking/protection

ILO. (2006). *Child Friendly Guidelines for the Recovery and Reintegration of Trafficked Children.* Bangkok: ILO.

International Office of Migration. (2007). *Direct Assistance for Victims of Trafficking.* Geneva: IOM.

Maney, G. M. (2011). *Meeting the Needs of Survivors of Human Trafficking in the New York City Metropolitan Area.* New York: Lifeway Network.

Menzel, D. J. (2011). *Support for MoWA Judicial Police Baseline Report.* Phnom Penh: GIZ Access to Justice .

Ministry of Planning. (October, 2008). *Implementation Manual on the Procedures of Identifying Poor Households.* Phnom Penh, Cambodia: Ministry of Planning.

MoSVY. (2006). *Policy on Alternative Care.* Phnon Penh: MoSVY.

MoSVY. (2012). Draft Prakas on Minimum Standards on Residential Care for Victims of Trafficking. Phnom Penh: MoSVY.

MoSVY. (2012). Referral Directoy. *Services for Returned Migrants and Survivors of Traffickig*. Cambodia: MoSVY.

MoSVY. (August 2011). *Standards and Guidelines for the Care, Support and Protection of Orphans and Vulnerable Children.* Phnom Penh.

MoSVY. (May 2008). *Minimum Standards on Alternative Care for Children.* Phnom Penh.

Sam McLeod. (2007). *John Bowlby Maternal Depravation*. Retrieved October 12, 2012, from Simply Psychology: http://www.simplypsychology.org/bowlby.html

SSC. (2011). SSC Kandal Program Evaluation. Social Services of Cambodia.

Tolfree, D. (2003). *Community Based Care for Separated Children.* Stockholm: Save the Children, Sweden.

Tsugami, F. (2012). *Social Inclusion of Child Survivors of Human Trafficking in Cambodia.* Phnom Penh: ICIRD.

United Nations. (2000). *Protocol to Prevent, Suppress and Punish Trafficking in Persons.* New York: United Nations.

US Department of State. (2011). *2011 Trafficking in Persons Report Cambodia.* Washington: US Department of State.

US Department of State. (2012). *2012 Trafficking in Persons Report Cambodia.* Washington: US Department of State.

# ឧបសម្ព័ន្ធខ: បញ្ជីរាយនាមអ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ

| **PHNOM PENH<br>AND NATIONAL LEVEL** | **Position of Interviewee** |
|---|---|
| **Government Ministries** | |
| Ministry of Women Affairs (MoWA) | Secretary of State in Charge of GBV<br>Under-secretary of State in Charge of GBV<br>Director General of Social Development<br>Social Development Deputy Director |
| Ministry of Interior (MoI) | Secretary of State<br>Police Headquarters |
| Ministry of Social Affairs, Veterans and Youth Rehabilitation (MoSVY) | Under Secretary of State<br>Staff in Charge of Trafficking and Re-integration Services |
| Ministry of Labor and Vocational Training (MLVT) | Secretary of State |
| Ministry of Health (MoH) | Secretary of State |
| **Development Partners** | |
| United Nations Interagency Project on Human Traffiking (UNIAP) | National Project Coordinator |
| United Nations Children’s Fund (UNICEF) | Child Protection Specialist |
| International Labor Organization (ILO) | Technical Officer |
| International Office of Migration (IOM) | Acting Director |
| **Civil Society Organizations** | |
| Cambodia Women's Development Agency | Acting Executive Director |
| Women Organization for Modern Economy and Nursing (WOMEN) | Program Manager |
| Women's Development Association (WDA) | Executive Director |
| LICADHO | Monitoring Coordinator |
| Damnok Toek | Executive Director |
| Strey Khmer Organization | Program Manager |
| Gender and Development Cambodia | Director |
| World Vision | Child Protection Manager |
| Transitions Global | Country Director<br>Clinic Director<br>Founders (2) |
| SISHA | Executive Director |
| Cambodian Children Against Starvation and Violence (CCASVA) | Director |
| Legal Support for Women and Children (LSCW) | Program Manager |
| Hagar | Case Management Operation Technical Advisor<br>Shelter Managers |
| Cambodia Women's Crisis Center (CWCC) | Executive Director |

| | |
|---|---|
| Chab Dai Coalition | Prevention Program Director |
| Legal Aid of Cambodia (LAC) | Program Manager |
| Cambodia Defenders Project (CDP) | Program Manager |
| Acting for Women in Distressing Situations (AFESIP) | Center Manager |
| Social Services of Cambodia (SSC) | Executive Director |
| Transcultural Psycho-social Organization (TPO) | Project Manager |
| End Child and Prostitution Child Pornography and Trafficking (ECPAT) | Executive Director |
| Cambodia Center for the Protection of Children's Rights (CCPCR) | Shelter in Svay Rieng Province |
| World Hope International | Anti-Trafficking Program Director<br>Counselor<br>Social Affairs/Social Worker |
| International Justice Mission (IJM) | Field Office Director |
| **BATTAMBANG** | |
| **Government** | |
| **Provincial Level** | |
| Department of Social Affairs Veterans and Youth Rehabilitation (DoSVY) | Cheif of Department |
| Department of Women's Affairs | Director<br>Director Legal Protection<br>Deputy Legal Protection |
| Department of Labour and Vocational Training | Director |
| Women and Children's Consultative Committee (WCCC) | WCCC Director |
| **Moung Ruessei District** | |
| Office of Social Affairs, Veterans and Youth Rehabilitation | Office Director, Social Worker |
| Office of Women's Affairs | Director |
| **Prey Svay Commune** | |
| Commune Committee for Women and Children | CCWC Officer |
| Commune Chief | Commune Staff |
| **ThmaKoul District** | |
| Office of Women's Affairs | DoWA Officer |
| Office of Social Affairs, Veterans and Youth Rehabilitation | Director |
| Women and Children's Consultative Committee | CCWC Representative<br>Deputy District Governor |
| **Boeng Pring Commune** | |
| Commune Committee for Women and Children | CCWC Representative |
| Commune Chief | Commune Chief |
| **Phnom Proek District** | |
| Office of Social Affairs, Veterans and Youth Rehabilitation | District Social Worker |

| | |
|---|---|
| Women and Children's Consultative Committee (Deputy District Governor?) | Director<br>Women affair officer<br>Deputy District Governor |
| **Chakrei/Bour Commune** | |
| Commune Chief | Commune Chief |
| **Civil Society Organizations** | |
| ADHOC | Coordinator |
| Banteay Srey | Director<br>Shelter Staff |
| Legal Aid of Cambodia | Assistant Lawyer |
| LICHADO | Provincial Coordinator |
| COSECAM | Field Case Manager |
| World Vision | Project Manager |
| KOMAR RIKREAY (KMR) | Executive Director<br>Shelter Director |
| Children and Poor Communities Development Organization | |
| Banteay Srey | Deputy CCWC |
| National Employment Agency (NEA) | Team Leader of Battambang Job Center |
| **BANTEAY MEANCHEY** | |
| **Government** | |
| **Provincial Level** | |
| Department of Social Affairs Veterans and Youth Rehabilitation | Deputy Director |
| Ministry of Labor and Vocational Training | Deputy Director |
| Department of Women's Affairs | Director |
| Women and Children's Consultative Committee | Director |
| **Malai District** | |
| Department of Social Affairs, Veterans and Youth Rehabilitation | Officer |
| Department of Women's Affairs | Director |
| Women and Children's Consultative Committee | Director CCWC<br>Deputy District Governor |
| **OuSralau Commune** | |
| Commune Committee for Women and Children | CCWC Focal Point |
| Commune Council | Chief |
| **PoiPet District** | |
| Department of Social Affairs, Veterans and Youth Rehabilitation | DoSVY-Ou Chreu District (No DoSVY in Poi Pet) |
| Department of Women's Affairs | Director DoWA |
| PoiPet Transit Center | Director of PTC |
| **CIVIL SOCIETY ORGANIZATIONS** | |
| LICADHO | Human Rights Monitor |

| | |
|---|---|
| Legal Aid of Cambodia | Director |
| CAMBODIAN HOPE ORGANIZATION (CHO) | Director |
| CAMBODIAN WOMEN'S CRISIS CENTER (CWCC) | Shelter Manager<br>Deputy Shelter Manager<br>Counselor |
| **SIEM REAP** | |
| **Government** | |
| **Provincial Level** | |
| Department of Social Affairs Veterans and Youth Rehabilitation | Deputy PDoSVY |
| Department of Women's Affairs | Director DPoWA |
| Anti-Human Trafficking Police | Lieutenant Colonel Deputy of Police Commissioner |
| Women and Children's Consultative Committee | Director CCWC |
| **SoutrNikom District** | |
| Office of Social Affairs, Veterans and Youth Rehabilitation | Deputy |
| Office of Women's Affairs | Director |
| Women and Children's Consultative Committee (Deputy District Governor?) | Director |
| Anti-Human Trafficking Police | District Police |
| **Banteay Srei District** | |
| Office of Social Affairs, Veterans and Youth Rehabilitation | Officer |
| Women and Children's Consultative Committee | Director |
| **SvayLeu District** | |
| Office of Social Affairs, Veterans and Youth Rehabilitation | Officer |
| Office of Women's Affairs | |
| Anti-Human Trafficking Police | Deputy District Police Commissioner |
| Women and Children's Consultative Committee | Director |
| **Boeng Mealea Commune** | |
| Commune Committee for Women and Children | Focal Point |
| **Civil Society Organizations** | |
| AFESIP | Center Manager<br>Head of AIDS Program in Region 1 |
| Cambodian Centre for Protection of Children's Rights (CCPCR) | Project Manager (Lotus House) |
| Legal Aid of Cambodia (LAC) | Lawyer |
| World Hope International | Field Operation Manager |
| ADHOC | Provincial Coordinator |
| Cambodia Women's Crisis Center Center (CWCC) | Siem Reap Regional Manager<br>Shelter Officer |
| **Focus Groups with Survivors of TIP** | |

| | |
|---|---|
| Cambodian Center for the Protection of Children's Rights (CCPCR) Lotus House | Siem Reap |
| Cambodian Women's Crisis Center – Services to Male Survivors of TIP | Kampong Thom |
| World Hope International | Siem Reap |
| Ou Slor Lao Commune Community Grop | Banteay Meanchey |
| AFESIP | Siem Reap |
| Cambodian Women's Crisis Center | Banteay Meanchey |
| AFESIP | Phnom Penh |
| Cambodian Women's Crisis Center | Siem Reap |
| Cambodian Center for the Protection of Children's Rights (CCPCR) | Svay Rieng |
| **Focus Group with Service Providers** | |
| Damnouk Toek | |
| Cambodian Center for the Protection of Children's Rights (CCPCR) | |
| Transitions | |
| Cambodian Women's Crisis Center | |
| WOMEN | |
| World Hope International | |
| HagarInternational | |

## ឧបសម្ព័ន្ធគ: គោលការណ៍ណែនាំអំពីការសម្ភាសន៍

**អង្គការ វីនរ៉ក អន្តរជាតិ** (Winrock International)

ការប៉ាន់ប្រម៉ាណអំពី ជម្រក ហើយនឹង វិធីសាស្រ្តនៃការផ្តល់ការថែទាំងនៅសហគមន៍
ដើម្បីបង្កើតនូវវិធីសាស្រ្តជាក់លាក់មួយ ក្នុងថែទាំជនរងគ្រោះ

គោលការណ៍ណែនាំ អំពីការសម្ភាសន៍ ដៃគូអភិវឌ្ឍន៍នានា

Development Partners

<u>ប្រមូលឯកសារបស់អង្គការ, របាយការណ៍ប្រចាំឆ្នាំ, និង ឯកសារបោះពុម្ពផ្សេងៗ</u>

| A. ពត៌មានអំពីការសម្ភាសន៍: | |
|---|---|
| ១. ឈ្មោះអ្នកសម្ភាសន៍: | ២. កាលបរិច្ឆេទនៃសម្ភាសន៍: |
| ៣. គូសរង្វង់មួយ:<br>A. ថ្នាក់ជាតិ<br>B. ថ្នាក់ខេត្ត<br>C. ថ្នាក់ស្រុក | ៤.<br>ខេត្តដែលកំពុងចុះសម្ភាសន៍: គូសរង្វង់មួយ<br>A. ភ្នំពេញ<br>B. បន្ទាយមានជ័យ<br>C. សៀមរាប<br>D. បាត់ដំបង |
| B. ពត៌មានអំពីភ្នាក់ងារ/អាជ្ញាធររាជរដ្ឋាភិបាល | |
| 1. ឈ្មោះអ្នកផ្តល់បទសម្ភាសន៍: | 2. តួនាទី: |
| 3. ឈ្មោះរបស់អង្គការ: | 4.<br>ឆ្នាំដែលអង្គការរបស់អ្នកបានបង្កើតឡើង: (ប្រសិនសមស្រប) |
| ៥. បេសកម្ម/ទស្សនវិស័យរបស់អង្គការ: | |

<table>
<tr><td>៥. គម្រោងថវិការប្រចាំឆ្នាំ</td><td colspan="2">៦. ប្រភពមូលនិធិសំខាន់ៗ</td></tr>
<tr><td colspan="2">7. តំបន់គោលដៅក្នុងការផ្តល់សេវាកម្ម (ខេត្ត និង ស្រុក)</td><td>8. ក្រុមគោលដៅ</td></tr>
<tr><td colspan="3">C. ការផ្តល់សេវាកម្មផ្សេងៗដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស (TIP):</td></tr>
<tr><td colspan="3">1. តើអ្វីខ្លះដែលជាតម្រូវការមូលដ្ឋានរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស?<br>តើមានតម្រូវការអ្វីដែលខុសគ្នាជាពិសេស សម្រាប់ជនរងគ្រោះជាបុរស ឬ ស្ត្រីទេ ឬ កុមារទេ?</td></tr>
<tr><td colspan="3">2. តើ អង្គភាពរបស់អ្នក បានប្រើវិធីសាស្ត្រអ្វី ក្នុងការឆ្លើយតបនឹងតម្រូវការផ្សេងៗ (សេវាកម្មដែលបានផ្តល់) របស់ជនរងគ្រោះ ដោយសារការជួញដូរមនុស្ស?<br>ហេតុអ្វីបានជាប្រើ វិធីសាស្ត្រនេះ?<br>តើអ្វីខ្លះជាចំណុចខ្លាំង និង/ ឬជាបញ្ហាប្រឈមរបស់វា?</td></tr>
</table>

៣. តើអ្នកកំណត់អត្តសញ្ញាណ (អង្គការដែលអ្នកផ្តល់មូលនិធិ ។ល។) មនុស្សម្នាក់ជាជនរងគ្រោះដោយសារ ការជួញដូរមនុស្សបានយ៉ាងដូចម្តេច?

*តើអ្នកមានពីធីការជាលាយលក្ខណ៍អក្សរ នៅកន្លែង ឬ លក្ខណៈវិនិច្ឆ័យដើម្បីកំណត់អត្តសញ្ញាណ ជនរងគ្រោះទេ?*

*តើជនរងគ្រោះដោយសារការជួញដូរមនុស្ស អាចរកឃើញសេវាកម្មផ្សេងៗបានយ៉ាងដូចម្តេច?*

៤. ប្រភេទជនរងគ្រោះដែលស្វែងរកសេវាកម្មផ្សេងៗ និង ភាពជោគជ័យក្នុងការបញ្ជូនទៅរកសេវាកម្ម (ប្រសិនជាមាន)

| ប្រភេទក្រុមជនរងគ្រោះ | ចំនួនជនរងគ្រោះដែលស្វែងរកសេវាកម្ម | ចំនួនជនរងគ្រោះដែលត្រូវបានបញ្ជូនទៅរកសេវាកម្ម | ចំនួនជនរងគ្រោះដែលបដិសេធន៍មិនទទួលសេវាកម្ម | យោបល់ ឬ កំណត់សំគាល់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

៥. ជនរងគ្រោះដោយសារការ ជួញដូរដែលបានទទួលសេវាកម្ម

| 1. ទីតាំងដែលស្ថិតនៅ | 2. ប្រភេទក្រុមជនរងគ្រោះ | 3. ចំនួនសរុបភេទ ប្រុស | | 4. ចំនួនសរុបភេទស្រី | |
|---|---|---|---|---|---|
| | | ក្រោម 18 | លើ 18 | ក្រោម 18 | លើ 18 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

សូមប្រមូលរបាយការណ៍ស្ថិតិផ្សេងៗ របាយការណ៍ប្រចាំឆ្នាំ ឬ របាយការណ៍ផ្សេងៗទៀតដែលមាន ឬ ខិតបណ្ណ័សម្រាប់ឆ្នាំកន្លងទៅរបស់អង្គការ ឬ អង្គការដែលជាម្ចាស់ជំនួយ។ ប្រសិនជាពួកគេមិនមានរបាយការណ៍ខាងលើទេ ស្នើរសុំស្ថិតិជនរងគ្រោះដែលមាន។ ស្នើសុំផងដែរនូវឯកសារព្យាករណ៍អំពីចំនួនជនរងគ្រោះនៅប្រទេសកម្ពុជា។

## ៦. ប្រសិនជាអ្នកផ្តល់សេវាកម្មដែលផ្តល់ដោយផ្ទាល់ តើមានប្រភេទអ្វីខ្លះ?

| | Yes | No | បញ្ជូន | យកកម្រៃពីជនរងគ្រោះ | មាន ខ្ទង់ថវិការរបស់អង្គការសម្រាប់ចំណាយលើសេវានីមួយៗ ឬ ខ្ទង់ថវិការសម្រាប់ចំណាយលើជនរងគ្រោះម្នាក់ៗ | ប្រុស ? | ស្រី? | អាយុកំណត់? | សូមរៀបរាប់ឈ្មោះអង្គការដែលបញ្ជូនទៅ ឬ យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| 1.ការគាំទ្រផ្នែកចិត្តសាស្រ្តសង្គម | | | | | | | | | |
| 2. ការថែទាំសុខភាពផ្លូវកាយ | | | | | | | | | |
| 3. អាហាររូបត្ថម្ភ | | | | | | | | | |
| 4. បំណិនជីវិត និង បណ្តុះបណ្តាលវិជ្ជាជីវៈ | | | | | | | | | |
| 5. សុវត្ថិភាពសេដ្ឋកិច្ច | | | | | | | | | |
| 6. ការអប់រំ | | | | | | | | | |
| 7. ឯកសារសំគាល់អត្តសញ្ញាណ | | | | | | | | | |
| 8.ពត៌មានអំពីច្បាប់ | | | | | | | | | |
| 9. និតិវិធីផ្លូវច្បាប់ | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 10. ជម្រក | | | | | | | | | |
| 11. ផ្សេងៗ | | | | | | | | | |
| 12. | | | | | | | | | |
| 13. | | | | | | | | | |

*របាយការណ៍ចំណាយពិបាកក្នុងការស្នើរសុំ ប៉ុន្តែស្នើសុំទិន្នន័យពាក់ព័ន្ធដែលមាន។

D. ប្រសិទ្ធិភាពនៃសេវាកម្មផ្សេងៗ

1. តើសេវាកម្មផ្សេងៗដែលអង្គការរបស់អ្នកបានផ្តល់មូលនិធិ (ឬសេវាកម្មទាំងនោះនៅមាន) បានឆ្លើយតប នឹងតម្រូវការក្រុមគោលដៅទេ?

*ប្រសិនជាបានឆ្លើយតប តើហេតុអ្វី? ប្រសិនជាមិនបានឆ្លើយតប តើហេតុអ្វី?*

*តើមានភស្តុតាង (ប្រសិនជាមាន) ដែលអ្នកមានដើម្បីគាំទ្រដល់គំរូរបស់អ្នក?*

*តើអង្គការរបស់អ្នកបានធ្វើការវាយតម្លៃផ្សេងៗទេ?*

២. តើអង្គការសំខាន់ណាខ្លះ/អ្នកផ្តល់សេវាកម្មណាខ្លះ ដែលអ្នក (អង្គការដែលអ្នកបានផ្តល់មូលនិធិ) បានបញ្ជូនជនរងគ្រោះដើម្បីទទួលបានជំនួយ?

*តើអ្នក/ពួកគេ បានបញ្ជូនជនរងគ្រោះទៅរកជំនួយយ៉ាងដូចម្តេច?*

*នៅពេលណា (សម្រាប់ហេតុផលអ្វី ឬ សេវាកម្មអ្វី) ដែលអ្នក/ពួកគេធ្វើការបញ្ជូនជនរងគ្រោះទៅរកសេវាកម្មថ្មី?*

*តើការបញ្ជូនទទួលបានជោគជ័យទេ?*

**៣. តើអ្វីខ្លះដែលជាកង្វះខាត (បញ្ហាប្រឈម) ក្នុងការផ្តល់សេវាកម្មដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស?**

*តើការកំណត់អត្តសញ្ញាណជនរងគ្រោះសមស្រប ឬ ងាយស្រួលទេ?*

*តើប្រភេទ ឬ ក្រុមជនរងគ្រោះណាខ្លះដែលកំពុងទទួលសេវាកម្មពីមណ្ឌល (ប្រុស, ស្រី, ពលកម្ម ។ល។)?*

*តើប្រភេទសេវាកម្មអ្វីខ្លះដែលនៅខ្វះខាត ឬ មិនមានសម្រាប់ជនរងគ្រោះ?*

*តើ កង្វះខាត់អ្វីផ្សេងៗទៀត ដែលខ្វះខាត់យូរមកហើយ?*

**4. តើប្រភេទសេវាកម្ម/យុទ្ធសាស្រ្តអ្វីខ្លះ ដែលអ្នកចង់ផ្តល់អនុសាសន៍ដើម្បីបំពេញកង្វះខាត ក្នុងការផ្តល់សេវាកម្មដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស?**

*តើអ្នកមានផែនការ ឬ តើអ្នកបានដឹងថាមានផែនការផ្សេងៗក្នុងការបង្កើតសេវាកម្មទាំងឡាយ ដើម្បីបំពេញ កង្វះខាតទេ?*

| |
|---|
| 5. តើអង្គការរបស់អ្នក (ឬ អង្គការដែលអ្នកផ្តល់មូលនិធិ) រក្សាការកត់ត្រាអំពីស្ថិតិជនរងគ្រោះទេ? ប្រសិនជាមាន តើមានចំនួនជនរងគ្រោះប៉ុន្មាននាក់? |
| ៦. តើមានពត៌មានផ្សេងៗ ដែលពួកយើងមិនសួរ ដើម្បីចែករំលែកទេ? ឧទា. អាទិភាពអ្វីខ្លះក្នុងការផ្តល់មូលនិធិ/ យុទ្ធសាស្ត្រផ្សេងៗ |

| |
|---|
| ៧. ការកត់ត្រាផ្សេងៗ |
| ៨. អ្នកសម្ភាសន៍កត់ត្រាផ្សេងៗបន្ទាប់ពីសម្ភាសន៍: ចំណុចផ្សេងៗ ត្រូវពិនិត្យឡើងវិញ ឬ ការប្រមូលពត៌មាន បន្ថែម ឬ ការបញ្ជាក់ផ្សេងៗ។ |

## អង្គការវីនរ៉ក អន្តរជាតិ (Winrock International)
## ការប៉ាន់ប្រមាណអំពីវិធីសាស្រ្តនៃការផ្តល់ការថែទាំងនៅ មណ្ឌល ហើយនឹង នៅសហគមន៍ ដើម្បីបង្កើតនូវវិធីសាស្រ្តជាក់លាក់មួយ ក្នុងថែទាំជនរងគ្រោះ

### គោលការណ៍ណែនាំ អំពីការពិភាក្សាជាក្រុម – ក្រុមជនរងគ្រោះដោយការជួញដូរ
### Focus Group Discussion Guide TIP Victims

នេះជាគោលការណ៍ណែនាំដើម្បីពិភាក្សាជាមួយក្រុមជនរងគ្រោះដោយការជួញដូរ។ ដំណើរការនេះត្រូវបានបង្កើតឡើង ដើម្បីណែនាំកិច្ចពិភាក្សាដែលដឹកនាំដោយអ្នកសម្របសម្រួលដែលមានបទពិសោធន៍។ គោលបំណងនៃកិច្ចពិភាក្សានេះគឺ ដើម្បីជួយអោយសមាជិកដទៃទៀតនិយាយដោយសេរី ហើយយើងណែនាំពួកគេពិភាក្សាគ្នាលើប្រធានបទផ្សេងៗដែលបានកំណត់។ ពេលខ្លះ មានន័យថា ការពិភាក្សានឹងមិនទៅតាមលំដាប់លំដោយទេ។ ប៉ុន្តែវាមិនមានបញ្ហាអ្វីទេ។

មានប្រធានបទចំនួន៣ដែលយើងចង់លើកមកពិភាក្សា។ បន្ទាប់មកប្រធានបទនីមួយៗត្រូវបានបង្កើតជាបញ្ជីរសំណួរស្ទាបស្ទង់ផ្សេងៗ។

### ការអាននូវ ការពន្យល់ណែនាំ ទៅដល់ក្រុមៈ

នៅថ្ងៃនេះ ខ្ញុំមកទីនេះតំណាងអោយអង្គការវីនរ៉ក់ អន្តរជាតិ ដើម្បី ពិភាក្សាជាមួយអ្នកអំពីបទពិសោធន៍របស់អ្នកក្នុងការទទួលបានសេវាកម្មផ្សេងៗ។ អ្វីដែលយើងផ្តោតការចាប់អារម្មណ៍គឺ ដើម្បីចង់ដឹងអំពីគំនិតរបស់អ្នក ថាតើសេវាកម្មដែលអ្នកបានទទួលមានប្រយោជន៍យ៉ាងដូចម្តេច និង មធ្យោបាយផ្សេងៗដែលអាចធ្វើឲ្យសេវាកម្មទាំងនោះមានភាពល្អប្រសើរឡើង។ ជាមួយគ្នានេះដែរ ពួកយើងក៏ចង់ពិភាក្សា ត្រួសៗអំពីប្រភេទសេវាកម្មផ្សេងៗដែលអ្នកបានទទួល និង មូលហេតុផ្សេងៗដែលអ្នកគិតអំពីវា។

ពត៌មានដែលយើងប្រមូលបាន នឹងត្រូវបានប្រើដើម្បីជួយពួកគេក្នុងវាយតម្លៃការងាររបស់យើង និងដើម្បីបង្កើតនូវអាទិភាពផ្សេងៗនៅពេលអនាគត។ ការចូលរួមរបស់អ្នកក្នុងក្រុម

នេះគឺដោយស្មគ្រ័ចិត្ត ហើយនៅពេលណាក៏ដោយ ប្រសិនជាអ្នកមិនចង់ឆ្លើយនូវសំណួរ ឬក៏អ្នកចង់បញ្ឈប់ការចូលរួមរបស់អ្នក គឺមិនមានបញ្ហាអ្វីទេ។

កិច្ចពិភាក្សានេះ នឹងមានរយៈពេល១ម៉ោង៣០នាទី។ ខ្ញុំមានប្រធានបទជាក់លាក់មួយចំនួន ដើម្បីពិភាក្សា។ ខ្ញុំនឹងលើកប្រធាននោះ ហើយ ខ្ញុំចង់អោយអ្នកទាំងអស់គ្នាបញ្ចេញគំនិតយោបល់រៀងៗខ្លួន។ ការឆ្លើយមិនចាំបាច់ជាលក្ខណៈផ្លូវការទេ ឬ តាមលំដាប់លំដោយដែរ។ ប៉ុន្តែយើងចង់អោយអ្នករាល់គ្នាមានលទ្ធភាពពិភាក្សាទាំងអស់គ្នា ពេលខ្លះប្រហែលជាខ្ញុំត្រូវចូលរួមជជែកជាមួយអ្នកទាំងអស់គ្នាដែរដើម្បីផ្តល់ឪកាសដល់អ្នកបន្ទាប់ក្នុងការបញ្ចេញយោបល់ ឬ ដើម្បីឈានចូលទៅប្រធានបទបន្ទាប់ទៀត។ ការងាររបស់ខ្ញុំគឺធានាថា យើងបានពិភាក្សាគ្នាគ្រប់ប្រធានបទនៅកំឡុងពេលនេះ។

យើងចង់ប្រើចម្លើយទាំងនេះដែលយើងប្រមូលបាន ដើម្បីជួយដល់អង្គការវីនរ៉ក់ (Winrock) ក្នុងការស្វែងយល់ពីសេវាកម្មផ្សេងៗដែលត្រូវការសម្រាប់បុគ្គលទាំងឡាយ ដែលធ្លាប់ទទួលរងគ្រោះដោយការជួញដូរ។ ប្រសិនជាមិនមានបញ្ហាអ្វីទេ យើងនឹងដកស្រង់ពាក្យពេជ្ររបស់អ្នកដែលបាននិយាយប្រាប់យើង នៅក្នុងរបាយការណ៍នេះ។ ទោះជាយ៉ាងណាក៏ដោយ យើងប្រហែលជាដក់ស្រង់យោបល់របស់អ្នកខ្លះៗ ប៉ុន្តែមិនបញ្ចេញឈ្មោះរបស់ឡើយ។

**ការកត់ត្រា.**អ្នកកត់ត្រាគួរ បំពេញពត៌មានមូលដ្ឋានរបស់អ្នកចូលរួម។ អ្នកកត់ត្រាគួរកត់ត្រាពាក្យពេជ្រទាំងស្រុងរបស់អ្នកចូលរួមដែលគាត់បាននិយាយ តាមលទ្ធភាពដែលអាចទៅបាន។ សូមប្រើក្រដាស់បន្ថែមទៀតប្រសិនជាចាំបាច់ត្រូវកត់ត្រាផ្សេងៗ។

**ខេត្តៈ ……………………………………… អង្គការ/អង្គភាពៈ……………………………………………………**

**កាលបរិច្ឆេទ: ………………………………………… អ្នកសម្របសម្រួល…………………………………**

**បញ្ជីរឈ្មោះអ្នកចូលរួមៈ**

| ល.រ | ឈ្មោះ | ភេទ | អាយុ | ប្រភេទនៃការរងគ្រោះដោយការជួញដូរ(TIP) |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| ១០ | | | | |

**សូមសួរ ដោយប្រើសំណួរ ហេតុអ្វី ដោយរបៀបណា/យ៉ាងដូចម្តេច នៅពេលណា នៅទីកន្លែងណា ចំនួនប៉ុន្មាន?**

**១. ការណែនាំ**

- ឈ្មោះ
- អាយុ (ប្រសិនជាអាចប្រាប់បាន)

**២. ការទទួលបានការជំនួយ**

- តើជំនួយ (សេវាកម្ម) ប្រភេទណាខ្លះដែលអ្នកធ្លាប់ទទួលបាន?

  តើអ្នកស្នាក់នៅក្នុងមណ្ឌល ឬ នៅសហគមន៍?
- នៅពេលអ្នកទៅពឹងគេអោយជួយ តើអ្នកបានទៅរកនៅកន្លែងណាដំបូងគេដើម្បីអោយគេជួយ? តើអ្នកបានទៅរកការពឹងអោយជួយនោះ ដោយរបៀបណា?

- តើគន្លឹះសំខាន់អ្វី ដែលធ្វើអោយអ្នកទៅពឹងគេអោយជួយ? តើការសម្រេចចិត្តទៅពឹងគេអោយជួយគឺជាគំនិតរបស់អ្នកម៉ែនទេ? ឬ មួយក៏មានគេណែនាំទៅរកសេវាកម្មទាំងនោះ?

- តើអ្វីខ្លះដែលជាឧបសគ្គ/ការលំបាក ក្នុងការទៅពឹងគេអោយជួយ?

## ៣. ប្រសិទ្ធិភាពនៃទទួលបានជំនួយ

- តើការជួយ បានឆ្លើយតបនឹងអ្វីដែលអ្នកត្រូវការដែរឬទេ? (សុវត្ថិភាព, ជម្រក, ច្បាប់, ផ្នែកពេទ្យ, ផ្សេងៗទៀត?)

- ចុះការជួយជ្រុំជ្រែងដែលអ្នកទទួលបាន តើមានប្រយោជន៍ ឬ គ្មានប្រយោជន៍?

- តើអ្នកមានអារម្មណ៍យល់ទេ?

- តើជំនួយអ្វីដែលអ្នកត្រូវការ តែវាមិនមាន?

- តើពត៌មានរបស់អ្នកត្រូវបានគេជួយរក្សាការសម្ងាត់ទេ?

## ៤. កិច្ចសហប្រតិបត្តិការ និង ការបញ្ជូន

- តើអ្នកធ្លាប់បានគេបញ្ជូន/ណែនាំទៅអង្គការផ្សេងទៀតទេ? តើអង្គការណា?
- តើការបញ្ជូននោះដូចម្តេចដែរ? តើអ្នកធ្លាប់បានគេបញ្ជូន/ណែនាំទៅអង្គការផ្សេងទៀតចំនួនប៉ុន្មានដងដែរ?

- តើការបញ្ជូននោះទទួលបានជោគជ័យទេ? តើអ្នកអាចមានលទ្ធភាពទទួលបានសេវាកម្មទាំងនោះទេ?

- តើឧបសគ្គអ្វីខ្លះដែលធ្វើអោយអ្នកមិនអាចទទួលបាន សេវាកម្មទាំងនោះ?
    - ចម្ងាយឆ្ងាយ ឬ ការធ្វើដំណើរ
    - ការចំណាយផ្សេងៗ
    - ការភ័យខ្លាច។ល។